# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣២ លេខ ១១ វិច្ឆិកា

ព. ស. ២៥០៣ គ. ស. ១៩៦០

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* ទំព័រ


- ពុទ្ធជីវប្បវត្តិ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ១២០១
- តម្លៃនៃព្រះពុទ្ធសាសនា លោក ស៊្រេង-ធូរ រៀបរៀង . . . . ១២២០
- ព្រះអភិធម្មបិដក គម្ពីរព្រះកថាវត្ថុ (តមក) លោក ប៊ូ-ប៉ូ រៀបរៀង . ១២៣៨
- មធុរសវាហិណី (តមក) សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ . . . . ១២៤៨
- មហោសថជាតក (តមក) លោក អ៊ឹម-កន បម្លងពីសាស្ត្រស្លឹករឹត ព្រះពុទ្ធវង្ស កឹម-ត្នូរ ពិនិត្យ . . . . . . ១២៥៥


*ផ្នែកអក្សរសាស្ត្រ*


- រឿងមរណមាតា (តមក) លោក ប៊ី-សុវណ្ណ បម្លងពីសាស្ត្រស្លឹករឹត . . ១២៦១
- រឿងតាងសក់ក្រអូប លោក ញ៉ែម-ទឹម រៀបរៀង តាមឯកសារទំនៀមទម្លាប់ ១២៧១
- រឿងសង្គ្រាមរវាងតិង្គក់នឹងព្រះព្រហ្ម លោក ឈាង-ហាប់-អាន រៀបរៀង . ១២៧៧
- រឿងព្រេងប្រទេសអ៊ុយក្រែន ភិក្ខុ ម៉ែន-រៀម ប្រែបាកភាសាអង់គ្លេស . . . ១២៨៣
- រឿងសាមកុក (តមក) ទកញ៉ ទូ-កន ប្រែ - . . . . ១២៩៤


*ផ្នែកកំណត់ទីប្រវត្តិការណ៍*


- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . ១៣១៨



មួយឆ្នាំ មាន ១២ សៀវភៅ ជំនៀជាវ ២៣០រ០០

# KAMBUJASURIYA

Revue mensuelle de Culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh

## sommaire

### Partie religieuse :

— La Vie du Buddha (suite) par Prah maha PANG-KHAT . 1201
— L'influence du Bouddhisme par M. SDOEUNG-CHHO . 1226
— Prah Abhidhammapitaka( Kathavathu) (suite) par M. BOU-PO 1238
— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM, revu et corrigé par le Vén. NHEAN-CHHOEUN . . . 1248
— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON, revu par le Vén-KEM-TO 1255

### Partie littéraire :

— Légende de Marana Mâtâ(suite) relevée du manuscrit sur feuilles de latanier par M. BY-SOVANN . . . . . . . 1261
—Légende "La dame aux cheveux odoriférants", par M. NHEM-KHEM d'après les renseignements de la Commission des Mœurs et Coutumes. 1271
— La lutte entre le crapaud et le maître du ciel par M. LEANG HAB-AN . . . . . . . . . 1277
—Légende de l'Ukraine traduite de l'anglais par le bonze MEN-RIEM 1283
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1294

### Notes et Chroniques :

— Dictionnaire Sanscrit-khmer (suite) par le Vén.PANG-KHAT 1318

---

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

# ផ្នែកសាសនា

## ពុទ្ធជីវប្បវត្តិ

(តមក)

*ព្រះមហាប៉ាង - ខាត់ រៀបរៀង*

### ៦-ទ្រង់ចូលទៅកាន់ឧរុវេលាប្រទេសសេនានិគម

*លុះព្រះបរមពោធិសត្វរៀនក្នុងសំណាក់ឧទ្ទកតាបសរាមបុត្រ បាន សម្រេចនេវសញ្ញានាសញ្ញាយតនជ្ឈាន ជាសមាបត្តិទី ៨ គឺរូបជ្ឈាន ៤ អរូបជ្ឈាន ៤ ហើយ ឃើញថាមិនមែនជាផ្លូវត្រាស់ដឹង ក៏ទ្រង់មាន បំណងនឹងបំពេញមហាបធានវីរិយៈ ដើម្បីសំដែងកំឡាំងសេចក្តីព្យាយាមដ៏ឧក្រិដ្ឋរបស់ព្រះអង្គ ឲ្យប្រាកដដល់មនុស្សទាំងទេវតា ទើបស្តេចចូលទៅកាន់ឧរុវេលាប្រទេស ទ្រង់ពិចារណាឃើញភូមិភាគនោះ ជាទីសុខាភិរម្យសមគួរដល់កុលបុត្របំពេញព្យាយាម ចំរើនសមណធម៌ស្វែងរកគុណវិសេស ទើបស្តេចសម្រេចព្រះឥរិយាបថអាស្រ័យធ្វើមហាបធានវីរិយៈនៅក្នុងទីនោះ ដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារ ថា*[១]

“ម្នាលរាជកុមារ! តថាគតនោះឯង កាលស្វែងរកកុសល

១- ពោធិរាជកុមារសូត្រ រាជវគ្គ, ម ម សៀវ -២៤ ទំព័រ ៣៦៨ ។

សន្តិវរបទ ត្រាប់ទៅកាន់បរិកក្នុងដែនមគធៈ ដោយលំដាប់ សំដៅទៅឧរុវេលាប្រទេសសេនានិគម ក្នុងទីនោះ តថាគតបាន ឃើញភូមិភាគគួរជាទីត្រេកអរ មានដងព្រៃគួរជាក់ត្រងំ មាន ស្ទឹងកំពុងហូរមានទឹកដ៏ត្រជាក់ ប្រដាប់ដោយកំពង់រាបស្មើ គួរ ជាទីរីករាយ ទាំងគោចរគ្រាម ក៏តាំងនៅជុំវិញ តថាគត ត្រិះរិះថា ទីនេះហ្ន៎ ! ល្មមតាំងសេចក្តីព្យាយាម សំបតក្នុងទី នោះបាន" ។

*លំដាប់នោះ បព្វជិតទាំង ៥ រូបមាននាមប្រាកដថាបញ្ចវគ្គិយគឺ កោណ្ឌញ្ញៈ ១ វប្បៈ ១ ភទ្ទិយ ១ មហានាម ១ អស្សជិ ១ បបួលគ្នាដើរ ស្វែងរកព្រះបរមពោធិសត្វក្នុងប្រទេសផ្សេងៗ ហើយដើរបិណ្ឌបាតចិញ្ចឹម ជីវិតរៀងៗតាមនិគមជនបទ ទៅជួបព្រះបរមពោធិសត្វនៅក្នុងឧរុវេលា ប្រទេសនោះឯង បានឃើញព្រះមហាបុរសបំពេញមហាបធានវីរិយៈក៏ គិតគ្នាថា ព្រះមហាបុរសនឹងបានត្រាស់ជាព្រះពុទ្ធពិតប្រាកដ ដូច្នេះក៏ បបួលគ្នាធ្វើកិច្ចប្រណិប័ត្តបំរើ មានកិរិយាបោសប្រាសទីបរិវេណជាដើម ហើយសម្រេចកិរិយានៅក្នុងទីនោះ ៗ ។*

## ៣-ទ្រង់ប្រព្រឹត្តអត្តកិលមថានុយោគ

*ព្រះបរមពោធិសត្វស្តេចតាំងព្រះទ័យធ្វើសេចក្តីព្យាយាមយ៉ាងក្រៃជ្ជ*

មិនបន្ទរបន្ថយ មិនមាននរណាធ្វើដូចបាន ទ្រង់ធ្វើគ្រាប់វត្តរបស់អន្យតិរ្ថិយ ផ្សេង ៗ ដើម្បីល្បងសាកមើល ព្រោះមានបំណងចង់បានត្រាស់ជាព្រះពុទ្ធ តែក្រៃនបានជួបប្រទះកុសលសន្តិវរបទដែលទ្រង់ប្រាថ្នា ដូចដំណើរសេចក្តីដែលទ្រង់ត្រាស់ចំពោះព្រះសារីបុត្តថា[១]

"... ម្នាលសារីបុត្ត ! តថាគតធ្លាប់ប្រព្រឹត្តព្រហ្មចរិយៈ[២] ប្រកបដោយអង្គ ៤ គឺ

១- បើនិយាយពីតបៈ តថាគត មានតបៈដ៏ក្រៃលែង, ២- បើនិយាយពីសៅហ្មង តថាគតមានសេចក្តីសៅហ្មងដ៏ក្រៃលែង, ៣-បើនិយាយពីការខ្ពើមបាប តថាគតខ្ពើមបាបដ៏ក្រៃលែង, ៤-បើនិយាយពីការស្ងប់ តថាគតស្ងប់ដ៏ក្រៃលែង ។

១- តបៈ របស់តថាគតក្នុងព្រហ្មចរិយៈ ប្រកបដោយអង្គ ៤ នោះផ្សេះ គឺតថាគតជាអ្នកអាក្រាត លះបង់មារយាទល្អ[៣] ប្រព្រឹត្តហត្ថាវលេខនប្បដិបត្តិ[៤], ជាអ្នកកាន់វត្តមិនទទួលភត្ត ដែលគេនិមន្តថា "លោកដ៏ចំរើន បូរបូលមក ",

១.មហាសីហនាទសូត្រ សីហនាទវគ្គ-ម.ម សៀវ ២៨, ទំព័រ ២៩១ ។ ២. ព្រហ្មចរិយៈក្នុងទីនេះសំដៅយកសេចក្តីព្យាយាម ។ ៣- ឈប់បន្ទោរបង់ទច្ចារបស្សាវនឹងឈរបរិភោគ ។ ៤- បរិភោគភោជនលិទ្ធដៃយកម្រាមដៃកិតឈាមក ព្រោះសំគាល់កំណត់ថាជាសត្វ ។

មិនរង់ចាំតាមគេនិមន្តថា « លោកដ៏ចំរើន ! សូមរង់ចាំសិន », មិនត្រេកអរនឹងបង្ហាន់ដែលគេកាន់យកមកមុន, មិនត្រេកអរនឹងបង្ហាន់ ដែលគេប្រាប់ថាធ្វើចំពោះខ្លួន, មិនត្រេកអរនឹងបង្ហាន់ដែលគេនិមន្ត, មិនទទួលបង្ហាន់ដែលគេកំពុងដោះដួសអំពីឆ្នាំង, មិនទទួលបង្ហាន់អំពីមាត់កញ្ជើ, មិនទទួលបង្ហាន់ដែលគេឲ្យត្រង់បន្លោះធរណី, មិនទទួលបង្ហាន់ ដែលគេឲ្យត្រង់បន្លោះត្បាល់, មិនទទួលបង្ហាន់ដែលគេឲ្យត្រង់បន្លោះអង្រែ, មិនទទួលបង្ហាន់របស់មនុស្សដែលកំពុងបរិភោគពីរនាក់, មិនទទួលបង្ហាន់របស់ស្ត្រីមានគភ៌, មិនទទួលបង្ហាន់របស់ស្ត្រីដែលកំពុងបំបៅកូន, មិនទទួលបង្ហាន់របស់ស្ត្រីដែលកំពុងនៅរួមនឹងបុរស, មិនទទួលបង្ហាន់ដែលគេអង្គាសគ្នាធ្វើ, មិនទទួលបង្ហាន់ក្នុងទីដែលមានឆ្កែចាំ, មិនទទួលបង្ហាន់ដែលមានរុយហោមរោម, មិនបរិភោគត្រី, មិនបរិភោគសាច់, មិនផឹកសុរានឹងមេរ័យ, មិនផឹកទឹកថ្នាំត្រាំដោយស្រូវទាំងពួង ។ តឋាគតទទួលបង្ហាន់តែក្នុងផ្ទះមួយឬបរិភោគភោជនតែមួយពំនូត, ទទួលបង្ហាន់ក្នុងផ្ទះពីរឬ

បរិភោគភោជនតែពីរពំនូត ។បេ។ ទទួលបង្អាក់ក្នុងផ្ទះ ៧ ឬបរិ-ភោគតែ ៧ ពំនូត ។ តថាគតចិញ្ចឹមអត្តភាពដោយបង្អាក់ ១ ភាជន៍តូចខ្លះ ដោយបង្អាក់ ២ ភាជន៍តូចខ្លះ ។បេ។ ដោយបង្អាក់ ៧ ភាជន៍តូចខ្លះ, ឆាន់អាហាររំលង ១ ថ្ងៃខ្លះ រំលង ២ ថ្ងៃខ្លះ ។បេ។ ឆាន់អាហាររំលង ៧ ថ្ងៃខ្លះ, តថាគតប្រកបរឿយៗ នូវការបរិភោគភត្តតាមលំដាប់ថ្ងៃយ៉ាងនេះ រហូតដល់រំលងកន្លះខែខ្លះ ដូចសំដែងមកនេះឯង ។ តថាគតមានបន្លែជាអាហារខ្លះ, មានស្រងែជាអាហារខ្លះ, មានស្មៅគែលលកជាអាហារខ្លះ, មានចំទៀរស្បែកដែលគេចៀរចោលជាអាហារខ្លះ, មានសារាយជាអាហារខ្លះ, មានកណ្ឌកជាអាហារខ្លះ, មានបាយក្តាំងជាអាហារខ្លះ, មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមនឹងផ្លែជាអាហារខ្លះ តែងបរិភោគផ្លែឈើដែលជ្រុះឯងខ្លះ ។ តថាគតប្រើប្រាស់សំពត់ដែលត្បាញដោយសំបកធ្មៃខ្លះ, ប្រើប្រាស់សំពត់ត្បាញលាយបម្រុះគ្នាខ្លះ, ប្រើប្រាស់សំពត់ដែលគេរុំសាកសពខ្លះ ប្រើប្រាស់សំពត់បំសុកូល[1]ខ្លះ ប្រើ

១ កំណាត់សំពត់ដែលចោលលើផែនដី ។

ប្រាស់សំពត់សំបកឈើខ្លះ, ប្រើប្រាស់ស្បែកខ្លាខ្លះ ប្រើប្រាស់ស្បែកខ្លាទាំងក្រចកខ្លះ, ប្រើប្រាស់សំពត់ដែលក្រងដោយស្បូវខ្លះ ប្រើប្រាស់សំពត់ដែលក្រងដោយសំបកក្រចៅខ្លះ, ប្រើប្រាស់សំពត់ដែលក្រងដោយសំបកផ្លែឈើខ្លះ, ប្រើប្រាស់សំពត់កម្ពលដែលត្បាញដោយសក់មនុស្សខ្លះ, ប្រើប្រាស់សំពត់ដែលត្បាញដោយរោមកន្ទុយសត្វខ្លះ, ប្រើប្រាស់សំពត់ដែលត្បាញដោយស្លាបមៀមខ្លះ, កាន់វត្តទុកសក់នឹងពុកមាត់ពុកចង្កាខ្លះ, ប្រព្រឹត្តតែឈរមិនអង្គុយខ្លះ, អង្គុយប្រពោងប្រកបរឿយ ៗ នូវសេចក្តីព្យាយាមប្រពោងខ្លះ, ដេកលើបន្លា សម្រេចការដេកលើបន្លាខ្លះ, ប្រកបរឿយ ៗ នូវសេចក្តីព្យាយាមចុះត្រាំក្នុងទឹក (ដើម្បីបន្សាត់បាប) ក្នុងមួយថ្ងៃ ៣ ដង[១] ប្រកបរឿយ ៗ នូវសេចក្តីព្យាយាមដុតកំដៅនូវកាយច្រើនប្រការ មានសភាពយ៉ាងនេះដូច្នេះឯង ។ ម្នាលសារីបុត្ត ! នេះជាវត្តរបស់អ្នកមានតបៈនៃតថាគត ។

២– សេចក្តីសៅហ្មងរបស់តថាគត ក្នុងព្រហ្មចរិយៈ

---

១ ពេលព្រឹកព្រហាមម្តង, ថ្ងៃត្រង់ម្តង ល្ងាចម្តង ។

ធម៌ប្រកបដោយអង្គ ៤ នេះដូច្នេះ មន្ទិលគឺធូលីរាប់ដោយឆ្នាំដ៏ច្រើនដែលជាប់នៅនឹងកាយ ក៏ក្លាយទៅជាក្រមរស្រទាប់ៗ ។ ម្នាលសារីបុត្ត ! ដង្គត់ដើមដង្កោ ដែលតាំងនៅរាប់ដោយឆ្នាំដ៏ច្រើនក៏កើតជាក្រមរ មានឧបមាដូចម្ដេចមិញ មានឧបមេយ្យដូចមន្ទិលគឺធូលីរាប់ដោយឆ្នាំដ៏ច្រើន ដែលជាប់នឹងកាយតថាគត ក៏ក្លាយទៅជាក្រមរដូច្នោះឯង ។ តថាគតមិនត្រិះថា-"ឱហ្ន៎ ! អាត្មាអញ គប្បីយកបាតដៃដុសមន្ទិល គឺធូលីនេះចេញដូច្នេះឡើយ ។ ម្នាលសារីបុត្ត ! សូម្បីតែគំនិតថា "ជនទាំងឡាយ ដទៃគប្បីយកបាតដៃដុសក្អែលរបស់តថាគតនេះដូច្នេះក៏មិនមានដល់តថាគតឡើយ" ម្នាលសារីបុត្ត ! នេះជាវត្តដែលសៅហ្មងរបស់តថាគត ។

៣- វត្តខាងខ្ពើមបាបរបស់តថាគត ក្នុងព្រហ្មចរិយៈប្រកបដោយអង្គ ៤ នេះដូច្នេះ តថាគតនោះឯង ឈានទៅមុខមានស្មារតី ថយក្រោយក៏មានស្មារតី តថាគតដឹកលំសេចក្ដី អា

ណិតបំពោះដំណក់ទឹក[១]ដរាបមកថា “តថាគតមិនបានញាំង ពួកសត្វៗ គឺដំណក់ទឹក ដែលដក់ជាប់នៅក្នុងទីផ្សេងៗឲ្យដល់ នូវសេចក្ដីវិនាសឡើយ ។ ម្នាលសារីបុត្ត ! នេះឯងជាវត្តនៃការ ខ្ពើមបាប របស់តថាគត ។

៤–វត្តខាងការស្ងប់ស្ងាត់របស់តថាគត ក្នុងព្រហ្មចរិយៈ ប្រកបដោយអង្គ ៤ ដូច្នេះ តថាគតនោះឯង តែងចូលសំដៅ ទៅនៅអាស្រ័យក្នុងព្រៃរហោឋានណាមួយ កាលណាបើតថាគត ឃើញគង្វាលគោក្ដី គង្វាលសត្វចិញ្ចឹមក្ដី អ្នករកស្មៅក្ដី អ្នករកឧសក្ដី អ្នករការបរក្នុងព្រៃក្ដី តថាគតក៏ចេញអំពីព្រៃទៅ កាន់ព្រៃ, ចេញអំពីព្រៃស្បាតទៅកាន់ព្រៃស្បាត, ចេញអំពីទី ទាបទៅកាន់ទីទាប, ចេញអំពីទីទួលទៅកាន់ទីទួល ព្រោះ តថាគត បានអធិដ្ឋានថា “សូមកុំឲ្យជនទាំងឡាយនោះ បាន ឃើញតថាគត ទាំងតថាគតសោត ក៏កុំឲ្យឃើញជនទាំងឡាយ

១-ដំណក់ទឹក ក្រួស, ថ្ម កំណាត់ឈើ នឹងដីឡាប់ជាដើម ពួកនិគ្រន្ថបញ្ញត្តថាជាសត្វតូចៗ ។

នោះឡើយ" ប្រៀបដូចម្រឹគឃើញមនុស្សទាំងឡាយតែងរត់អំពីព្រៃចូលទៅកាន់ព្រៃ, ចេញអំពីព្រៃស្បាត ចូលទៅកាន់ព្រៃស្បាត, ចេញអំពីទីទាបចូលទៅកាន់ទីទាប, ចេញអំពីទីទួលចូលទៅកាន់ទីទួល យ៉ាងណាមិញ ម្នាលសារីបុត្ត ! តថាគតក៏យ៉ាងនោះដែរ ម្នាលសារីបុត្ត ! នេះឯងជាវត្តខាងសេចក្តីស្ងប់ស្ងាត់ របស់តថាគត ។

ម្នាលសារីបុត្ត ! តថាគតជាអ្នកវារដោយជង្គង់ ៤ ចូលទៅរកក្រោលគោដែលមានគោចេញហើយ មានគង្វាលគោចៀសចេញទៅហើយៗ ស៊ីអាចម៍របស់កូនគោជំទង់ដែលនៅបៅមេៗ ម្នាលសារីបុត្ត ! មូត្រនឹងករីសរបស់តថាគត មិនទាន់អស់ដរាបណា តថាគតក៏ស៊ីនូវមូត្រនឹងករីសរបស់ខ្លួនឯង ដរាបនោះៗ ម្នាលសារីបុត្ត ! នេះឯងជាវត្តខាងភោជនយ៉ាងបំផ្លែកធំរបស់តថាគត ។

ម្នាលសារីបុត្ត ! តថាគតចូលទៅអាស្រ័យនៅក្នុងដងព្រៃមួយដែលគួរស្ញែង, សេចក្ដីតក់ស្លុតនឹងដងព្រៃគួរស្ញែងនោះតែងមាន, បុគ្គលណានីមួយមិនទាន់ប្រាសចាករាគៈទេ ចូលទៅកាន់ដងព្រៃនោះ ច្រើនតែព្រឺព្រួចរោម រាត្រីទាំង ៨ ជាចន្លោះខែមាឃនឹងខែផល្គុនក្នុងហេមន្ត(១)រដូវ ជាសម័យធ្លាក់ទឹកសន្សើមដ៏ត្រជាក់ ក្នុងរាត្រីមានសភាពដូច្នេះ តថាគតនៅក្នុងទីវាលក្នុងពេលយប់, នៅក្នុងដងព្រៃក្នុងវេលាថ្ងៃ ខែជាខាងចុងគិម្ហរដូវ តថាគតនៅក្នុងទីវាលក្នុងវេលាថ្ងៃ នៅក្នុងដងព្រៃក្នុងវេលាយប់ ។ ម្នាលសារីបុត្ត ! អើក៏គាថាដែលគួរអស្ចារ្យនេះ ដែលតថាគតមិនដែលបានស្ដាប់ក្នុងកាលពីមុនទេ, ស្រាប់តែភ្លឺច្បាស់ប្រាកដ ដល់តថាគតថា :

សោ តត្តោ សោ សីនោ ឯកោ
ឯកោ ភឹសនកេ វនេ

---

១-គឺខាងចុងខែមាឃ ៤ រាត្រី ខាងដើមខែផល្គុន ៤ រាត្រី រួមជា ៨ រាត្រី ។

ឆគ្គោ ឆ ចក្ខុមាសិតោ

ឯសនា បសុតោ មុនីតិ ។

ប្រែថា: "អ្នកប្រាជ្ញដែលខ្វល់ខ្វាយក្នុងកិរិយាស្វែងរក (នូវសេចក្ដីបរិសុទ្ធ) អ្នកប្រាជ្ញនោះត្រូវតែក្ដៅ អ្នកប្រាជ្ញនោះត្រូវតែត្រជាក់ម្នាក់ឯង ជាអ្នកត្រូវតែនៅក្នុងព្រៃ គួរស្ញើមតែម្នាក់ឯង អាក្រាតមិនចូលទៅរកភ្លើងឡើយ ។

ម្នាលសារីបុត្ត ! តថាគតនោះសម្រេចនូវកិរិយាបបដេកក្នុងព្រៃស្មសាន ហើយលើឆ្អឹងសាកសពទាំងឡាយ ។ ចំណែកពួកក្មេងឃ្វាលគោ នាំគ្នាចូលទៅជិតតថាគត ហើយស្ដោះដាក់ខ្លះ នោមដាក់ខ្លះ យកដីរាយដាក់ខ្លះ យករំកាច់ឈើមករុកក្នុងរន្ធត្រចៀក(១)ខ្លះ តថាគតមិនដែលធ្វើចិត្តឲ្យអាក្រក់ចំពោះពួកក្មេងឃ្វាលគោទាំងនោះឡើយ ។ ម្នាលសារីបុត្ត ! នេះឯងឈ្មោះថា ជាវត្តខាងការនៅប្រកបដោយឧបេក្ខា របស់

---

១– ពួកក្មេងបង្ខំឲ្យពោធិសត្វនិយាយ ហើយទ្រង់មិននិយាយ ទើបពួកក្មេងរាំធ្វើអំពើអាក្រក់យ៉ាងនេះ ។

តថាគត ។

ម្នាលសារីបុត្ត ! មានសមណព្រាហ្មណ៍ពួកមួយ តែង និយាយយ៉ាងនេះ យល់យ៉ាងនេះថា សេចក្ដីបរិសុទ្ធិ កើតមានព្រោះអាហារ ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏ស៊ីផ្លែពុទ្រាខ្លះ ស៊ីលំអិតនៃផ្លែពុទ្រាខ្លះ ផឹកទឹកដែលប្រឡាក់លាយដោយផ្លែពុទ្រាខ្លះ បរិភោគនំដែលធ្វើដោយផ្លែពុទ្រាច្រើនខ្លះ ។ ម្នាលសារីបុត្ត ! តថាគតធ្លាប់យកផ្លែពុទ្រាតែមួយប៉ុណ្ណោះមកធ្វើជាអាហារ. ម្នាលសារីបុត្ត ! ប្រហែលអ្នកមានសេចក្ដីយល់យ៉ាងនេះថា " ផ្លែពុទ្រាក្នុងសម័យនោះជាផ្លែធំៗណាស់ដំណើរគ្គុះ អ្នកមិនគួរយល់យ៉ាងនោះទេ ព្រោះថាផ្លែពុទ្រាក្នុងកាលឥឡូវនេះ មានទំហំប៉ុនណា ក្នុងកាលពីដើមក៏មានទំហំប៉ុណ្ណោះដែរ " ។ ម្នាលសារីបុត្ត! កាលតថាគត យកផ្លែពុទ្រាតែមួយប៉ុណ្ណោះមកធ្វើជាអាហារ កាយក៏ដល់នូវភាវៈស្គាំងស្គមហួសប្រមាណ អវយវៈតូចធំរបស់តថាគត ក៏ដូចថ្នាំង

វល្លិឈ្មោះអសីតិ (ដកកគន់ ឬលៃនពែន) ឬដូចជាថ្នាំងវល្លិកាឡា (វល្លិអណ្តាតត្រគួត) ទ្រូគាករបស់តថាគតក៏ដូចជាជើងសត្វឱដ្ឋ, ឆ្អឹងខ្នងរបស់តថាគតរគីមរគាមដូចជាខ្សែដែលគេវេញ, ឆ្អឹងជំនីរទាំងឡាយរបស់តថាគត រគីមរគាមដូចជាបង្កង់សាលាចាស់ដែលរខេករខាក, ប្រស្រីភ្នែករបស់តថាគត ក៏ខូងជ្រៅទៅក្នុងរណ្តៅភ្នែក ដូចជាទឹកដែលជ្រៅខូងទៅក្នុងអណ្តូងទឹកដ៏ជ្រៅ, ស្បែកក្បាល របស់តថាគតក៏រួបរិតស្វិតស្រពោន ដូចជាផ្លែឃ្លោកព្រៃដែលគេកាត់ទាំងខ្ចី តែងរួបរិតស្វិតដោយខ្យល់និងកំដៅថ្ងៃ ។ ម្នាលសារីបុត្ត ! តថាគតស្ទាបស្បែកពោះ ហើយចាប់ទៅ ត្រូវទ្រនុងឆ្អឹងខ្នងវិញ, តថាគតស្ទាបទ្រនុងឆ្អឹងខ្នង ហើយចាប់ទៅត្រូវស្បែកពោះវិញ ស្បែកពោះរបស់តថាគតជាប់គ្នានឹងទ្រនុងឆ្អឹងខ្នង ។ ម្នាលសារីបុត្ត ! តថាគតបន្ទោបង់វច្ចៈឬទឹកមូត្រក៏ដួលផ្កាប់មុខទៅលើផែនដី ព្រោះតែអាហារតិចនោះឯង ។ ម្នាលសារីបុត្ត ! តថាគតកាលធ្វើកាយនោះ

ឯងឲ្យបានស្រួល ក៏យកដៃស្ទាបខ្លួន រោមទាំងឡាយដែលមានគល់ស្អុយក៏ជ្រុះចេញចាកកាយ ព្រោះតែអាហារ(១) តិចនោះឯង។

## ៨- សេចក្ដីឧបមា ៣ យ៉ាង

*កាលដែលព្រះបរមពោធិសត្វកំពុងបំពេញមហាបធានវីរិយៈយ៉ាងតឹងរឹងនេះ មានសេចក្ដីឧបមា ៣ ប្រការកើតប្រាកដឡើងដល់ព្រះអង្គ ដូចព្រះតម្រាសដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារ(២) ថា*

" - - - ម្នាលរាជកុមារ ! ឧបមា ៣ ប្រការ មិនសូវជាអស្ចារ្យណាស់ណា ដែលតថាគត មិនធ្លាប់បានស្ដាប់ឮមកពីមុនក៏បានកើតប្រាកដ ដល់តថាគត ។

ឧបមា ទី ១ ម្នាលរាជកុមារ ! ប្រៀបដូចឈើស្រស់ប្រកបដោយជ័រ ដែលបុគ្គលត្រាំទុកនៅក្នុងទឹក ហើយបុរសគិតថា "យើងនឹងកាន់យកឈើពីខ្លួតខាងលើ មកពួតភ្លើង

១- តពីនោះទៅមានសេចក្ដីដូចគ្នាគ្រាន់តែផ្លាស់ការបរិភោគ ដូចជាទ្រង់បរិភោគសណ្ដែកបាយ, ល្ង អង្ករពុំណ្ណោះ, ព្រះអង្គបានល្បងធ្វើមើលគ្រប់បែប ផ្លាស់ប្ដូរគ្នា ត ៗ ទៅ, លុះទ្រង់ឃើញថាមិនជាប្រយោជន៍ដល់ការត្រាស់ដឹងព្រះអង្គទេ ទ្រង់លះបង់ចោលទៅ ។ រឿងទាំងនេះសំដែងឲ្យឃើញថា ព្រះអង្គទ្រង់បានប្រព្រឹត្តវត្តនិគ្រន្ថដែលហៅថាអត្តកិលមថានុយោគគ្រប់ ៗ យ៉ាង ដល់វេលាបានត្រាស់ ទ្រង់បដិសេធឲ្យលះបង់មិនគួរប្រតិបត្តិតាម ។

២ ពោធិរាជកុមារសូត្ររាជវគ្គ ម.ម. សៀវ ២៤ ទំព័រ ៣៦៩ ។

និងធ្វើតេជោជាតុឲ្យកើតប្រាកដឡើងបាន» ។ ម្នាលរាជ-កុមារ! អ្នកសំគាល់សេចក្ដីនោះដូចម្ដេច ? បុរសនោះគប្បីព្រួតឲ្យកើតភ្លើង ធ្វើឲ្យតេជោជាតុកើតឡើងបានឬទេ ? បពិត្រព្រះអង្គដ៏ចំរើន ! មិនកើតទេ ព្រោះឈើឯណោះនៅស្រស់ប្រកបដោយជ័រ ថែមទាំងឈើនោះត្រាំនៅក្នុងទឹកផង, បុរសនោះ គ្រាន់តែបានចំណែកនៃសេចក្ដីលំបាក បង្អៀតបង្អល់តែប៉ុណ្ណោះ ។ ម្នាលរាជកុមារ ! សេចក្ដីនេះក៏ឧបមេយ្យដូច្នោះឯង ពួកសមណព្រាហ្មណ៍ណាមួយ មិនបានចៀសចេញចាកកាមដោយកាយ សមណព្រាហ្មណ៍ទាំងនោះ ថែមទាំងមានសេចក្ដីពេញចិត្តក្នុងកាម ស្នេហាក្នុងកាម ជ្រប់ក្នុងកាម ស្រេកឃ្លានក្នុងកាម ក្រហល់ក្រហាយព្រោះកាមក្នុងកាមទាំងឡាយ កាមនោះជារបស់ដែលសមណព្រាហ្មណ៍ទាំងនោះមិនទាន់លះបង់ដោយប្រពៃ មិនទាន់ធ្វើឲ្យស្ងប់រម្ងាប់ដោយប្រពៃព្ធដ៏ខាងក្នុង ប្រសិនបើពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ

បានទទួលរងវេទនា ជាទុក្ខក្លៀវក្លាខ្លោចផ្សា កើតអំពីសេចក្តីព្យាយាម ។ ពួកសមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹង នូវព្រះនិព្វានដ៏ប្រសើរបានឡើយ ។ ទោះបីពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ មិនបាន រងទុក្ខវេទនា ដ៏ក្លៀវក្លាខ្លោចផ្សា ដែលកើតអំពីព្យាយាមនោះទេ ពួកសមណព្រាហ្មណ៍ទាំងនោះមិនគួរ ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងនូវព្រះនិព្វានដ៏ប្រសើរបានឡើយ ។ ម្នាលរាជកុមារ ! នេះឯងជាឧបមាដំបូង មិនសូវជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានឮមកពីមុន មកប្រាកដ ដល់តថាគត ។

ឧបមាទី ២ ម្នាលរាជកុមារ ! ដូចឈើស្រស់ប្រកបដោយជ័រ ដែលគេដាក់លើគោក នៅឆ្ងាយពីទឹក បុរសគិតថា "យើងនឹងកាន់យកឈើពំនួតខាងលើ មកពួតភ្លើងធ្វើតេជោធាតុឲ្យកើតប្រាកដឡើង" ។ ម្នាលរាជកុមារ ! អ្នក

សំគាល់សេចក្ដីនោះដូចម្ដេច ? បុរសនោះគប្បីពួតឲ្យកើតភ្លើង ធ្វើតេជោជាតុឲ្យកើតបានឬទេ ? បពិត្រព្រះអង្គដ៏ចំរើន ! មិនកើតទេ ព្រោះឈើឯណោះនៅស្រស់ ប្រកបដោយជ័រពិតមែន តែគេដាក់លើគោកនៅឆ្ងាយពីទឹក, ឯបុរសនោះ គ្រាន់តែបានភាគនៃសេចក្ដីលំបាកចង្អៀតចង្អល់ប៉ុណ្ណោះ ។ ម្នាលរាជកុមារ ! សេចក្ដីឧបមេយ្យ ក៏ដូច្នោះឯង ពួកសមណព្រាហ្មណ៍ឯណាមួយ ចៀសចេញចាកកាម ដោយកាយហើយ តែសមណព្រាហ្មណ៍ទាំងនោះ នៅមានសេចក្ដីពេញចិត្ត ក្នុងកាម ស្នេហាក្នុងកាម ជ្រប់ក្នុងកាម ស្រេចឃ្លានក្នុងកាម ក្រហល់ក្រហាយព្រោះកាមក្នុងវត្ថុកាមទាំងឡាយ, កាមទាំងនោះ សមណព្រាហ្មណ៍ទាំងនោះ មិនទាន់លះបង់ដោយប្រពៃ មិនទាន់ធ្វើឲ្យស្ងប់ស្ងាត់ដោយប្រពៃ ។ ទោះបីពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ បានរងវេទនាជាទុក្ខដ៏ក្លៀវក្លា ខ្លាំងក្លា ដែលកើតអំពីព្យាយាម ក៏ដោយ ពួកសមណព្រាហ្មណ៍ទាំងនោះ

ក៏មិនគួរ ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងនូវព្រះនិព្វានដ៏ប្រសើរបានឡើយ ។ បើទុកជាពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ មិនបានរងវេទនា ជាទុក្ខដ៏ក្លៀវក្លា ខ្លោចផ្សា ដែលកើត អំពីព្យាយាមនោះទេ ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរ ដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹងនូវព្រះនិព្វានដ៏ប្រសើរបានឡើយ ។

ឧបមាទី ៣ ម្នាលរាជកុមារ ! ដូចឈើស្ងួត ជាឈើពុក ដែលគេដាក់លើគោកនៅឆ្ងាយពីទឹក, បុរសគិតថា „យើងនឹងកាន់យកឈើពំនួតខាងលើមកពួតភ្លើង ធ្វើតេជោ-ធាតុឲ្យកើតប្រាកដឡើង " ។ ម្នាលរាជកុមារ ! អ្នកសំគាល់សេចក្តីនោះដូចម្តេច ? បុរសនោះគប្បីពួតឲ្យចេញភ្លើង ធ្វើតេ-ជោធាតុឲ្យកើតបានឬទេ ? បពិត្រព្រះអង្គដ៏ចំរើន ! យ៉ាងនោះទើបកើតបាន, ព្រោះឈើស្ងួតឯណោះជាឈើពុក ថែមទាំងឈើនោះសោត គេដាក់លើគោកនៅឆ្ងាយពីទឹកផង ។ ម្នាល

រាជកុមារ! សេចក្ដីឧបមេយ្យក៏ដូច្នោះឯង ពួកសមណព្រាហ្មណ៍ណាមួយ ចៀសចេញចាកកាមដោយកាយហើយ ទាំងមិនមានសេចក្ដីពេញចិត្តក្នុងកាម ស្នេហាក្នុងកាម ជ្រប់ក្នុងកាម ស្រេកឃ្លានក្នុងកាម ក្រហល់ក្រហាយ ព្រោះកាមក្នុងវិតកាមទាំងឡាយ សមណព្រាហ្មណ៍ទាំងនោះ ក៏បានលះបង់ដោយប្រពៃ បានធ្វើឲ្យស្ងប់រម្ងាប់ដោយប្រពៃ នូវវិតក្កកាមនោះឰដ៏ខាងក្នុង ។ ទោះបីពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ បានរងវេទនាជាទុក្ខដ៏ក្លៀវក្លាខ្លោចផ្សា ដែលកើតអំពីព្យាយាមពិតមែន ប៉ុន្តែពួកសមណព្រាហ្មណ៍ទាំងនោះ គួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹង នូវព្រះញាណដ៏ប្រសើរបាន ។ បើទុកជាពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ មិនបានរងវេទនាជាទុក្ខដ៏ក្លៀវក្លាខ្លោចផ្សា ដែលកើតអំពីព្យាយាមទេ ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏គួរដើម្បីដឹង ដើម្បីឃើញ ដើម្បីត្រាស់ដឹង នូវព្រះញាណដ៏ប្រសើរបាន ។

(ទៅមានទៀត)

# តម្លៃនៃព្រះពុទ្ធសាសនា

លោក ស្តើង-ឆូរ ប្រមូលរៀបរៀង

---

## អស់លោកអ្នកអានជាទីគោរពទាំងឡាយ !

វេលានេះ ខ្ញុំសូមរៀបរាប់អំពីតម្លៃនៃព្រះពុទ្ធសាសនាដែលខ្ញុំបាន អាន បានយល់តាមសតិបញ្ញាដូចតទៅនេះ ៖

ព្រះពុទ្ធសាសនានេះ, គួរអស់លោកអ្នកអានទាំងឡាយជ្រាបថា ជាពាក្យប្រៀនប្រដៅមានតម្លៃយ៉ាងក្រៃលែង ។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ សុទ្ធតែជាពាក្យប្រៀនប្រដៅដឹកនាំមនុស្សសត្វព្រមទាំងទេវតា ឲ្យដើរត្រង់ទៅរកសេចក្ដីសុខ-ចំរើន ទាំងក្នុងលោកនេះនិងលោកខាងមុខ ។ បណ្ដាពាក្យប្រៀនប្រដៅទាំងនោះ មានពាក្យប្រៀនប្រដៅខ្លះបានត្រូវគ្នានឹងសុភាសិតអ្នកប្រាជ្ញទាំងឡាយ អំពីបុរាណក៏មាន, មានពាក្យប្រៀនប្រដៅខ្លះទៀត ជាពាក្យប្រៀនប្រដៅផុតវិស័យគំនិតមនុស្សសត្វព្រមទាំងទេវតាទាំងអស់; ក្រៅតែអំពីព្រះសម្ពុទ្ធជាម្ចាស់ ឥតមានអ្នកណាម្នាក់ អាចរកគិតបង្កើតឡើងបានដូចនោះក៏មាន ។

ព្រះពុទ្ធសាសនា មានឡើងដំបូងនៅក្នុងមជ្ឈិមប្រទេស គឺប្រទេសឥណ្ឌៀសម័យសព្វថ្ងៃនេះ ។ នៅក្នុងមជ្ឈិមប្រទេសទាំងមូល, កាលដែល

មិនទាន់មានព្រះពុទ្ធសាសនានៅឡើយ មនុស្សទាំងអស់ តែងនាំគ្នាប្រព្រឹត្តប្រតិបត្តិ តាមលទ្ធិសាសនាព្រាហ្មណ៍ខ្លះ, តាមលទ្ធិសាសនាឯទៀត ៗ ខ្លះ ដែលជាផ្លូវប្រតិបត្តិតឹងពេកក៏មាន ធូរពេកក៏មាន ដូចយ៉ាងប្រព្រឹត្តប្រតិបត្តិបង្អត់អាហារខ្លួន ឲ្យលំបាករូបកាយ, ប្រព្រឹត្តទុកសក់ឲ្យវែងអន្លាយ, ប្រព្រឹត្តដេកលើបន្លា, ប្រព្រឹត្តអាំងភ្លើងក្នុងវេលាថ្ងៃនាផ្លូវក្តៅជាដើម ដែលសុទ្ធតែជាសេចក្តីប្រតិបត្តិឥតប្រយោជន៍ទាំងអស់ ក៏ឥតមានមនុស្សណាម្នាក់គិតឃើញថា ជាសេចក្តីប្រតិបត្តិឥតប្រយោជន៍ ហើយនឹងរកគិតរកផ្លូវប្រតិបត្តិជាថ្មីទៀតនោះសោះឡើយ ។

លុះដល់ព្រះសម្ពុទ្ធជាម្ចាស់ បានត្រាស់ដឹងឡើងក្នុងលោកព្រះអង្គបានសំដែងធម៌ទេសនាជាដំបូង ចំពោះបញ្ចវគ្គិយភិក្ខុ ដើម្បីកែប្រែសេចក្តីប្រតិបត្តិទាំងនោះ គឺពន្យល់មិនឲ្យប្រតិបត្តិតាម នូវសេចក្តីប្រតិបត្តិឥតប្រយោជន៍ទាំងនោះ ហើយឲ្យត្រឡប់មកប្រតិបត្តិតាមបែប ដែលព្រះអង្គទ្រង់យល់ថាជាផ្លូវប្រតិបត្តិមានប្រយោជន៍ពិត ៗ នោះវិញ ។ ធម៌ទេសនាដែលព្រះអង្គបានសំដែង ជាដំបូងនោះមានសេចក្តីថា :

ទ្វេ មេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា

ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រតិបត្តិដ៏លាមកអាក្រក់ទាំងពីរយ៉ាងនេះ, បព្វជិតមិនគួរសេព គឺថាមិនត្រូវប្រតិបត្តិឡើយ ។ សេចក្តីប្រតិបត្តិ

អាក្រក់ទាំងពីរយ៉ាងនោះគឺ កាមសុខល្លិកានុយោគ ការប្រកបខ្លួនឲ្យជាប់ជំពាក់ដោយសេចក្ដីសុខក្នុងកាមទាំងឡាយ ១, អត្តកិលមថានុយោគ ការប្រកបសេចក្ដីលំបាកដល់ខ្លួន ឲ្យនឿយលំបាកឥតប្រយោជន៍ ១ ។ សេចក្ដីប្រតិបត្តិទាំង ២ យ៉ាងនេះ ជាអំពើថោកទាបជាការនាំឲ្យសាបសូន្យ មិនជាសេចក្ដីចំរើនទេ; មិនតែប៉ុណ្ណោះ ថែមទាំងជាហេតុនាំបណ្ដាលឲ្យបានសេចក្ដីទុក្ខព្រួយថែមទៀត ។

ឯតេ តេ ភិក្ខវេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រតិបត្តិជាកណ្ដាល ដែលមិនបាច់អាស្រ័យនូវសេចក្ដីប្រតិបត្តិដ៏លាមក អាក្រក់ទាំង ២ យ៉ាងនោះ ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្ដីប្រតិបត្តិធ្វើឲ្យកើតប្រាជ្ញា ឲ្យកើត សេចក្ដីដឹងច្បាស់ប្រាកដ ប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់ ដើម្បីសេចក្ដីដឹងក្រៃពេក ដើម្បីសេចក្ដីដឹងល្អ ដើម្បីព្រះនិព្វាន ។

សេយ្យថីទំ សេចក្ដីប្រតិបត្តិជាកណ្ដាលនោះតើដូចម្ដេចខ្លះ ?

សេចក្ដីប្រតិបត្តិជាកណ្ដាលនោះ គឺធម៌ដែលគួរស្វែងរកមានអង្គ ៨ ហៅថា អដ្ឋង្គិកមគ្គ ជាគ្រឿងចេញផុតចាកសត្រូវគឺកិលេស ។ អដ្ឋង្គិកមគ្គនោះគឺ: សម្មាទិដ្ឋិ ប្រាជ្ញាយល់ត្រូវ ១, សម្មាសង្កប្បោ សេចក្ដីត្រិះរិះត្រូវ ១, សម្មាវាចា សំដីនិយាយត្រូវ ១ សម្មាកម្មន្តោ

ការងារត្រូវ ១ សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ ១ សម្មាវាយាមោ សេចក្តីព្យាយាមត្រូវ ១ សម្មាសតិ សេចក្តីរលឹកត្រូវ ១ សម្មាសមាធិ កិរិយាដំកល់ចិត្តត្រូវ ១ ។

មានធម៌ជាពុទ្ធសាសនាជាន់ខ្ពស់ទៀត ហៅថា សច្ចធម៌ ជាធម៌ប្រកាសនូវសេចក្តីពិត ជាធម៌កំបាំងទីងងឹតគំនិតប្រាជ្ញារបស់មនុស្សទេវតាទាំងអស់, កាលមុនដែលពុំទាន់មានព្រះពុទ្ធសាសនានោះ ឥតមានអ្នកណាមួយចេះប្រដៅគ្នាឲ្យយល់ពិតដូចជាសច្ចធម៌នេះឡើយ, បើទុកជាមានបុគ្គលអ្នកឃើញខ្លះ ក៏ឃើញនោះគ្រាន់តែព្រិល ៗ មិនច្បាស់លាស់, លុះដល់ព្រះពុទ្ធបានត្រាស់ដឹងឡើង ទើបព្រះអង្គសំដែងអំពីសច្ចធម៌នោះ ឲ្យអស់មនុស្សទេវតាទាំងអស់ បានស្គាល់ច្បាស់ច្រើនគ្នាឡើង ហៅថា អរិយសច្ច ។ អរិយសច្ចនោះមាន ៤ យ៉ាងគឺ:

១- ទុក្ខំ ការកើត, ការចាប់កំណើត, ការកើតប្រាកដនៃខន្ធប្រាំ ជាទុក្ខ ១ ឈ្មោះថាជាតិទុក្ខ; ជរា គឺការចាស់ទ្រុឌទ្រោមគ្រាំគ្រានៃខន្ធប្រាំជាទុក្ខ ១ ឈ្មោះថាជរាទុក្ខ; សេចក្តីស្លាប់ក៏ជាទុក្ខ ១ ឈ្មោះថាមរណទុក្ខ; សេចក្តីស្តាយស្រណោះអាឡោះអាល័យ ក្តៅរំជួលខាងក្នុង ព្រោះសេចក្តីវិនាសនៃញាតិសន្តាន ទ្រព្យធនគូស្រករគ្រួសារជាដើម ជាទុក្ខ ១ ដែរឈ្មោះថាសោកទុក្ខ; សេចក្តីខ្សឹកខ្សួលយំស្រែងស្រែ

កាល័យញាតិសន្តានទ្រព្យធនគ្គស្រែករគ្រួសារជាដើម ដែលវិនាសស្លាប់បាត់បង់ទៅ ជាទុក្ខ ១ ឈ្មោះថា បរិទេវទុក្ខ; ជម្ងឺតំកាត់កើតមានក្នុងកាយ ធ្វើឲ្យលំបាករូបកាយ ជាទុក្ខ ១ ឈ្មោះថាទុក្ខទុក្ខ; សេចក្តីតូចចិត្តលំបាកចិត្ត ជម្ងឺកើតអំពីចិត្ត ជាទុក្ខ ១ ឈ្មោះថាទោមនស្សទុក្ខ; សេចក្តីខឹងក្រោធពិរោធ កើតអំពីសេចក្តីលំបាកចិត្តខ្លាំងពេក ដោយហេតុវិនាសនៃញាតិសន្តាន ទ្រព្យធនគ្គស្រែករគ្រួសារជាដើម រួមសេចក្តីទៅថា ការតានតឹងក្នុងចិត្ត បង្អៀតបង្អល់ចិត្តជាទុក្ខ ១ ឈ្មោះថា ឧបាយាស. ទុក្ខ; ការជួបប្រទះនូវសត្វ (បានដល់រូបមនុស្សសត្វទៅ) នឹងសង្ខារ (បានដល់រូប-សំឡេង-ក្លិន រស-សម្ផស្ស) មិនជាទីស្រឡាញ់ ជាទុក្ខ ១ ដែរឈ្មោះថា អប្បិយសម្បយោគទុក្ខ; ការព្រាត់ប្រាសនិរាសចាកសត្វនឹងសង្ខារជាទីស្រឡាញ់ ជាទុក្ខ ១ ឈ្មោះថា បិយវិប្បយោគទុក្ខ; បុគ្គលប្រាថ្នានូវវត្ថុណា ហើយមិនបាននូវវត្ថុនោះដូចប្រាថ្នា អំពើនោះជាទុក្ខ ១ ឈ្មោះថាឥច្ឆិតាលាភទុក្ខ: បើនិយាយឲ្យខ្លី ឧបាទានក្ខន្ធទាំង ៥ សុទ្ធតែជាទុក្ខទាំងអស់ហៅថា ឧបាទានក្ខន្ធទុក្ខ ។

២- ទុក្ខសមុទយោ ហេតុដែលជាមេនាំបណ្តាលឲ្យកើតសេចក្តីទុក្ខនោះ ហៅថាអរិយសច្ច បានខាងតណ្ហាជាធម្មជាតិតាក់តែងនូវភពថ្មីជាប្រក្រតី ប្រកបដោយសេចក្តីត្រេកត្រអាល ត្រេកអរក្នុងភពនោះៗ

ឬក្នុងអារម្មណ៍នោះ ៗ ។ តណ្ហានោះមាន ៣ យ៉ាងគឺ: កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។

៣- ទុក្ខនិរោធ ធម៌ជាគ្រឿងរលត់មិនសល់នៃតណ្ហានោះឯង ហៅថាអរិយសច្ច គឺសេចក្តីសាបរលាបទៅ នឹងសេចក្តីរលត់ទៅដោយមិនសល់នៃកិលេស មានតណ្ហាជាដើមនោះ ។

៤- ទុក្ខនិរោធគាមិនី បដិបទា សេចក្តីប្រតិបត្តិធ្វើអ្នកដែលប្រតិបត្តិតាម ឲ្យដល់នូវទុក្ខនិរោធ ហៅថាអរិយសច្ច បានខាងមគ្គដ៏ប្រសើរ មានអង្គ ៨ មានសម្មាទិដ្ឋិជាដើម មានសម្មាសមាធិជាទីបំផុត ដូចបានរៀបរាប់ពីខាងដើមរួចមកហើយ ។

អរិយសច្ចធម៌ទាំង ៤ ប្រការនេះ មានអ្នកប្រាជ្ញជាច្រើនដែលបានរិះគិត បានស្តាប់ បានសិក្សា ទៅតាមលំអានព្រះពុទ្ធដីកានេះហើយ មានសេចក្តីស្ងើចសរសើរថាត្រូវពិតឥតឃ្លៀងឃ្លាត ៗ សម័យសព្វថ្ងៃនេះ, បានដំណឹងថា នៅក្នុងមហាប្រទេសទាំងឡាយនៅក្នុងទ្វីបអឺរ៉ុប ដែលពីដើមគេមិនជឿព្រះពុទ្ធសាសនាសោះ, លុះបានពិនិត្យដល់ព្រះពុទ្ធសាសនាត្រង់ណេះ គេក៏ជឿ នាំគ្នាកាន់តាម ប្រតិបត្តិតាម ៗ ដូច្នេះ, បានជាព្រះពុទ្ធសាសនាយើងឃើញមានប្រតិស្ឋាននៅក្នុងទ្វីបអឺរ៉ុបស្ទើរតែគ្រប់ប្រទេស គ្រាន់តែច្រើននឹងតិច ចំរើននឹងអន់ថយប៉ុណ្ណោះ ។

ធម៌ជាពុទ្ធសាសនាម្យ៉ាងទៀត សម្រាប់ប្រដៅមនុស្សឲ្យចេះគិតពិចារណាដល់រូបកាយ ឲ្យឃើញជាក់ច្បាស់ថាមិនទៀង ជាទុក្ខ និងមិនមែនជារបស់ខ្លួនហៅថា ព្រះត្រៃលក្ខណ៍ ជាប្រយោជន៍កុំឲ្យមនុស្សទាំងអស់មានសេចក្ដីស្រវឹងទៅក្នុងរូបកាយ ។

ធម៌ជារបៀបនៃពុទ្ធសាសនា ដែលនាំយកមកពន្យល់ក្នុងទីនេះបន្តិចបន្តួចប៉ុណ្ណោះ ដើម្បីឲ្យឃើញជាតួយ៉ាងនៃព្រះពុទ្ធសាសនាដែលមានតម្លៃពិសេស រស់នៅប្រចាំលោកជានិច្ចមិនចុះតម្លៃ ព្រោះជាពាក្យប្រៀនប្រដៅផុតវិស័យគំនិតមនុស្សសត្វ និងទេពតាទាំងអស់, ឥតមាននរណាមួយ ក្រៅអំពីព្រះពុទ្ធ គិតប្រដៅគ្នាឲ្យដូចបានឡើយ ។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់របៀបនេះនៅមានច្រើនណាស់ មិនអាចដកស្រង់យកមកពន្យល់ឲ្យសព្វគ្រប់បានទេ, ព្រោះពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ដែលហៅថា ព្រះធម៌ នោះមានដល់ទៅ ៨ ម៉ឺន ៤ ពាន់ព្រះធម្មក្ខន្ធ ដែលព្រះសង្គីតិការចារ្យបានចែកចេញជាបិដកមាន ៣ គឺ: ព្រះវិន័យ, ព្រះសូត្រ, ព្រះអភិធម្ម ។

ព្រះពុទ្ធសាសនាដែលថាដឹកនាំប្រៀនប្រដៅមនុស្សសត្វ ឲ្យមានប្រយោជន៍ ឲ្យបានសេចក្ដីសុខនោះ មិនមែនឲ្យបានប្រយោជន៍និងសេចក្ដីសុខក្នុងបរលោកដែលយើងមើលទៅមិនឃើញនោះទេ ជាពាក្យ

ប្រៀនប្រដៅឲ្យបានប្រយោជន៍ ឲ្យបានសេចក្តីសុខក្នុងលោកនេះ ទៀតផង ដូចពុទ្ធដីកា ដែលខ្ញុំសូមរៀបរាប់ខ្លះ ៗ ខាងក្រោមនេះ ៖

ក្នុងសិង្គាលោវាទសូត្រ គម្ពីរទីឃនិកាយ បាដិកវគ្គព្រះពុទ្ធជាម្ចាស់ ទ្រង់សំដែងអំពីអបាយមុខ ៦ យ៉ាងចំពោះសិង្គាលមាណពថា: មិនឲ្យផឹកសុរា ១, មិនឲ្យដើរលេងតាមច្រកល្ហកក្នុងវេលាយប់ ១, មិនឲ្យដើរមើលល្បែងមហោស្រព ១, មិនឲ្យលេងល្បែងស៊ីសង មានបៀរប៉ោជាដើម ១, មិនឲ្យសេពគប់មិត្តនឹងមនុស្សខូច យកធ្វើជាមិត្តសំឡាញ់ ១, មិនឲ្យខ្ជិលធ្វើការងាររកស៊ីចិញ្ចឹមជីវិត ១ ។

ក្នុងបរាភវសូត្រ គម្ពីរខុទ្ទកនិកាយ សុត្តនិបាត ព្រះពុទ្ធជាគ្រូនៃយើងទ្រង់បានសំដែងយ៉ាងច្បាស់លាស់ អំពីហេតុដែលនាំឲ្យបានទូវសេចក្តីវិនាស ផ្ទុយគ្នានឹងសេចក្តីចំរើន ចំពោះទេវតា ១ អង្គដែលមាននាមទីងគោត្រមិនប្រាកដ ។

សូមដកស្រង់យកពុទ្ធភាសិតក្នុងបរាភវសូត្រនោះ មកបង្ហាញអស់លោកអ្នកឲ្យបានជ្រាបដូចតទៅ :

១- សុវិជានោ ភវំ ហោតិ ។ ល ។ ធម្មទេស្សី បរាភវោ ។

សេចក្តីថា: នរជនណាមួយមានចំណេះវិជ្ជា គឺចេះអក្សរសាស្រ្ត

លេខនពន្ធគុណហារជាដើម ជាវិជ្ជាលោកិយក្តី វិជ្ជាលោកុត្តរក្តី, នរជននោះនឹងបាននូវសេចក្តីចំរើន ក្នុងលោកទាំងពីរគឺក្នុងលោកនេះនឹងលោកខាងមុខ ។ នរជនណាមួយ ទោះជាគ្រហស្ថក្តី បព្វជិតក្តី ដែលអាប់ឥតចំណេះវិជ្ជាអ្វី នៅក្នុងខ្លួន នរជននោះឈ្មោះជានាំសេចក្តីវិនាសមកដាក់ខ្លួន ក្នុងលោកនេះនឹងលោកខាងមុខមិនខាន ។

២- អសន្តស្ស បិយា ហោន្តិ ។ល។ តំ បរាភវតោ មុខំ ។

សេចក្តីថា: នរជនណាមួយ យកមនុស្សអសប្បុរសពាលយង់ឃ្នង ដែលប្រព្រឹត្តធ្វើតែអំពើលាមកអាក្រក់គ្រប់បែបគ្រប់យ៉ាង មានធ្វើអំពើបាណាតិបាតជាដើម មិនជឿកម្មនឹងផលរបស់កម្ម នៃកុសលអកុសលឡើយ មកធ្វើជាមិត្រសំឡាញ់ រួមសុខ-ទុក្ខជាមួយគ្នា មិនសេពគប់នឹងអ្នកប្រាជ្ញជាមិត្រភក្តិ រាប់អានចូលចិត្តតែនឹងអសប្បុរសប្រុស្តមិត្តដូច្នេះ ជាហេតុជាប្រធានធ្វើឲ្យនរជននោះដល់នូវសេចក្តីវិនាសដែរ ។

៣- និទ្ទាសីលី សភាសីលី ។ល។ តំ បរាភវតោ មុខំ ។

សេចក្តីថា: ជនណាមួយ ល្មោភដេកច្រើន ចូលចិត្តប្រជុំគ្នានិយាយលេងនូវពាក្យពេយពាយឥតប្រយោជន៍, ខ្ជិលច្រអូសមិនធ្វើការងារ,លុះក្នុងអំណាចនៃសេចក្តីក្រោធ, ចិត្តមួរទឹងច្រើន យ៉ាងនេះក៏ជាឧបាយជាប្រធាននាំជននោះឲ្យដល់នូវសេចក្តីវិនាសដែរ ។

៧– យោ មាតរំ វា បិតរំ វា ។ល។ តំ បរាភវតោ មុខំ ។

សេចក្តីថា ជនណាមួយ មានទ្រព្យសម្បត្តិស្តុកស្តម្ភមាំមួន ឥតមានរោគាព្យាធិអ្វីមកបៀតបៀន, ឃើញមាតាបិតាចាស់ជរា មានវ័យកន្លងផុតទៅហើយ មិនជួយចិញ្ចឹមបីបាច់ថែរក្សា ដោយវត្ថុទាំងឡាយ មានភោជនាហារជាដើម ជននោះឈ្មោះថាជាមនុស្សអកតញ្ញូ មិនដឹងឧបការគុណលោកអ្នកដ៏មានគុណ នេះក៏ជាហេតុនៃសេចក្តីវិនាសដែរ ។

៨– យោ ព្រាហ្មណំ សមណំ វា ។ល។ តំ បរាភវតោ មុខំ ។

សេចក្តីថា: នរជនណាមួយ បានឃើញសមណៈ គឺអ្នកបួសក្នុងព្រះពុទ្ធសាសនា, ព្រាហ្មណ៍ ឬ ស្មូមយាចកណាមួយ មករកបិណ្ឌបាត ឬ ស្មូមទាន ហើយខ្លួនពោលពាក្យទ្រគោះបោះបោកបញ្ឆោតដោយមុសាវាទថា គ្មានអ្វីឲ្យទេដូចេះជាដើម អ្នកនោះឈ្មោះថា

ជាមនុស្សក្រខ្វះឬស្សាស្វទុជិន ប្រទូស្តនឹងស្វាមានោះ ទោះបីទៀតក្ដី មិនទៀតក្ដី គប្បីពោលពាក្យសមគួរដោយវាចា ។ ដែលពោលពាក្យអសុរោះ ប្រទេះទៅរកសមណ, ព្រាហ្មណ៍:, ស្វមយាចកនោះ ក៏ជាហេតុជាប្រធាននៃសេចក្ដីវិនាសដែរ ។

៦- បហុតវិត្តោ បុរិសោ ។ល។ តំ បរាភវតោ មុខំ ។

សេចក្ដីថា នរជនណាមួយ មានទ្រព្យសម្បត្តិច្រើន មានមាសប្រាក់កែវពិទូរ្យសូរិកាន្តសុក្កស្វម, មានទាំងគ្រឿងបរិភោគឧបភោគបរិបូណ៌គ្រប់គ្រាន់ តែចិត្តស្វទុជិនកំណាញ់ស្វិតហួសហេតុ បានចំណីអាហារឆ្ងាញ់ពិសា លួចស៊ីតែម្នាក់ឯង មិនចែករំលែកឲ្យទៅអ្នកដទៃផងគ្នាបរិភោគផង, នរជននោះឈ្មោះថាជាមនុស្សអប្បលក្ខណ៍ឥតសិរី គ្មានអ្នកផងដទៃចូលចិត្តរាប់អាន ។ នេះ, ក៏ជាប្រធាននៃសេចក្ដីវិនាសដែរ ។

៧- ជាតិត្ថទ្ធោ ធនត្ថទ្ធោ ។ល។ តំ បរាភវតោ មុខំ ។

សេចក្ដីថា: អ្នកណាមួយ មានជាតិខ្ពង់ខ្ពស់ មានគោត្រត្រកូលឧត្តុង្គឧត្ដម មានសម្បត្តិច្រើន តែមានចិត្តឆ្មើងឆ្មៃ ប្រកាន់

ជាតិត្រកូល មានទ្រព្យសម្បត្តិ ចិត្តរបីងរឹងរូសឃើញញាតិសាលោហិត ឬអ្នកដទៃដែលទីទាល់ក្រ មានចិត្តប្រមាថមើលងាយ មិនរាប់អាន ធ្វើហាក់ដូចជាអ្នកកន្ទៀត ឬធ្វើជាមិនដឹង មិនឃើញ ប្រកាន់អស្មិមានៈ រតើតរតើងក្រអឺតក្រអោង គោងកាច អ្នកនោះឈ្មោះថាស្វែងរកសេចក្តីទុក្ខមកដាក់ខ្លួន អំពើដែលធ្វើទាំងអស់នេះក៏ជាប្រធាន ជាឧបាយនាំបណ្តាលឲ្យបានសេចក្តីវិនាសដែរ ។

៨- ឥត្ថីធុត្តោ សុរាធុត្តោ ។ ល ។ តំ បរាភវតោ មុខំ ។

សេចក្តីថា ជនណាមួយ ប្រព្រឹត្តលេងស្រី ៖ ប្រព្រឹត្តផឹកស្រា, ប្រព្រឹត្តលេងល្បែងស៊ីសងភ្នាល់គ្នា ។ អ្នកលេងស្រីនោះត្រេកអរនឹងស្ត្រីភាព បានរបស់អ្វី ។ មានមាសប្រាក់ជាដើមលបលាក់យកទៅឲ្យតែស្រី ។, ធ្វើឲ្យទ្រព្យសម្បត្តិរបស់ខ្លួនវិនាសអស់ ពីព្រោះតែស្រី; អស់ទ្រព្យសម្បត្តិម្យ៉ាងចំពោះការស៊ីចាយ ដើម្បីឲ្យស្រីស្រឡាញ់ខ្លួន, អស់ម៉្យាង គួងការឲ្យទៅពួកស្រី ។ ដែលខ្លួនត្រូវការយកមកសប្បាយ អស់ម៉្យាងទៀត គួងការទិញថ្នាំយកមកពាក់ ព្យាបាលរោគ ស្វាយ ប្រមេះ ទៀមឡា ឬទឹកនោមផ្អែម ដែលមានសមុដ្ឋាន កើតមកអំពីស្ត្រីពេស្យាផ្កាមាសទាំងនោះ ។ ឯអ្នកផឹកស្រា តែស្រវឹងឡើងកាល

ណា គឺវង្វេងភាំងភ្លេចភ្លេចស្មារតី មិនស្គាល់បាបបុណ្យ គុណទោស ដែលស្គាល់អ្នកធំ អ្នកតូច, យកខុសជាត្រូវ យកត្រូវជាខុសប្រទូស្ត ដល់ខ្លួនឯង ឬ អ្នកដទៃ រហូតដល់ហ៊ានប្រទូស្តចំពោះអ្នកមានសីល មាន គុណវិសេស, សូម្បីមាតាបិតាបង្កើត ក៏ហ៊ានប្រទូស្តគប់ផង ។ ឯអ្នក ដែលប្រព្រឹត្តលេងល្បែងភ្នាល់ស៊ីសង មានបៀ-អាប៉ោង-ឡូ ជាដើម ក៏ជាហេតុនាំឲ្យវិនាសទ្រព្យសម្បត្តិ ដែលរកបានមកដោយក្រ ៗ មិន តែប៉ុណ្ណោះ ថែមទាំងខាតពេលដែលត្រូវរកស៊ីខានរក ព្រោះរវល់តែ នឹងដើរលេង, ខាតទាំងពេលរៀនសូត្រ ( ចំពោះអ្នកសិក្សា ) ខូចទាំង ពេលដេកពេលសម្រាក, ខូចចិត្តខូចគំនិត ភ្លេចភាំងស្មារតី នាំឲ្យ អាប់កិត្តិយសឈ្មោះអាក្រក់ បេះភ្លូតកុហក លួចប្លន់ បោកបញ្ឆោត ប្រវញ្ចយកទ្រព្យរបស់អ្នកដទៃ, ក្បត់ពងការផែនដី ក្បត់ជាតិ, ក្បត់ សាសនា, និងក្បត់ព្រះមហាក្សត្រថែមទៀត ។ កាលបើអំពើទាំងនេះ កើតមានក្នុងខ្លួនហើយ, ខ្លួនត្រូវមានការលក់ផ្ទះសម្បែង, លក់គោក្របី លក់របស់ដូនតា លក់ស្រែចំការចម្ការដំណាំអស់, រហូតដល់ទៅ មានទោសទុក្ខ ជាប់គុកច្រវាក់ ដោយសារតែខ្លួនប្រព្រឹត្តធ្វើនូវអំពើពុំ គប្បី នាំឲ្យគប្រយទុយិស ធ្លាក់ដល់បាត់ជីវិតទៅក៏មាន ៗ

ល្បែងទាំង ៣ ប្រការនេះ ជាហេតុជាប្រធាននាំឲ្យក្ររ នាំឲ្យវេទ្ធិន នាំឲ្យវិនាសហិនហោចទ្រព្យសម្បត្តិ ៗ នេះជាសេចក្តីវិនាសយ៉ាងធំក្រៃលែង ៗ សមដូចសុភាសិតខ្មែរយើងមួយល្បះថា លោកថាក្ររបី ក្ររមួយនឹងស្រី ក្ររមួយនឹងស្រា ក្ររមួយនឹងល្បែងអំពើពាលា បីនេះលោកថា មហាក្ររកន្ទេល ៗ

៤- សេវិ ជារេហិ អសន្ទុដ្ឋោ ៗលៈៗ តំ បរាភវតោ មុខំ ៗ

សេចក្តីថា: បុរសបុគ្គលឯណាមួយ មានចិត្តប្រកបដោយកាមរាគ មិនត្រេកអរនឹងភរិយារបស់ខ្លួន ត្រេកត្រអាលតែនឹងស្ត្រីដទៃ ប្រព្រឹត្តសេពសមនឹងស្ត្រីពេស្យាផ្កាមាស ឬ ភរិយារបស់អ្នកដទៃ ៗ គប់នឹងស្ត្រីពេស្យាផ្កាមាស នាំឲ្យវិនាសទ្រព្យសម្បត្តិ រហូតដល់ធ្លាក់ខ្លួនទៅជាកើតរោគាព្យាធិ មានរោគស្វាយប្រមេះ ទៀមឡាជាដើម ៗ គប់នឹងភរិយាអ្នកដទៃ មានទោសជាទម្ងន់ក្នុងបច្ចុប្បន្នផង ក្នុងបរលោកផង ៗ ទោសក្នុងបច្ចុប្បន្ន គឺកើតទៅជាទាស់ទែងខ្វែងគំនិតគ្នានឹងភរិយាខ្លួនក៏មាន ស្វាមីគេចឹងប្តឹងផ្តល់ក៏មាន ទៅជាមានគំនុំគំគួន លបចាក់កាប់សម្លាប់គ្នាក៏មាន, ទាស់ខុសនឹងច្បាប់សម្រាប់ប្រទេស ត្រូវរាជការ

លក់ពិន័យត្រូវជាប់ឃុំឃាំងមានដាក់ខ្នោះ ដាក់គុកច្រវាក់ក៏មាន បង់ទ្រព្យសម្បត្តិក៏មាន ។ ទោសក្នុងបរលោក, លុះធ្វើមរណកាលអំពីលោកនេះទៅកាន់លោកខាងមុខ សោយទុក្ខក្នុងនរក ទៀងរការដែកអស់កាលជាយូរ សេសសល់ផលកម្មនោះ បានមកកើតជាមនុស្ស ទុព្វលភាពខ្វាក់ខ្វិន ភរិយាសោក ក៏មានចិត្តមិនស្លូតត្រង់ចំពោះខ្លួន, មិត្តភក្តិក៏មិនស្លូតសុចរិតមានចិត្តមិនស្មោះត្រង់នឹងខ្លួន, កូនប្រុសស្រីក៏មិនលុះក្នុងដំបូន្មាន, ទ្រព្យសម្បត្តិក៏អន្តរធាន ទាំងនេះក៏ជាហេតុជាប្រធានធ្វើបុរសបុគ្គលនោះឲ្យដល់នូវសេចក្តីវិនាសដែរ ។

១០- អតីតយោព្វនោ ពោសោ ។ល។ តំ បរាភវតោ មុខំ ។

សេចក្តីថា: នរជនណាមួយ មានវ័យកន្លងហួសផុតទៅហើយ ធ្មេញបាក់ត្រហុប, សក់ស្កូវព្រោងឌី, ស្បែកនឹងតថែមវែងតាឡើងជាបួន សាច់ស្បែកជ្រីវជ្រួញយុរយា មិនគិតប្រយោគរូបអាត្មា ទៅនាំយកឯស្រីក្រមុំដោះក្បត្រពុំដូចផ្លែទម្លាប់ សាច់ខ្ចីទន់ល្វន់ល្វាសសស្រួលដូចបណ្តូលចេក មកធ្វើជាភរិយា សេចក្តីដំរេកត្រេកត្រអាលដោយកាមរាគ មិនល្មមគ្រាន់ដល់ចិត្តភរិយា ដ្បិតខ្លួនគេក្មេងខ្លួនឯងចាស់ ធ្វើដូចម្តេចគេនឹង

ស្រឡាញ់ពេញចិត្តបាន, សេចក្តីប្រចណ្ឌក៏កើតមានឡើង កើតទុក្ខក្តៅ
ក្រហាយពេលកលក្នុងសន្តាន ព្រោះរាគៈគ្របសង្កត់ ជួនកាលកើតទុក្ខ
ស្លាប់ទាំងខ្លួនក៏មាន ហេតុនោះក៏ជាប្រធាននៃសេចក្តីវិនាសដែរ ។

១១- ឥត្ថី សោណ្ឌី វិកិរណី ។ល។ តំ
បរាភវតោ មុខំ ។

សេចក្តីថា: បុរសណាមួយលើកតំកើងនូវស្ត្រីអកលេង ស៊ីផឹក
ខ្ជះខ្ជាយឲ្យជាធំក្នុងផ្ទះ ពុំនោះសោតស្ត្រីណាមួយលើកតំកើងបុរសមាន
សភាពដូច្នោះដែរ ឲ្យជាម្ចាស់ផ្ទះ ជាមនុស្សខ្ជះខ្ជាយ ចាយវាយឥត
សណ្តាប់ធ្នាប់ បុរសស្ត្រីនោះនឹងមានសេចក្តីហិនហោច ខ្សត់ខ្សោយ
ក្រីក្រលំបាកវេទនា ហេតុនោះក៏ជាប្រធាននៃសេចក្តីវិនាសដែរ ។

១២- អប្បភោគោ មហាតណ្ហោ ។ល។ តំ
បរាភវតោ មុខំ ។

សេចក្តីថា: បុរសបុគ្គលណាមួយ កើតក្នុងត្រកូលក្សត្រមាន
ភោគសម្បត្តិនឹងបរិវារសម្បត្តិតិច ចំណេះវិជ្ជាតិច, តែមានសេចក្តី
ប្រាថ្នា លោភលន់ពន់ប្រមាណ ចង់សោយរាជ្យជាម្ចាស់ផែនដី ដែលមិន
គប្បីខ្លួននឹងទទួលបាន ម្ល៉ោះហើយចែកចាយទ្រព្យសម្បត្តិដែលមានចំនួន

តិចតួចស្តួចស្តើងបពោះបញ្ចូលមនុស្សទាំងឡាយ មានសេចក្តីលោភជាដើម លុះមិនបានសម្រេចដូចបំណង ក៏ត្រូវខូចដល់ខ្លួនទោសជាទម្ងន់ ហេតុនោះក៏ជាប្រធាននៃសេចក្តីវិនាសដែរ ។

ពុទ្ធដីកា ក្នុងបកស៊ូត្រទាំង ១២ បទនេះ បើយើងពិនិត្យគិតតាមលំអាននេះទៅ យើងនឹងបានយល់ថា: ត្រូវពិតដូចព្រះពុទ្ធដីកានេះមែន ។

ម្យ៉ាងទៀត, ព្រះអង្គបង្ហាញប្រយោជន៍បច្ចុប្បន្ន ៤ យ៉ាងទៀតគឺ :

១- ឧដ្ឋានសម្បទា ឲ្យមានព្យាយាមក្នុងការរកចិញ្ចឹមជីវិត ។

២- អារក្ខសម្បទា ឲ្យចេះថែរក្សាទ្រព្យសម្បត្តិ ដែលកើតឡើងដោយសេចក្តីព្យាយាមនោះ ។

៣- កល្យាណមិត្តតា ឲ្យរកមនុស្សល្អធ្វើជាមិត្រភក្តិ

៤- សមជីវិតា ឲ្យចេះចាយវាយទ្រព្យសម្បត្តិតាមសមគួរដល់របរដែលខ្លួនរកបាន ។

-ព្រះអង្គប្រដៅមនុស្សទាំងអស់ឲ្យចេះសង្គ្រោះគ្នាទៅវិញទៅមកតាមជាន់ថ្នាក់, ដូចមាតាបិតានឹងបុត្រធីតា, គ្រូនឹងសិស្ស, ភរិយានឹងស្វាមី មិត្តសំឡាញ់នឹងមិត្តសំឡាញ់ផងគ្នា, ចៅហ្វាយនាយនឹងកម្មករ, ព្រះមហាក្សត្រនឹងប្រជាពលរដ្ឋ ។

- ព្រះអង្គប្រដៅមនុស្សឲ្យចេះសំអាតកងកាយ សំអាតទីលំនៅ និងសំលៀកបំពាក់ជាដើម ដែលក្នុងបាលីលោកហៅថា: វត្ថុវិសទកិរិយា ។

ព្រះពុទ្ធសាសនា ដែលនាំយកមកពន្យល់ បន្តិចបន្តួចប៉ុណ្ណោះ គ្រាន់តែឲ្យឃើញថា ជាពាក្យប្រៀនប្រដៅ មានប្រយោជន៍ក្នុងបច្ចុប្បន្ននេះឯង ។

ព្រះពុទ្ធដីកានៃព្រះសម្ពុទ្ធទាំងអស់ បើអស់លោកអ្នកឯណាមួយបាន សិក្សា បានសង្កេតពិនិត្យមើលឲ្យសព្វគ្រប់ ហើយប្រតិបត្តិតាមគង់ នឹងបានដឹងថា ព្រះពុទ្ធប្រាកដជាអ្នកវិទ្យាសាស្ត្រខាងផ្លូវចិត្ត, ជាអ្នកដឹកនាំ មនុស្សឲ្យដើរតាមផ្លូវសន្តិភាព ស្ងប់កាយស្ងប់ចិត្ត មិនឲ្យកើតវិវាទឈ្លោះ ទាស់ទែងគ្នា ដែលក្លាយទៅជាសង្គ្រាម កាប់ចាក់សម្លាប់គ្នា; បង្ហូរឈាម គ្នារវាងមនុស្សនឹងមនុស្សឡើយ ។

រៀបរាប់មកអំពីតម្លៃនៃព្រះពុទ្ធសាសនា ដែលដឹកនាំមនុស្សឲ្យ មានប្រយោជន៍ក្នុងបច្ចុប្បន្ននឹងបរលោក សន្មតថាចប់តែប៉ុណ្ណោះ ។

# ព្រះអភិធម្មបិដក

## គម្ពីរព្រះកថាវត្ថុ

លោក ប៊ូ-ប៊ូ ប្រែរៀបរៀង

## អសុចិសុក្កវិសដ្ឋកថា

(តមក)

---

បរវាទី– ទេវតាទាំងឡាយជាពួកនៃមារ មានចិត្តប្រទុស្តនាំទឹកអសុចិមកដាក់ក្នុងអវយវៈដំបាំង ហេតុតែពួកភិក្ខុទាំងនោះ មិនទាន់បានសម្រេចព្រះអរហត្ត សឹងលក់ក្នុងវេលារាត្រី លុះដល់ពេលជិតភ្លឺភ្ញាក់ពីលក់ឃើញទឹកអសុចិ ក៏សំគាល់ថា ទឹកអសុចិរបស់ខ្លួនហូរចេញមក ទើបដាស់តឿនរំឮកស្មារតីគ្នាឲ្យពិចារណា នូវសង្ខារធម៌ឲ្យឃើញច្បាស់ ដោយព្រះត្រៃលក្ខណញ្ញាណ បានសម្រេចព្រះអរហត្តកាត់កិលេសដាច់ជាសមុច្ឆេទប្បហារ នាំគ្នាចេញពីព្រៃចូលមកក្នុងវត្ត ប្រាថ្នានឹងថ្វាយបង្គំគាល់ព្រះបរមគ្រូ ដំណាលរឿងខ្លួនប្រាប់ភិក្ខុទាំងឡាយ ។ ចូលចិត្តថា ពួកភិក្ខុដែលត្រឡប់មកពីព្រៃនោះមិនមែនជាព្រះអរហន្តទេ ប៉ុន្តែនិយាយថាខ្លួនបានសម្រេចព្រះអរហត្ត ទើបនាំសេចក្ដីនោះក្រាបទូលព្រះបរមសាស្ដា ។ ឲ្យហៅរកពួកភិក្ខុទាំងនោះ ចូលមកគាល់ ហើយទ្រង់ត្រាស់សួររឿងរ៉ាវ ។

សកវាទី– សត្ថា ច ជានាតិ សម្តេចព្រះបរមសាស្តាមិនទ្រង់ជ្រាបថា ពួកភិក្ខុទាំងនោះបានសម្រេចព្រះអរហត្តទេឬអ្វី បានជាចាំឲ្យហៅគេចូលមកគាល់ហើយត្រាស់សួរដូច្នោះ ?

បរវាទី– សម្តេចព្រះសម្ពុទ្ធទ្រង់ជ្រាបប្រវត្តិហេតុនោះគ្រប់ប្រការ គ្មានសល់បន្ទោះត្រង់ណាទេ ; ប៉ុន្តែទ្រង់ត្រាស់សួរភិក្ខុទាំងនោះឲ្យបានជាដើមហេតុ ទើបបានទ្រង់បញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយ កាលត្រាស់សួរភិក្ខុទាំងឡាយ ។ ក៏ក្រាបទូលសេចក្តីនោះតាំងពីដើមរហូតដល់ចប់ បានទ្រង់ព្រះសណ្តាប់ហើយទើបទ្រង់តិះដៀលនូវភិក្ខុដែលមិនបានសង្រួមឥន្ទ្រីយ៍ប្រាំមួយប្រការ ហើយទើបទ្រង់បញ្ញត្តសិក្ខាបទ អ្នកគប្បីចូលចិត្តដោយន័យដូច្នេះចុះ ។

អសុចិសុក្កវិសដ្ឋិកថា ចប់ ។

---

## សុគន្ធជាតិកថា

ពុទ្ធស្ស ភគវតោ ឧច្ចារបស្សាវោ អតិវិយគន្ធោ អញ្ញេ គន្ធជាតេ អធិគណ្ហាតីតិ អាមន្តា ភគវា គន្ធភោជីតិ ន ហេវំ វត្តព្វេ ភគវា គន្ធភោជីតិ ។ ននុ ភគវា ឱទនំ កុម្មាសំ ភុញ្ជតីតិ ។

វារៈនេះនឹងវិសជ្ជនាក្នុងសុគន្ធជាតិកថាតទៅ ក្នុងសុគន្ធជាតិកថា

នេះ សម្តេចព្រះមានព្រះភាគត្រាស់ទេសនាជាសកវ៉ាទីបរវ៉ាទីដូចតទៅនេះ

សកវ៉ាទី– ពុទ្ធស្ស ភគវតោ ឧច្ចារបស្សាវោ ព្រះឧច្ចារៈនឹងបស្សាវៈ[១]របស់ព្រះពុទ្ធទ្រង់ព្រះភាគនោះ មានក្លិនក្រអូបឈ្ងុយឈ្ងប់លើសលុប គ្របសង្កត់ នូវគ្រឿងក្រអូបទាំងឡាយដទៃដែលមាននៅក្នុងលោកនិស្ស័យទាំងអស់ ពាក្យនេះពិតមែនឬមិនពិតទេ ?

បរវ៉ាទី– អាមន្តា អើ ! ពិតមែន ដូចពាក្យអ្នកថានោះហើយ ព្រះឧច្ចារៈនឹងបស្សាវៈរបស់ព្រះពុទ្ធទ្រង់ព្រះភាគនោះ ក្រអូបក្រអែបផ្សព្វផ្សាយលើសគ្រឿងក្រអូបក្នុងភពទាំងបី ។

សកវ៉ាទី– ភគវា ភត្តភោជីតិ សម្តេចព្រះមានព្រះភាគជាទីសេពគប់នៃទេពតានឹងមនុស្សទាំងឡាយ ព្រះអង្គសោយតែភោជនា-ហារដែលលាយទៅដោយវត្ថុមានក្លិនក្រអូបឈ្ងុយ មិនសោយនូវវត្ថុជាអាហាររបស់មនុស្ស មានបាយនឹងសណ្តែកល្ងជាដើមទេ ឬដូចម្តេច ?

បរវ៉ាទី– នហេវំ វត្តព្វេ អ្នកកុំនិយាយយ៉ាងហ្នឹងឡើយ សម្តេចព្រះមានព្រះភាគ មិនមែនសោយតែគ្រឿងក្រអូប នឹងភោជ-នាហារដ៏លាយដោយវត្ថុមានក្លិនក្រអូបនោះទេ ព្រះអង្គទ្រង់គោចរបិណ្ឌបាតតាមពុទ្ធវិស័យបានយ៉ាងណា ក៏សោយយ៉ាងនោះ នឹងកំណត់

---

១–ព្រះឧច្ចារៈ ប្រែថា អាចម៍, ព្រះបស្សាវៈ ប្រែថា ទឹកនោម ។

ថា ព្រះអគ្គិសោយតែតែមានក្នុងត្រអូបមិនបានទេ ដូចពាក្យក្នុងព្រះសូត្រថា នាងមល្លិកាជាធីតា នៃនាយមាលាការ នាងបាននាំយកនំល្មមកថ្វាយដាក់ចុះក្នុងបាត្រ ហេតុតែកុសលនោះ នាងបានជាអគ្គមហេសីនៃព្រះបាទបសេនទិកោសលរាជ ឲ្យឃើញផលជាទិដ្ឋធម្មវេទនីយ៍ ។ ក្នុងព្រះសូត្រមួយទៀតថា ព្រះមហាមោគ្គល្លានត្ថេរជាម្ចាស់និមន្តទៅទូន្មានមច្ឆរិយសេដ្ឋី ឲ្យធ្វើនំអំបែងមកថ្វាយព្រះពុទ្ធអង្គក្នុងវត្តជេតពន ។ ក្នុងព្រះសូត្រខ្លះទៀតថា ព្រះពុទ្ធអង្គបរមគ្រូសោយភត្តាហារ ដែលជនទាំងឡាយនាំយកមកថ្វាយជាច្រើន ប្រកបដោយសូបព្យញ្ជនៈ គឺបន្ទុំនឹងអន្លក់ស្រស់ ៗ ជាច្រើនយ៉ាង ប៉ុន្តែក្នុងព្រះវិន័យថា ព្រះពុទ្ធអង្គស្តេចយាងទៅក្នុងនគរវេរញ្ជា ចាំព្រះវស្សាអស់ត្រៃមាស មារចូលបង្កិលចិត្តអ្នកនគរ មិនឲ្យអ្នកណាម្នាក់ជ្រះថ្លានឹងព្រះពុទ្ធអង្គ ឯវេរញ្ជ-ព្រាហ្មណ៍ ថ្វាយអាហារបិណ្ឌបាត្រ បានសោយតែបាយគ្រៀមបាយក្តាំង ដែលឈ្មួញសេះនៅក្នុងនគរវេរញ្ជានាំចូលទៅថ្វាយ ៗ ក្នុងព្រះសូត្រ នឹងព្រះវិន័យនោះ មានសេចក្តីជាអនេកបរិយាយដូចសំដែងមកបុំណោះជាដើម ។

សកវាទ- ឆន្ទ កតកា សម្តេចព្រះមានព្រះភាគសោយបាយនឹងសូបព្យញ្ជនៈ គឺសម្លអន្លក់នំសណ្តកល្មមែនឬទេ ?

បាលី- សម្តេចព្រះមានព្រះភាគ សោយភោជនាហារតាម
តែការគួរដែលបានមកដោយភិក្ខាចារវត្ត មិនមែនរើសសោយតែភោជន
មានក្លិនក្រអូបទេ ។

សកវាទី- ហាញ្ចិ ភគវា បើសម្តេចព្រះមានព្រះភាគ
សោយភោជនាហារ គឺបាយត្រីសាច់សណ្តែកល្ងជាដើមដូច្នេះ ទើបថា
ព្រះឧច្ចារៈបស្សាវៈរបស់ព្រះពុទ្ធជាម្ចាស់ក្រអូប គ្របសង្កត់ក្លិនគ្រឿងក្រអូប
ទាំងឡាយដទៃបានដែរឬអ្វី ? យើងនៅតែសង្ស័យ មិនទាន់ជឿពាក្យ
អ្នកឡើយទេ ។

បរវាទី- ភោ វត្តរេ វត្តពេ ជនទាំងឡាយមិនគប្បី
និយាយថា ព្រះឧច្ចារៈនឹងបស្សាវៈរបស់ព្រះមានព្រះភាគ មិនក្រអូបទេ
រមែងនិយាយថា ក្រអូបគ្រប់គ្នា ; សម្តេចព្រះមានព្រះភាគនោះ ជា
មនុស្សអស្ចារ្យមិនគួរបុគ្គលនឹងសង្ស័យទេ ព្រោះហេតុព្រះអង្គបានកសាង
សន្សំ កងការកុសលរាប់ជាតិ ទាល់តែបានសម្រេចព្រះសព្វញ្ញុ-
តញ្ញាណជាយូរយារណាស់ រាប់ដោយកោដិនៃកប្បជាច្រើន បំពេញ
បញ្ចមហាបរិច្ចាគ លះទ្រព្យ, លះព្រះអង្គ, លះព្រះជន្ម, លះព្រះ
អគ្គមហេសី, លះព្រះឱរសព្រះធីតា គ្រាន់តែឆ្កៀលព្រះនេត្រចេញបំ
ពេញទាន នឹងឲ្យដួងហឫទ័យដោយសព្វ នឹងកាត់ព្រះសិរឲ្យជាទាន

ទឹងប្រមាណកប់ជាតិមិនបាន នឹងបាច់និយាយទៅថ្វី ដល់ទៅព្រះឧច្ចារៈ ទឹងព្រះបស្សាវៈថាមិនបានក្រអូប គឺក្រអូបដោយសម្តេចព្រះពុទ្ធអង្គជាអគ្គបុគ្គល គេអ្នកណាទឹងប្រៀបផ្ទឹមឲ្យត្រឹមស្មើគានទេ គឺក្រអូបដោយហេតុជាមនុស្សអច្ឆរិយពិតប្រាដក ហើយព្រះអង្គទ្រទ្រង់នូវអធិសីល អធិចិត្ត អធិបញ្ញាក្រៃលែងជាងព្រះអរិយទាំងឡាយនោះៗ លុះតែបានស្តាប់នូវព្រះពុទ្ធាធិប្បាយ ទើបបានទ្រទ្រង់នូវអធិសីល អធិចិត្ត អធិបញ្ញា ក្នុងកាលជាខាងក្រោយ សម្តេចព្រះមានព្រះភាគជាម្ចាស់មានព្រះឧច្ចារៈ ទឹង ព្រះបស្សាវៈគ្រប់សព្វគ្រឿងក្រអូបទាំងពួងនោះ គួរទឹងជឿស្តាប់បានដោយពុទ្ធវិស័យ បុគ្គលមិនគួរគិតឆ្ងល់ទេ គ្រាន់តែបុគ្គលស្តាប់ព្រះធម៌ទេសនាហើយបញ្ចេញវាចាថាសាធុៗ ប៉ុណ្ណោះ ក្លិនកាយក្រអូបដូចខ្លឹមចន្ទន៍ ក្លិនមាត់ក្រអូបដូចក្លិនផ្កាឧប្បលទៀត ក្នុងព្រះពុទ្ធសាសនានេះបាន ដូចព្រះមហាថេរជាស្វាមីរបស់ស្ត្រី ដែលព្រះបាទបសេនទិកោសល នាំយកទៅទុកក្នុងព្រះបរមរាជវាំង ។

ប្រការមួយទៀត ដូចសន្តតិមហាមាត្យ កាលពីជាតិមុនដើរត្រាច់ប៉ាវគងប្រកាសឲ្យអ្នកនគរស្តាប់ព្រះសទ្ធម្មទេសនា ក្លិនមាត់ក្រអូបឈ្ងុយ ផ្សាយចេញដូចក្លិនផ្កាឧប្បល ក្លិនសរីរៈកាយក្រអូបដូចក្លិនខ្លឹមចន្ទន៍ សេចក្តីនេះមានច្បាស់នៅក្នុងរឿងសន្តតិមហាមាត្យ ។ កាល

លោកបានសម្រេចព្រះអរហត្តហើយ ទូលលានឹងចូលអមតមហានិព្វាន ហើយក្រាបទូលនូវកុសលដែលខ្ញុំបានធ្វើពីជាតិមុនមក ចំពោះសម្តេចព្រះមានព្រះភាគចប់ហើយ ទើបចូលកាន់ព្រះនិព្វាន ។

ហេតុដូច្នេះ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ព្រះឧច្ចារៈនឹងព្រះបស្សាវៈរបស់ព្រះពុទ្ធអង្គនោះ ក្រអូបគួបសង្កត់នូវគ្រឿងក្រអូបទាំងពួងដោយពុទ្ធវិស័យ ហើយគុនសីលរបស់ព្រះមានព្រះភាគនោះ ក្រអូបទូទៅពេញសាកលលោកធាតុ ដោយអំណាចគុនរបស់ព្រះពុទ្ធអង្គនោះ រមែងជាទីស្រឡាញ់នៃទេវតានឹងមនុស្ស ។

ព្រះអដ្ឋកថាចារ្យពោលទុកថា ឥន្ទសាលគុហាយំ វិហារន្តោ កាលសម្តេចព្រះបរមសាស្តាចារ្យសម្រេចពុទ្ធកិច្ចដោយចតុពិធឥរិយាបថក្នុងឥន្ទសាលគុហា ។ អថខោ កកភា ក្នុងគ្រានោះ សម្តេចព្រះមានព្រះភាគទ្រង់ប្រឈួនរោគាពាធ សក្កោ ទេវរាជា សម្តេចអមរិន្ទទេវរាជទ្រង់ជ្រាបនូវប្រវត្តិហេតុនៃព្រះប្រឈួន ទើបស្តេចប្រញាប់ប្រញាល់ចុះពីតាវតឹង្សពិភព មកកាន់សំណាក់សម្តេចព្រះបរមគ្រូធ្វើឧបដ្ឋាកៈដោយគោរពពុំមានសេចក្តីរង្កៀសធុញទ្រាន់សោះឡើយ សីសេន នីហារន្តោ នាំយកនូវភាជនៈដាក់ព្រះឧច្ចារៈនឹងព្រះបស្សាវៈនៃព្រះមានព្រះភាគ ដោយព្រះសិរ ទៅចាក់ចោលក្នុងមហាសមុទ្រ

ហាក់ដូចជាកាជនៈដាក់គ្រឿងក្រអូប មានព្រះភក្ត្រស្រស់ប៉ប្រឹមញញឹម ញញែមឥតដូរ ឬក្រញូវចិត្តបន្តិចសោះឡើយ លុះព្រះពុទ្ធអង្គសះជាព្រះរោគាពាធហើយ ព្រះឥន្ទ្រាធិរាជក៏វិលទៅកាន់ទេវស្ថានវិញ ។

ធម្មសភាយំ កថំ សមុដ្ឋាបេសុំ ភិក្ខុទាំងឡាយសន្និបាតប្រជុំគ្នាក្នុងរោងធម្មសភាហើយ សន្ទនាគ្នាថា អហោ ពុទ្ធា·នុភាវោ ទុហ្វុ ! គួរឱ្យអស្ចារ្យនឹងអានុភាពរបស់ព្រះពុទ្ធជាម្ចាស់ពេកណាស់ អម្បាលសម្តេចអមរិន្ទទេវរាជជាធំជាងទេវតា ក្នុងទេវ·កពាម្តេចគង់ចុះមកបម្រើព្រះអង្គ ព្រោះហេតុមានសេចក្តីស្រឡាញ់ព្រះបរមសាស្តាយ៉ាងក្រៃលែង ។ សត្ថា អាគន្ត្វា កាលដែលភិក្ខុទាំងនោះកំពុងតែសន្ទនាគ្នាដូច្នោះ សម្តេចព្រះបរមសាស្តាទ្រង់ព្រះសណ្តាប់ដោយព្រះសោតធាតុ ទើបស្តេចយាងមកកាន់រោងធម្មសភាគង់លើព្រះបវរពុទ្ធាសនៈ ហើយមានព្រះពុទ្ធដីកាសួរថា កាយ នុត្ថ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងពួងមកសន្និបាតក្នុងរោងធម្មសភា សន្ទនាគ្នាអំពីរឿងអ្វី ។

សព្វាទិ- កស្មា ហេតុអ្វី បានជាសម្តេចព្រះសាស្តាស្តេចមកដល់ហើយត្រាស់សួរ ? ។ ពាក្យដែលថាព្រះអង្គត្រាស់សួរនេះហេតុមានសេចក្តីសង្ស័យណាស់ ព្រោះពាក្យមុននឹងពាក្យក្រោយមិន

សមគ្គា ។ ដែលថាព្រះអង្គទ្រង់ជ្រាបហើយត្រាស់សួរនោះមិនស្រប គ្នាសោះ ។ បើថាមិនត្រាស់សួរទើបស្របគ្នា ព្រោះហេតុថាព្រះសម្មាសម្ពុទ្ធលះបង់នូវមាយាបានដាច់ស្រេចហើយ ។ បើទ្រង់ជ្រាបរួចហើយនៅតែត្រាស់សួរដូច្នោះ ពាក្យដែលថា ព្រះអង្គលះបង់មាយាបានជ្រះស្រឡះហើយនោះ មិនគួរឲ្យជឿសោះឡើយ ។

បរវាទី- ចូរអ្នកកុំយល់ឃើញដូច្នោះ ខុសទេ ; ការដែលព្រះពុទ្ធជាអម្ចាស់ទ្រង់ជ្រាបហើយនៅតែត្រាស់សួរនោះ មិនមែនជាអាការនៃមាយាសោះឡើយ ដ្បិតព្រះអង្គនឹងទ្រង់លើកសេចក្ដីដែលពួកភិក្ខុក្រាបទូលនោះឡើងជាឧបត្តិហេតុ ហើយនឹងបានសំដែងព្រះសទ្ធម្មទេសនា ។

ភិក្ខាបា វុត្ត កាលដែលព្រះពុទ្ធអង្គត្រាស់សួរនោះ ភិក្ខុទាំងពួងក៏ក្រាបទូលសេចក្ដីដែលខ្លួនសន្ទនាគ្នាតាំងអំពីដើមរហូតដល់ចប់ ព្រះពុទ្ធអង្គទ្រង់ប្រទានព្រះសទ្ធម្មទេសនាថា សីលវតំ គន្ធោ ក្លិននៃសីលនោះ ក្រអូបទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្រអូបទៅក្នុងទិសខាងក្រោមនិងខាងលើ ក្រអូបទៅច្រាសខ្យល់ក៏បាន បណ្ដោយខ្យល់ក៏បាន ឥតប្រកាន់ទិសទីណាឡើយ ក្រអូបក្រៃលែងជាងក្លិននៃគ្រឿងក្រអូបទាំងពួង បណ្ដាគ្រឿងក្រអូបដែលមានក្នុងស្ថានមនុស្សនិងស្ថានសួគ៌ ។ ក្លិនក្រអូបវិសេសបំផុត ក្នុងមនុស្សលោកនោះ គឺក្រស្នាក្លាំពាក់

ទឹងខ្លឹមចន្ទន៍ជាដើម មិនអាចក្រអូបទៅប្រាសខ្យល់បានឡើយ ក្លិននៃបុប្ផជាតិដែលក្រអូបក្នុងស្ថានសួគ៌នោះ បានដល់ក្លិនផ្កាបារិច្ឆត្តកព្រឹក្សក្រអូបទៅប្រាសខ្យល់បានក៏ពិតមែនហើយ ប៉ុន្តែមានកំណត់ ។ ឯក្លិននៃសីលរបស់បុគ្គលអ្នកមានសីលនេះ ក្រអូបឈ្លួយឈ្លប់សាយកាយទៅរហូតដល់ព្រហ្មលោក [illegible] មិនចេះបាត់ក្រអូបសោះឡើយ ក្រអូបទាំងថ្ងៃទាំងយប់គ្រប់ពេលវេលាមិនចេះឈប់ ហេតុដូច្នោះ បានជាសម្តេចអមរិន្ទទេវរាជចុះមកបម្រើព្រះតថាគត ។

តាមលំអានព្រះពុទ្ធដីកាសំដែងព្រះសទ្ធម្មទេសនាដូច្នេះ បណ្ឌិតជាតិអ្នកមានបញ្ញាញាណបានសមាទាននូវសីលហើយ គប្បីព្យាយាមរក្សាឲ្យបរិសុទ្ធល្អ ទើបបានជាទីស្រឡាញ់របស់មនុស្ស ព្រមទាំងទេវតា បើទុកជាមានសត្រូវឬអមនុស្សមកប្រទូសរ៉ាយ ក៏មិនបាន ។

ឯព្រះធម្មទេសនាព្រះឋស្សាវៈរបស់ព្រះសត្ថាសម្ពុទ្ធក្រអូបលើសលែងគ្រឿងក្រអូបទាំងអស់ក្នុងលោកវិស័យនោះ ជាពុទ្ធប្រពៃណីរបស់ព្រះពុទ្ធជាម្ចាស់ទាំងពួង បុគ្គលមិនគួរនឹងគិតរវៀលទេ ព្រោះជាព្រះពុទ្ធវិស័យនោះឈ្មោះថា អចិន្តេយ្យហេតុ ។ សេសមេត្ថ យថា បាលិយំ ឯវំ ពាក្យដ៏សេសសល់ក្រៅពីបានសំដែងមកនេះ ដូចជាពាក្យក្នុងព្រះបាលី ពុំបានខុសពីគ្នាទេ ។

សុគន្ធជាតិកថា ចប់ ។

# មធុរសវាហិណី

សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

(តមក)

---

## ឥន្ទកភាជវគ្គទី ២ មានរឿងនិទាន ១០

### ឥន្ទកភាជវត្ថុកថា

សំដែងរឿងនិទានព្រះបាទឥន្ទកភាជជាបឋមក្នុងវគ្គទីពីរ ដោយបាលីថា: ឥតោ កិរ កប្បសតសហស្សមត្ថកេ បទុមុត្តរោ នាម សត្ថា លោកេ ឧប្បជ្ជិ ដូច្នេះជាដើម

អធិប្បាយសេចក្តីថា: គេបានឮរឿង ៗ មកថា: មានព្រះសាស្តាចារ្យមួយព្រះអង្គទ្រង់ព្រះនាមបទុមុត្តរ: ទ្រង់បានត្រាស់ដឹងបរមាភិសេកសម្ពោធិញ្ញាណ ជាព្រះពុទ្ធប្រាកដក្នុងលោក ក្នុងទីបំផុតមួយសែនកប្បអំពីកប្បយើងនេះ ហើយព្រះអង្គញុំាងមនុស្សលោកព្រមទាំងទេវលោកឲ្យឆ្លងរួចផុតចាកសំសារវដ្ត ឲ្យបានសម្រេចនូវមគ្គនិងផលដល់ព្រះនិព្វានជាទីរលត់នៃទុក្ខទាំងពួង ៗ

ក្នុងសម័យនោះ មានកុដុម្ពិកម្នាក់ បានស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តាចារ្យហើយមានចិត្តជ្រះថ្លាបាននិមន្តព្រះភិក្ខុសង្ឃ មានអង្គព្រះសម្មាសម្ពុទ្ធជាប្រធាន ហើយតាក់តែងនូវមហាទានបានធ្វើប្រដាប់នូវ

ទីលំនៅរបស់ខ្លួនឲ្យល្អបីដូចជាភពទេវតា ហើយចាត់ចែងឲ្យក្រាលទីអាសនៈដ៏ប្រសើរ គួរដល់ព្រះសម្មាសម្ពុទ្ធ អារាធនានិមន្តព្រះមានព្រះភាគថា: បពិត្រព្រះអង្គដ៏ចំរើន កាលនេះជាកាលគួរដល់ព្រះអង្គ ហើយសូមព្រះអង្គព្រមទាំងភិក្ខុសង្ឃនិមន្តចូលទៅកាន់គេហ៍ភត្ត ក្នុងកាលឥឡូវនេះឯង ។

កាលនោះ ព្រះមានព្រះភាគមានព្រះភិក្ខុសង្ឃច្រើន ចោមរោមជាបរិវារ ស្តេចចូលទៅកាន់គេហ៍ភត្តដោយពុទ្ធានុភាពដ៏ប្រសើរ ហើយទ្រង់គង់នៅលើពុទ្ធាសនៈដែលបុគ្គលតាក់តែងថ្វាយ ។

លំដាប់នោះ កុដុម្ពិកព្រមទាំងបរិស័ទរបស់ខ្លួន ក៏មានចិត្តរីករាយត្រេកអរជ្រះថ្លាពន់ពេក បានគង្គាសចង្ហាន់ដ៏មានឱជារសឆ្ងាញ់ពិសាជាអនេក ថ្វាយព្រះមានព្រះភាគព្រមទាំងភិក្ខុសង្ឃ ។

កាលនោះ មានព្រះមហាថេរមួយព្រះអង្គ ព្រះនាមវិសភត្ថេរ ជាសាវកដ៏ប្រសើរលើសជាងព្រះថេរៈទាំងឡាយ ដែលជាអ្នកទ្រទ្រង់នូវធុតង្គ ក្នុងសាសនានៃព្រះមានព្រះភាគអង្គនោះឯង, លោកត្រាច់ទៅបិណ្ឌបាតតាមលំដាប់ច្រកជាប្រក្រតី ក៏បានចូលទៅឈរជិតទ្វារផ្ទះនៃកុដុម្ពិកនោះ ។

ចំណែកឯកុដុម្ពិកនោះបានឃើញព្រះថេរៈហើយ ក៏ទូលអារាធនានិមន្តថា: បពិត្រលោកម្ចាស់ដ៏ចំរើន ! ព្រះសាស្តាគង់នៅឯគេហដ្ឋាន

របស់ខ្ញុំនោះ សូមលោកម្ចាស់និមន្តចូលមក ។ ព្រះថេរៈលោកពុំបានទទួលនិមន្តចូលទៅឡើយ ហើយលោកក៏និមន្តហួសទៅ ។ វិកុដុម្ពិកចូលទៅកាន់សំណាក់ព្រះមានព្រះភាគហើយ ក្រាបបង្គំទូលសួរថា: បពិត្រព្រះមានបុណ្យដ៏ចំរើន បុគ្គលដែលប្រសើរជាងគេដោយគុណវិសេស វៀរលែងតែព្រះអង្គ ; ក្នុងមនុស្សលោកព្រមទាំងទេវ-លោកមានដែរឬទេ ?

កាលនោះ ព្រះបទុមុត្តរសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់សម្តែងសរសើរនូវព្រះថេរៈនោះថាដូចជាបុត្ររបស់ព្រះអង្គ ហើយពណ៌នានូវគុណនៃព្រះថេរៈដោយព្រះគាថា ដូច្នេះថា:

ចាលេន្តិ និម្មលំ គត្តា ចាដិមោក្ខានិសំវរំ
សមាទិណ្ណធុតង្គញ្ច អបិច្ឆា មុនិសូនវោ ។

អធិប្បាយថា: បុត្រទាំងឡាយនៃព្រះពុទ្ធជាអ្នកប្រាជ្ញ ជាបុគ្គលមិនមានសេចក្តីប្រាថ្នា បានធ្វើនូវកិរិយាសង្រួមតាមសីលទាំងបួន មានបាដិមោក្ខសំវរសីលជាដើមផង នូវកិរិយាសមាទានធុតង្គគុណផង ហើយរក្សាពុំឲ្យមានសេចក្តីសៅហ្មងឡើយ ។

និច្ចមន្តកយុត្តម្ហិ ឧទ្ធយោជាត៖ ឧបដ្ឋិតា
បុញ្ញានំ វត្ថុតាវេ ទេវមានុស្សការីនំ ។

អធិប្បាយថា: សាវកជាពុទ្ធបុត្រទាំងឡាយ ជាវត្ថុសម្រាប់បណ្តុះ

បុណ្យ ចំពោះទេវជនទាំងឡាយមានទេវតានិងមនុស្សជាដើម លោកប្រព្រឹត្តទៅដោយដំរិះល្អ បីដូចជាយោធាទ្រទ្រង់នូវគ្រឿងអាវុធដោយប្រពៃ គ្រេចទៅក្នុងស្នាមចម្បាំងគឺមរណភ័យអស់កាលជានិច្ច ។

ធារេ មហំ វណ្ណវន្តំ សិវេយ្យំ ច ចីវរំ
ពុទ្ធបុត្តា មហានាគា ធារេន្តិ ន តថាវិធំ ។

ម្យ៉ាងទៀត បុគ្គលទ្រទ្រង់នូវសំពត់មានថ្លៃច្រើន មានពណ៌ល្អផ្សេងៗ ដែលគេបូជាហើយ ជាសំពត់កើតក្នុងដែនឈ្មោះសិវីយ៉ាងណា មហានាគជាពុទ្ធបុត្រទាំងឡាយ មិនទ្រទ្រង់នូវចីវរមានពណ៌ល្អយ៉ាងនោះទេ ។

ធារេន្តិ តេ បំសុកូលំ សង្ឃាដេត្វា បិលោតិកេ
វណ្ណជាតជិគុច្ឆម្ហា ឥទ្ធាលោកំ វិវជ្ជិតា ។

អធិប្បាយថា ព្រះមហានាគជាពុទ្ធបុត្រទាំងឡាយនោះ តែងវៀរបង់នូវសេចក្តីឥច្ឆាទីងលោកៈ ដើរស្វែងរក ប្រមូលមកនូវកំណាត់សំពត់ទាំងឡាយ អំពីកំណាត់សំពត់សំពប់រុំដំបៅជាដើម ហើយស្ទៀកដណ្តប់ឲ្យជាសំពត់បង្សុកូលជាប្រក្រតី ។

សាធិយាមិ សទា ហម្ភោ ឧបាសក និមន្តំ
នេវ សាទេន្តិ សម្ពុទ្ធ- បុត្តា ឧបាសក យាចនំ ។

ម្នាលឧបាសកដ៏ចំរើន ! តថាគតតែងត្រេកអរនូវការដែលគេនិមន្ត

គ្រប់កាលទាំងពួង; ម្នាលចុន្ទ ! មហានាគទាំងឡាយជាបុត្រនៃព្រះសម្ពុទ្ធ ពុំបានត្រេកអរនូវកិរិយាដែលគេនិមន្តឆាន់ឡើយ ។

មួយវិញទៀត វត្ថុណាសៅហ្មងក្តី ចុតមថៃថាក្តី ដែលអ្នកបួសត្រូវបាន ដោយទានដែលជនឲ្យតាមសទ្ធា បុត្រទាំងឡាយនៃតថាគត តែងវៀរលែងសេចក្តីបង្អៀតបង្អល់ គឺចំណង់ក្នុងសេដ្ឋប្រពៃ ត្រេកអរចំពោះតែទានដែលជនឲ្យដោយសទ្ធានោះឯង ។ តថាគតតែងផ្តល់ទីដំណេកល្អ គឺបុគ្គលក្រាលដោយកម្រាលដ៏ប្រពៃ ឯបុត្រទាំងឡាយនៃតថាគតតែងភ័យខ្លាចសំសារវដ្ត មិនបានសំរេចទីដំណេកយ៉ាងនោះឡើយ គ្រាន់តែសំរេចតិរិយាបថអង្គុយទីងដើរតែប៉ុណ្ណោះ ។ តថាគតតែងនៅក្នុងប្រាសាទដ៏ប្រឡាំងដោយជនច្រើនខ្ទះ ឯពុទ្ធបុត្រទាំងឡាយនៃតថាគត ពុំបានចូលទៅកាន់ប្រាសាទដែលមានដំបូលប្រក់បិទបាំង ដូច្នោះឡើយ ។ ពុទ្ធបុត្រទាំងឡាយនោះ តែងត្រេកអរតែក្រោមដើមឈើ ក្នុងព្រៃស្មសាន ក្នុងទីវាលល្ហល្ហៅជាប្រក្រតី ដែលពុទ្ធបុត្រទាំងឡាយចូលទៅកាន់ព្រៃនោះមិនប្រយោជន៍អ្វីទេ គឺប្រយោជន៍តែនឹងបំរើនព្រះធម៌ឲ្យជាហេតុផលដ៏ចុតមចំពោះអ្នកទាំងឡាយដោយអំណាចការនោះនោះឯង ។ តថាគតតែងចូលទៅកាន់ស្រុកញ៉ាំងប្រជុំជនឲ្យបានដល់នូវ ព្រះនិព្វានជាធម៌ទៀងទាត់ ឯបុត្រទាំងឡាយរបស់តថាគតនោះពុំបានចូលទៅក្នុងស្រុកឡើយ គ្រាន់តែត្រេកអរក្នុងទីសេនាសនៈដ៏ស្ងាត់ជាប្រក្រតីតែប៉ុណ្ណោះ ។ ឯភិក្ខុនេះ

មានកិត្តិគុណប្រាកដក្នុងសាសនាតថាគត ថាជាអ្នកទ្រទ្រង់នូវធុតង្គដ៏ប្រសើរផង ថាជាអ្នកជាប់ដំពាក់នៃគុណធុតង្គពុំដាច់ផង គិកុនេះឯងមាននាមថាវសកត្ថេរ ជាសប្បុរសវិសេសឯកជាងពុទ្ធបុត្រនានាដោយពិត ។

ព្រះបទុមុត្តរសម្មាសម្ពុទ្ធជាម្ចាស់ លុះទ្រង់សំដែងយ៉ាងនេះហើយ ក៏លើកឡើងនូវព្រះហស្តខាងស្តាំប្រកាសគុណរបស់ព្រះវសកត្ថេរ ដូចជាបុគ្គលចង្អុលបង្ហាញនូវមណ្ឌលព្រះចន្ទឲ្យឃើញប្រាកដក្នុងកាលនោះ ។

ឯកុលបុត្តក៏នោះ កាលបើបានស្តាប់នូវគុណកថានៃព្រះវសកត្ថេរហើយ ក៏មានសេចក្តីប្រាថ្នាចង់បានទីសាវកនោះចំពោះខ្លួន ទើបតាំងប្រាថ្នាថាបើដូច្នេះ ខ្ញុំសូមប្រាថ្នាទៅអនាគតសូមឲ្យបានជាសាវកដ៏ប្រសើរជាងសាវកទាំងឡាយ ដែលជាអ្នកទ្រទ្រង់នូវធុតង្គ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធអង្គឯណាមួយជាខាងក្រោយដោយពិត ។ លុះតាំងប្រាថ្នាក្នុងចិត្តយ៉ាងនេះហើយ ក៏ចូលទៅក្រាបទៀបបាទមូល នៃព្រះដ៏មានព្រះភាគក្នុងខណៈនោះឯង ។

សម្តេចព្រះសាស្តា ទ្រង់រំពឹងពិចារណានូវអនាគតសញ្ញាណ ក៏បានជ្រាបច្បាស់នូវហេតុនោះហើយ ទ្រង់ព្យាករ (ទាយ) ថា ទីនមានព្រះសាស្តាបរនាមព្រះគោតមត្រាស់ដឹងឡើងប្រាកដ ក្នុងទីបំផុតមួយសែនកប្បរាប់អំពីកប្បនេះ រូបអ្នកនឹងបានជាសាវកដ៏ប្រសើរលើសសាវកទាំងឡាយ អ្នកទ្រទ្រង់នូវធុតង្គ មាននាមប្រាកដថាមហាកស្សបត្ថេរក្នុង.

កាលនោះឯង ៗ

ឯកុដុម្ពិកក៏មានចិត្តសោមនស្សជ្រះថ្លា ចាប់ដើមតាំងតែពីបានពុទ្ធព្យាករណ៍នោះមកហើយតែងបំពេញនូវបុញ្ញកម្មជាបដល់អស់ជីវិត លុះច្យុតចាកអត្តភាពនោះ ក៏បានឡើងទៅសោយសម្បត្តិទិព្វដ៏មានសិរីសួស្តីក្នុងស្ថានទេវលោកនាយ អស់កាលជាអង្វែងយូរពន់ពេក ដល់មកក្នុងសាសនកាលនៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមវិបស្សី ក៏បានមកកើតជាព្រាហ្មណ៍មាននាមឯកសាដក បានបរិច្ចាគទ្រព្យបំណាយធ្វើទានយ៉ាងធំក្នុងសាសនាព្រះពុទ្ធវិបស្សីនោះឯង ៗ គ្រាន់តែអន្ទោលទៅមកក្នុងស្ថានមនុស្សនិងទេវតាសោយសុខក្សេមក្សាន្ត ពុំដែលធ្លាក់ទៅក្នុងអបាយដល់ម្តងឡើយ ៗ កាលព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប ទ្រង់បានត្រាស់ជាសព្វញ្ញុតញ្ញាណ ហើយចូលព្រះបរមនិព្វានទៅនោះ ឯកសាដកព្រាហ្មណ៍ក៏បានមកជាសេដ្ឋីក្នុងនគរពារាណសី បានបូជានូវព្រះសរីរៈធាតុនៃព្រះសម្មាសម្ពុទ្ធអង្គនោះ ~ លុះច្យុតចាកអត្តភាពនោះហើយតែងអន្ទោលទៅក្នុងសង្សារវដ្ត អស់កាលជាអង្វែង ទើបបានត្រឡប់មកកើតជាកុដុម្ពិកម្នាក់ក្នុងនគរពារាណសីទៀត មានទ្រព្យសម្បត្តិច្រើនស្តុកស្តម្ភមាំមួន ដល់សម័យមួយជាខាងក្រោយកុដុម្ពិកនោះឯង បានត្រេចទៅក្នុងព្រៃ ក៏បានឃើញព្រះបច្ចេកពុទ្ធមួយព្រះអង្គ មាននាមពុំប្រាកដ ស្ថិតនៅក្នុងដងព្រៃមួយ ទៀបស្រុកជនបទជាទីបំផុតនៃដែន ៗ (នៅមានត)

# មហោសថជាតក

(តមក)

លោក អ៊ឹម.គុន ចម្លងពីសាស្ត្រស្លឹករឹត

ព្រះពុទ្ធវង្ស គឹម-ទូរ ពិនិត្យ

---

ឰដ៏កាលនោះព្រះមហាសត្វអ្នករមិលមើលទៅសិរីវឌ្ឍកសេដ្ឋីជាព្រះបិតា , ឯសិរីវឌ្ឍកសេដ្ឋីនោះក៏ដោះក្ដោះឡើងចេញអំពីអាសនាអង្គុយនោះ ហើយសំគាល់ព្រះមហាសត្វដែលអង្គុយមើលនោះហើយថា ម្នាលចៅមហោសថ ចូរចៅមកអង្គុយឰដ៏អាសនានេះ, រីព្រះមហាសត្វនោះមកអង្គុយឰដ៏អាសនាដែលអាពុកអង្គុយនោះហោង ។

រីអាចារ្យទាំង ៤ មានអាចារ្យសេនក បុក្កុស កាមិន្ទ ទេវិន្ទជាដើម នូវអ្នកអនុពាលផងដទៃ យល់ព្រះមហាសត្វអ្នកឲ្យអាពុកដោះឡើងហើយ ក៏អង្គុយឰដ៏អាសនាដែលអាពុកនោះវិញទៀតហោង ។ រីអាចារ្យទាំង ៤ យល់ពោធិសត្វឲ្យអាពុកដោះឡើងដូច្នោះហើយ ក៏ស៊ីនទះដៃហើយសើចដៀវព្រមគ្នា ហើយអ្នកទាំងអម្បាលនោះស្រដីគ្នះតិះដៀលថា អ្នកកំឡៅដូច្នេះមកថាជាអ្នកប្រាជ្ញ អ្នកឯណាក៏ឲ្យអាពុកដោះឡើងអំពីអាសនាហើយក៏យកខ្លួនឯងមកអង្គុយដែលអាពុកវិញ ហើយអ្នកប្រាជ្ញនោះមិនសមគួរហៅថាអ្នកប្រាជ្ញឡើយ ។

ស្តេចស្តាប់គស់អ្នកផងទាំងតិះដៀលចៅអ្នកប្រាជ្ញនោះហើយ ស្តេចមានព្រះភ័ក្ត្រនោះឡើងក្រហមទុំអាក្រក់ ពុំស្រណុកក្នុងព្រះរាជហឫទ័យឡើយ ។ ឮដំណាលនោះ, ព្រះមហាសត្វអ្នកទូលដណ្តឹងស្តេចថា បពិត្រព្រះសម្មតិទេពមហារាជក្សត្រថ្លៃប្រសើរអើយ, ស្តេចមានព្រះភ័ក្ត្រអាក្រក់ពុំស្រណុកក្នុងព្រះហឫទ័យឬអម្ចាស់ ? ទើបស្តេចថា អើ ចៅអ្នកប្រាជ្ញអើយ, អញមិនស្រណុកចិត្តហោង ។ ព្រះមហាសត្វអ្នកទូលថា ព្រះបាទអម្ចាស់គ្រាន់តែឮអំពីដើមថា ខ្ញុំមិញគឺគាប់ព្រះរាជហឫទ័យ, ឥឡូវនេះ លុះអម្ចាស់បានយល់អញខ្ញុំហើយ គឺកើតខ្វះជាពុំគាប់ព្រះរាជហឫទ័យវិញតើហេតុអ្វីអម្ចាស់ ? ទើបស្តេចបន្ទូលថា អញយល់បានឡើងអាពុកដោះឡើងអំពីកាសនាហើយ យកខ្ទង់ឯងមកអង្គុយដែលវិញ គួរឲ្យអស់សំណើចដល់អ្នកផងទាំងឡាយ ហេតុនោះហោង អញមានចិត្តពុំស្រណុកឡើយ, ហេតុអ្វីក៏បាមកធ្វើអំពើដូច្នេះហឹង, ព្រះមហាសត្វអ្នកទូលថា បពិត្រមហារាជអើយ, អម្ចាស់គ្មានថាជះហានអាពុកសឹងឧត្តមប្រសើរក្រៃលែងសព្វហានទាំងពួង ឬ អម្ចាស់ ? ។ ស្តេចថា អើចៅអ្នកប្រាជ្ញអើយ អញយល់ថាដូច្នេះហោង ។ ព្រះមហាសត្វទូលថា មហារាជ បពិត្រមហារាជអើយ, មួយទៀតសោតថា ព្រះបាទអម្ចាស់នូវអ្នកប្រាជ្ញទាំងឡាយ បានផ្តាំទៅកាន់អញខ្ញុំដូច្នោះថា រីសិរីវឌ្ឍកសេដ្ឋី

នូវទៅមហោសថ ឲ្យជូនសេះអស្សតរ នូវសេះសេដ្ឋតរមកកាន់យើងទ្រ, ថាមែនដូច្នេះឬមហារាជ ។ ព្រះមហាសត្វអ្នកថា អម្បាលនោះហើយ ក៏ប្រែព្រះនេត្រទៀងមើលទៅគំលោះនាក់កាន់លានោះ រំអ្នកកាន់លានោះ ដឹងហេតុនោះហើយម្ចាស់យកលានោះមកឲ្យ ទើបពោធិសត្វអ្នកឲ្យចាប់លានោះទៅផ្តេកទៀបព្រះបាទនៃស្តេចស្រេច ទើបព្រះមហាសត្វអ្នកទូលថ្វាយលានោះរួចហើយ អ្នកទូលដណ្តឹងថា បពិត្រអម្ចាស់អើយ, មួយនិសោតរំដៃថ្លៃថ្លៃនៃលានេះ តើប៉ុន្មានអម្ចាស់ ? ។ ស្តេចបន្ទូលថា ម្នាលទៅអ្នកប្រាជ្ញអើយ រំដៃថ្លៃលានេះតិចទេ ថាបើវាខ្ទាំងមានគុណនោះ រំដៃថ្លៃវានេះអស់តែ ៧ ដំឡឹងទេហោង ។ ព្រះមហាសត្វអ្នកទូលវិញថា បពិត្រមហារាជអើយ ថាបើសេះអស្សតរ មកអាស្រ័យនឹងលានេះ ក៏កើតគភ៌ផ្ទៃមកជាមេយ្យនាមានកំឡាំងច្រើននោះ តើនាថ្លៃអស្សតរប៉ុន្មានសោត ។ ស្តេចត្រាស់ថា ម្នាលទៅអ្នកប្រាជ្ញអើយ, ថាបើដូច្នោះនឹងកាត់ថ្លៃពុំបានឡើយ ។ ព្រះមហាសត្វអ្នកទូលវិញថា បពិត្រមហារាជអើយ, អ្វីអម្ចាស់បន្ទូលថាដូច្នោះសោត ។ ព្រះបន្ទូលថា នាអាពុកក៏ប្រសើរលើសក្រៃលែងកូនសព្វបាននាំងពួងមិញ មុខជាអម្ចាស់មិនបន្ទូលឯងឬអម្ចាស់ ? ។ ស្តេចថា ទៅអ្នកប្រាជ្ញអើយ អញថាដូច្នោះហោង ។ ព្រះមហាសត្វអ្នកថា បពិត្រមហារាជអើយ ថាបើ

អម្ចាស់បន្ទូលថាដូច្នោះពិត , ក៏លានេះឧត្តមក្រៃលែងនឹងសេះអស្សតរវិញ នោះក៏ចូរអម្ចាស់យកឯអាពុក ថាបើអម្ចាស់បន្ទូលថា សេដ្ឋតរប្រសើរថ្លៃក្រៃទឹងណាវិញ , ក៏អម្ចាស់យកឯខ្ញុំហោង ។ បពិត្រមហារាជអើយ រីអ្នកប្រាជ្ញអម្ចាស់នេះ អម្ចាស់ឲ្យយកអំពីឯណាមកចិញ្ចឹមឲ្យជាអ្នកប្រាជ្ញ យល់ហាក់មានប្រាជ្ញាបេះស្រដី ឧបមាបីដូចឆ្មាខ្វាក់ពញាក់ពញើលលើដូច្នេះ ទេគួរ ទឹងកេដោះប្រស្នាតែតម្រិះខ្លួនឯងក៏ពុំបានផងសោត ម្ដេចឡើយក៏ ហ៊ានសើចទះដៃដៀលអញបាន , ថាឲ្យអ្នកប្រាជ្ញអម្ចាស់ប្រកបនូវប្រាជ្ញា ដូច្នោះទេគួរ អម្ចាស់ចិញ្ចឹមឲ្យហៅថាអ្នកប្រាជ្ញរាបធំ ឈ្មោះអ្នកប្រាជ្ញគេទេ អម្ចាស់ ។ ព្រះមហាសត្វអ្នកដៀលអ្នកប្រាជ្ញទាំង ៤ នោះហើយ មក សូត្រជាបទគាថានេះមានព្យដ៏ក្នុងគម្ពីរឯកនិបាត ។

ហសិ តុវំ ឯវំ មញ្ញសិ សេយ្យោ បុត្តេន បិតាតិ
រាជ សេដ្ឋ ហន្ទស្សតរស្ស តេ អយំ អស្សតរស្ស
ហិ គទ្រភោ បិតាតិ ។

បពិត្រមហារាជប្រសើរក្រៃលែងរាស្ត្រផងទាំងឡាយអើយ សម អម្ចាស់គ្មានសន្និដ្ឋានស្មានជាអាពុកប្រសើរថ្លៃ ក្រៃលែងកូនសព្វហានទាំង ពួងឬអម្ចាស់ គ្មានអនុគ្រោះក្នុងព្រះហឫទ័យដូច្នេះថា បើដូច្នោះសមជាលា ប្រសើរថ្លៃក្រៃទឹងសេះអស្សតរហោង, វីលានេះ ប៉ុនគ្មានទឹងអាពុក

អស្សតរ ឬ ទីងប្រសើរថ្លៃក្រទីងសេះអស្សតរមិនបានឡើយ ។

ព្រះមហាសត្វអ្នកជាអម្បាលនោះហើយ អ្នកទូលវិញថា បពិត្រមហារាជ ជាបើអាពុកប្រសើរថ្លៃក្រលែងកូននោះ ក៏ព្រះអង្គយកអ្នកអាពុកវិញ , ជាបើកូនប្រសើរថ្លៃក្រលែងទីងអាពុក ក៏អម្ចាស់យកឯអញខ្ញុំហោង អញខ្ញុំបំរើព្រះបាទអ្នកជាអម្ចាស់ហោង ។

រីព្រះបាទវិទេហរាជ ស្តេចស្តាប់ចម្លើយពោធិសត្វដោះសារសាបប្រស្នានោះហើយ មានព្រះរាជហឫទ័យដ៏លុះទូវសោមនស្សសោទរក្រៃពេករីករាយបុរសទាំងឡាយនោះ ឲ្យសាធុការព្រះមហាសត្វជាពាន់ដង ដ៏មានសព្ទសម្រែកជាដើមថា ប្រស្នានេះ ហៅអ្នកប្រាជ្ញឆ្លើយពីរោះ ។ ប្រពៃក្រៃពេកហោង សឹងដ៏ទះដៃរកាយកន្សែងវែងមាលា ។ រីអ្នកប្រាជ្ញទាំង ៤ នោះមិញ ដ៏មានមុខនោះអាក្រក់ទុនស្មៀមស្ងប់សោកទៅ ។

រីពាក្យបំណោទចោទថាដូច្នេះ នាបីហៅអ្នកផងទាំងឡាយក៏ទីងដឹងគុណម្តាយ-អាពុក ទីងលើសក្រៃទីងស្មេពោធិសត្វនោះឥតអង្គមានឡើយ; ហេតុអ្វីព្រះមហាសត្វក៏ធ្វើដូច្នេះ ? រីពាក្យចម្លើយថាដូច្នេះ ឯប្រយោជន៍អ្នកទីងមើលងាយអ្នកជាអាពុកឥតអង្គមានឡើយ ។ បចកែស្តេចប្រើឲ្យអ្នកស្រុកឯកើតជូនសេះអស្សតរមកហោង ។ ក៏ព្រះមហាសត្វអ្នកធ្វើដូច្នេះ ធ្វើប្រយោជន៍ទីងឲ្យច្បាស់នៃប្រស្នានោះឯង, មួយទៀត

ប្រយោជន៍នឹងសំដែងប្រាជ្ញាអាត្មា , មួយទៀត ប្រយោជន៍ធ្វើឲ្យអាស្រូវ ភាសនៃអ្នកប្រាជ្ញទាំង ៤ នោះឯង ។ គន្ទកបញ្ហា ជិដ្ឋគោ ។ វិធីស្រដីអាចប្រស្នាពីការល្បែងលាមិញ កំស្រេចនូវប្រការអម្បាលនេះឯង ហោង ។

រាជា តុសិត្វា ។ ល ។ ព្រះបាទវិទេហរាជ ស្តេចមាន ព្រះរាជហឫទ័យត្រេកអរ ហើយស្តេចយកកុណ្ឌីមាសដំពេញនូវទឹកអប់ ត្រឡប់នូវគន្ធពាជោរប្រសើរស្រេច ស្តេចប្រូចលើដៃមហាសិរិវឌ្ឍកសេដ្ឋី ហើយស្តេចមានព្រះបន្ទូលមធុរពីរោះថា ម្នាលសេដ្ឋី ចូរព្រះស្តេចបរិភោគ ស្រុកបាច័នយវមជ្ឈគ្រាម ចូរធ្វើអំពើនូវសម្បត្តិក្រមក្រឹត្យជាស្តេចហោង ។ ហើយស្តេចបន្ទូលទីងមហាសេដ្ឋីសំណល់លែងនោះថា ម្នាលសេដ្ឋី ទាំងឡាយអើយ ចូរព្រះស្តេងឡើងចុះគាល់ហៅទៅបំរើសិរិវឌ្ឍកសេដ្ឋីដូច អ្នកផងបំរើអញហោង ។ ស្តេចថាអម្បាលនោះហើយ ស្តេចឲ្យណ្តាប់នូវ គ្រឿងជាគ្នាទ់ប្រដាប់ទាំងពួង ឲ្យជូនទៅព្រះមាតាពោធិសត្វនោះហោង ។

ព្រះបាទវិទេហរាជ ស្តេចមានព្រះហឫទ័យជ្រះថ្លា ទ្រង់ព្រះអំណរ អរទឹងអាចប្រស្នានោះហើយ ស្តេចទីងយកពោធិសត្វជាកូន ស្តេចបន្ទូល ថា ម្នាលសេដ្ឋី ចូរព្រះស្តេងឲ្យមហោសថបណ្ឌិតជាកូនសំឡាញមក អញហោង ។

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

# រឿងមរណមាតា

(តមក)

លោក ប៊ុ-ស៊ុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត

ស្ដេចពេញមេត្រី អាយិអគ្គមហេសី វេងវងស្នេហា ទត ហើយមហាក្សត្រ សួរថ្នាក់ទៅថា វៃហនាងធីតា កាលចាកបុរី ៗ ជាសត្វសារិកា ហើរហើយយាត្រា លំបាកក្រក្រី ឬមួយយ៉ាងណា ម្ដេចមាតាត្រី ចូរប្រាប់សេចក្ដី ឲ្យដឹងថ្លៃថ្លា ៗ នាងស្ដាប់ស្វាមី សួរសព្វសេចក្ដី ទុក្ខសុខអាត្មា នាងទូលរៀបរាប់ ដំណើរកិច្ចការ ដូចបាន ពណ៌នា អំពីមុនស្រាប់ ៗ ស្ដេចស្ដាប់មហេសី ទូលសព្វសេចក្ដី ទុក្ខសោករៀបរាប់ ពីនាងលំបាក តោកយ៉ាកអង្គអាប់ អង្គឲ្យអភ័ព្វ ព្រាត់ព្រះបេស្ដា ៗ ស្ដេចមានព្រះទ័យ អាសូរនាងក្រៃ សង្វេគ អនិច្ចា អាក់អួលអាណិត ផ្ដិតផ្ដិតទុក ព្រះហស្ដប្រាប់ ឱបអង្គមហេ-សី ៗ ទ្រង់ព្រះសោកា ទោរទន់កាយា ព្រះបាទចក្រី ញាប់ញ័រ ចំប្រប់ សន្ធប់ស្មារតី ព្រះស្នំសាវស្រី សឹងយំគ្រប់គ្នា ៗ បន្ទោសោក ស្រេច នោះទើបសម្ដេច បរមរាជា ឲ្យរៀបរាជយាន សូរិកានសោភា

ទាហានយោធា ចតុរង្គទាំងឡាយ ៗ ស្ដេចយាងចូលទៅ អាស្រម លំនៅ ក្សត្រីឆោមឆាយ លុះដល់ក្សត្រក្សាន្ត ចុះយានសិវិកាយ យាង ចូលទៅថ្វាយ បង្គំឥសី ៗ រៀបភ័ស្ដុនានា ទៀនធូបភ្ញីផ្កា សារៈ តើចំណី ដំកល់ភាជន៍មាស ធូរុះផ្កាបរស្មើ មហាក្សត្រទាំង៣ ចូល ថ្វាយនមស្ការ ៗ ផ្កាមាសផ្កាប្រាក់ ផ្កាកែវត្នៅត្នាក់ លើកថ្វាយ ព្រះមហា ឥសីរួចស្រេច ទើបស្ដេចសួរសារ សព្វគ្រប់ប្រការ ទុក្ខ សោកអ្វី ៗ ៗ ឥសីថ្វាយពរ សាសង់ទៅមក ស្មានស្មោះ មេត្រី ស្រេចហើយក្សត្រា ទូលមហាឥសី ថាសូមក្សត្រី មរណមាតា ៗ ទឹងរៀបអភិ- សេកសូមឡើងទី ជាអគ្គមហា មហេសី ឧត្ដម សូមសុំមេត្តា ឥសីសីលា បើកតាមព្រះទ័យ ៗ ស្រេចក្សត្រទាំងបី លាព្រះឥសី យាងយាសវិលវៃ មកអាស្រមនាង ជិតខាងជលសៃ កុមារ បុត្រថ្លៃ គង់គាល់បិតា ៗ ទើបក្សត្រនរនាថ ត្រាស់ប្រើអមាត្យ ឲ្យតែង របនា ពេងរ័ត្នលលង់ សង់ព្រះពន្លា រួចស្រេចក្សត្រា ឡើងគង់សុខ សាន្ត ៗ លុះបានពេលា ជោគជ័យជតា ល្អល្អះបើកបាន ស្ដេច ប្រើខុនណាង ស្អាងនាងកល្យាណ ហៃយាងទៅបាន ពេងរ័ត្នរបនា ៗ គង់លើផ្ទករ័ត្ន ព្រាហ្មណ៍ព្រឹទ្ធសារសេត្ស សារសូត្រសាត្រា ស្ដុតី មង្គល សកលជយា ព្រឹកព្រាងសុរិយា បង្វិលពពិល ៗ ប្រគំ ដន្ត្រី ត្រែស័ង្ខភេរី គ្រឹងផ្កាមាទិល មានប្រៀងថ្វាយពរ កំដរពពិល

ដំរេះមន្ទិល ចង្រៃទាំងឡាយ ៗ ទើបយកពពិល មាសមកបង្វិល
មង្គលគបកាយ ហើយរៀបភ្ជា បុប្ផារត្នថ្វាយ ទេព្តាទាំងឡាយ
បិតសព្វបព្វតា ៗ និមន្តឥសី សារសូត្រស្តុតី ឲ្យពរព្រះមហា
មហេសីឧត្តម ឲ្យសមសក្តា ឥសីសីលា សូត្រថ្វាយពរ ៗ
អាយុវណ្ណំ សុខំពលំ ជយជយោ ជយតុភវំ វឌ្ឍសេដ្ឋោ
សុខត្តិយោ មហារាជា ៗ ឥសីសូត្របច់ ស្តុតីសារសព្វ ទើបព្រាហ្មណ៍
ព្រឹទ្ធា សូត្រថ្វាយតាមក្រោយ បណ្តាយពល់គ្នា គរីយោភា ថ្វាយពរ
អឹងកង ៗ ខុនណាងចាស់ទុំ អករយាយស្និទ្ធស្នំ ថ្វាយពរព្រមផង
ប្រគំជន្ត្រី ភេរីពង ត្រែស័ង្ខផ្លុំផង ហែស្រង់គង្គា ៗ ហើយថ្វាយ
ព្រះនាម ក្សត្រីទៀតតាម នាមដើមនោះណា សម្តេចមហេសី សិរី
សេដ្ឋា មរណមាតា បរមបពិត្រ ៗ អភិសេកក្សត្រី គំរប់ថ្ងៃបី
អស់ទាំងស្នំស្និទ្ធ សឹងសុខក្សេមក្សាន្ត ពុំមានភ័យកិត ទើបស្តេចគន់
គិត លាព្រះឥសី ៗ លុះបានពេលា ឫក្សជ័យជោគជា ទើបព្រះបក្រី
ឲ្យរៀបរាជយាន សូរ្យកាន្តរង្សី ជុំពលសេនីយ យាងចូលនគរ ៗ
ទើបក្សត្រទាំងពីរ ឡើងលាឥសី ទឹងវិលចេញចរ ឥសីសីលសាយ
សោកថ្វាយព្រះពរ ថាបើស្តេចចរ ស្តេចចេញយាត្រា ៗ ឲ្យមានតេជះ
ជោគជ័យជំនះ សត្រូវនានា ឲ្យមូលមហេសី ក្សត្រក្សត្រា ឲ្យគ្រងរដ្ឋា
ក្សេមក្សាន្តព្រស្តផង ៗ ទើបក្សត្របីអង្គ ទទួលពរម- ង្គលគាប់កន្ទង

ក្រាបលាឥសី មុនីឥតហ្មង ឯក្សត្រីច្បង នូវរាជបុត្រា ។ អ្នកទឹកស្រណោះ អាល័យអាឡោះ ឥសីសីលា ធ្លាប់នៅសាន្តសុខ ឥតទុក្ខចិន្តា ឥសីមេត្តា តែសព្វថ្ងៃ ។ ឥឡូវយាត្រា ចាកចោលព្រះមហា ឥសីសីលថ្ងៃ ទុសមអ្នកស្ងាត់ យើងខ្វាត់ឃ្លាតឃ្លៃ មានតែសត្វព្រៃ កំដរជាគ្នា ។ ទុកអាស្រមយើង ធ្លាប់នៅចុះឡើង សុខសព្វវេលា ឥឡូវយើងទៅ ចោលនៅសាធារណ៍ ស្ងួនស្ងាត់មហិមា រលីងធេងទេ ។ នាងទឹកឥសី ទឹកដល់កុដី ធ្លាប់នៅធ្លាប់ថៃ នេត្រនាងហូរខ្លាយ សព្វសាយកាយេ ទុក្ខធ្ងន់សែនវេទ្ធ ផ្អែតផ្អិតទុក ។ ឥសីបានយល់ ក្សត្រីទុក្ខល់ លួងលោមទៅថា សូមស្តេចក្សេមក្សាន្ត សំរាន្តចិន្តា កុំគិតអាត្មា នាំឱ្យរីករ ។ ឥសីលួងថ្វាត់ ទើបតាំងបីក្សត្រ ក្រាបលាចេញចរ ចេញចាកឥសី មុនីបវរ ពួកពលនិករ ប្រៀបប្រុងអាត្មា ។ ឯក្សត្របីអង្គ ស្តេចយាងឡើងគង់ ទីនាំងរថា ព្រះបទុមវង្ស ស្តេចគង់អស្សពាហនៈ អភិរមា បើកបាំងថ្វាយក្សត្រ ។ ព្រះបាទវិមល គង់យានមង្គល គជេន្ទ្រសារសត្វ មូលនីងមហេសី ក្សត្រីរូបរត្ន គង់ខែបមហាក្សត្រ ចេញចរយាត្រា ។ ប្រុកដន្ត្រី ត្រែស័ង្ខខ្លុយប៉ី សំភោររមនា ភ្លេងខែកពីងពាង មានទាំងស្គរជ្វា គាំងហោបីគ្រា កក្រើកព្រឹក្សព្រៃ ។ ព្រះបទុមវង្ស ស្តេចទ្រង់ប្រើអង្គ ប្រើសមាសវិលៃ ទៅ

រកសេនា អាត្មាពេញព្រៃ ប្រើសមាសអក្រៃ លាស្តេចយាត្រា ។ ព្រះបទុមវង្ស កុមារនេត្រង្គ រឹងឫទ្ធិក្លៀវក្លា ចេញជាទ័ពស្រួច ត្រដួច យាត្រា ពួកពលសេនា ប្រាំពីរកោខា-ៗ គិទប័មាន ហៃមុខក្សត្រ ក្សាន្ត សប្បាយនោឡា ព្រះអង្គប្រពាត រុក្ខជាតិវនា វនេបព្វតា ព្រៃភ្នំហិមពាន្ត ។ ព្រះបាទវិមល ធម្មាជជើងថ្កល់ ស្តេចលើកទាហាន ប្រពាតសប្បាយ ក្អាកក្អាយក្សេមក្សាន្ត បង្ហាញហិមពាន្ត មហេសី ធីតា ។ ព្រះបទុមវង្ស យល់បិតាទ្រង់ ក្រសាលព្រឹក្សា អ្នកយាង ចូលជិត នៃបទិត្យបិតា រៀបពប់ព្រឹក្សា ថ្វាយក្សត្រពណ្ណរាយ ។ ផ្លូវនេមង្សត ក្របក្រាយស្វាយល្មុត ដកពដកពោយ ដើមជុះទាបស្រាប់ ល្អកទាប់បេះឆាយ ផ្លែទុំជ្រុះពាយ ដោយដីគ្រៀបគ្រា ។ ពួកពលទាំង ឡាយ បេះស៊ីគេស្លាយ ពាសពេញព្រឹក្សា មាក់ប៉ែនចេកចាន់ សិរមាន់សែជា មៀនទៀបទ្រៀលស្វា សន្តាន់សន្ទៃ ។ ផ្លែប្រាលទៃងទុំ ផ្អែមដូចទឹកឃ្មុំ ជុះជាសពាសព្រៃ មើលយល់សឹងយប់ ជាម្លប់ត្រៃឈើ ផ្លែទាបលូកដៃ បេះបានគោក្តា ។ មាក់ប្រេងមាក់ប្រាង មាក់ដោក មាក់សាង ក្របក្រាយនានា ទ្រមូងក្រវាន់ តាប់តាន់គ្រៀបគ្រា ទន្ទាប់ ទន្ទា ទ្រមែងព្រីងទុំ ។ ពង្រីងពង្រៀង ដើមល្វាវៀង ផ្ជឹងផ្ជុំ បង្គាបង្គៅ សាវម៉ាវខ្នុរគួម ខ្ទិតខ្វាវស្រគំ រាំងពោតព្នាលព្នៅ ។

ត្រខុបក្រឡាញ់ អង្កោលអង្កាញ់ អំពិលអំពៅ ឥឡឹកឥឡោក មាក់ ជោគជុះទៅ ម្រំម្រោមម្រះព្រៅ ត្រឡែតត្រឡាត់ ។ ផ្លែល្អគ្រកាល ខ្លះទើបស្រគាល ខ្លះក្តិបច្រើនក្តាត់ ខ្លះទុំជោរជាំ សត្វពាំខ្វាយខ្វាត់ ជ្រុះដែលមាត់សត្វ ដោយដីពេញពាស ។ ស្វាយបេកស្វាយក្បាល-ដំរីទុំប្រាល ស្វាយម៉ឹងស្វាយមាស ស្វាយឥន្ទលាំ ជ្រុះខ្លាំពេញពាស ស្វាយក្រាមមាស ក្បាលសេះអង្រ្គង ។ ផ្លែឈើហិមពាន្ត ផ្លែផ្កាមិនមាន រដូវឡើយហោង ខ្លះផ្កាខ្លះផ្លែ ហូរហៃជាម្ដង ខ្លះទុំទាំងចងតាបល្ហុមបេះបាន ។ ដើមខ្ពស់មានមែក ពាក់ព័ន្ធញឹកញែក ជាថ្នាក់ជាស្ពាន ទីងទៀងកំពាយ សប្បាយឈរឈាន បង់ដើរកំបាន មិនភ័យខ្លាចធ្លាក់ ។ មែកវែងត្រសាយ យារយុរយោកធ្លាយ ត្រសុំត្រសាក់ ទីងឈប់បាត់ក្តៅ មានស្មៅត្រជាក់ ក្រោមដើមដូចម្នកលាតលាកន្ទេល ។ ស្មៅស្មើត្រឹមព្រេង បើចង់ដេកលេង លុះលក់វៀងវេល គ្មានមូសសុបស្មោះ ដេកចុះរំណាល ធូលីមិនដែលហូរជាប់មុខមាត់ ។ ឯខ្យល់មន្ទូរាច បោកបក់ឲ្យស្អាត ផ្អេះផ្អាបស្អុយបាត់ ហើយបក់ក្លិនផ្កា បុប្ផាផាយផាត់ ល្ហេងល្ហើយពេកក្តាត់សាយសព្វព្រឹក្សា ។ ស្រឡឹតស្រឡៀ ម្ញុះរួតខ្លួនស្រី ចំប៉ីចម្ប៉ា រំដួលរំដេញ ពាសពេញបព្វតា រំចេកយុថ្កា សារិយុគមហាហង់ ។ វែង

រីកស្គុសស្គាយ ផ្ទុំក្លិនកកាយ សាយសព្វអប់អង្គ ក្លិនក្លាយផ្សះផ្សាយ ដកបបាត់បង់ ស្បូវសព្វកន្ទង់ ផញ្ញក់គេសរ ៗ ដូចស្បូវសព្វក្ងួន ពីពេះ ល្វើយល្វើង ក្នុងព្រឹក្សាករ ពួកពលទាហាន ក្សេមក្សាន្តត្រេកអរ សោមនស្សស្មោះសរ ក្លួចបុត្រករិយា ៗ យានយាសសប្បាយ ផ្ទៃ ឈើទាំងឡាយ មានសេទុជា ស្ដេចសោយស្កប់ស្កល់ គ្រប់ផលព្រឹក្សា មហោសីធីកា សឹងសោយសប្បាយ ៗ ពួកពលសេនា ចតុរង្គអាសា ទាហានទាំងឡាយ ឃើញព្រៃហិមពាន្ត ក្សេមក្សាន្តសប្បាយ ឡើង លេងប្រញាយ ដោយព្រៃព្រឹក្សា ៗ ខ្លះទៅឡើងភ្នំ ឡើងឈើតូចធំ បូតបេះផលា ខ្លះចុះងូតទឹក ពន្ទឹករង៉ា លោតលេងបេះផ្កា ឈូកស រៀនកយ ៗ ផ្ទៃឈូកក្រឪ ឈូកឈោងដៃទៅ បេះបានដោយងាយ ក្នុងទឹកគ្មានឈ្មើង តាមដើងជាប់កាយ ហៃហាលលេងសប្បាយ ពាល់ ល្បាបឥតក្ស័ ៗ ក្រពើពេញពាស ខ្លាចមនុស្សម្នាណាស់ ពួនដោយ រូងដី មិនដូចក្រពើ ស្រុកយើងទៀត ព្រះហើនពេកក្រៃ ខាំមនុស្សស៊ី ហោង ៗ អាក្រហិមពាន្ត ឃើញមនុស្សពុំហ៊ាន ពាធាយើងផង គ្មានបាញ់ទឹកដី ប្រុសស្រីជាម្ដង ទឹងនោមដុះហោង មិនខុសអ្នកតា ៗ មិនព្រួយនឹងតម ទឹងកាន់គ្រណាម លេងសើចម្ដេចម្ដា មិនបេះខុសមាត់ ភ្លាំងភ្លាត់គ្រង់ណា តាមតែនឹងថា ម្ដេចៗក៏បាន ៗ ដើរលេងតាមចិត្ត

សប្បាយឥតគិត ត្រេកអរគ្រប់ប្រាណ ខ្លះរើសត្បូងពេជ្រ ដោយខ្សាច់

ក៏មាន ខ្លះកាប់ត្បូងបាន ដុះដោយទូរថ្ម ៗ ពួកពលទាំងឡាយ ដណ្តើម

ប្រញាយ សើចសាំនត្រេកអរ ខ្លះរើសបានច្រើន ក្រវែនចំរក់ ខ្លះ

គ្មានល្អបល ល្អបលេងជាល្បែង ៗ ខ្លះបានផ្កាថ្ម ខ្លះបានដីស ប្រក

ជាលវែកសែង សំបកខ្យងខ្ចៅ លៀសអាវគ្រំគ្រែង សម្បុរប្រាលវែង

ខ្លះខៀវខ្លះស ៗ ខ្លះលឿងខ្លះខ្មៅ ខ្លះដូចគេដៅ បញ្ចពណ៌

ស្រស់ល្អ ពួកពលទាំងឡាយ កើបកាយរើសយក ខ្លះយកកែវថ្ម

ក្រឡឹងជន្ទាប់ ៗ ដាក់ក្នុងដំរី រទេះសាលី ស្ងួតសាំនអឹងកាប់ ខ្លះឃើញ

ម្ទេស ជ្រែកដីដុះជាប់ ថ្នាំងញឹកហើយកាប់ ធ្វើខ្សែរដក់ថ្នាំ ៗ មាន

កោដធ៌សាលី ដុះជាសដោយដី ហាក់ដូចអ្នកដាំ គូវែងមួយហត្ថ ច្រើន

កាត់ជ្រុះខ្លាំ បើបង់ផ្ដាំ បាយបរិភោគ្គា ៗ ទៅបូតយកមក មិនព្រួយ

ប៉ុកប៉ក អុំស្ងួទៀយណា ផ្លែជាអង្ករ ស្អាតល្អជ្រះថ្លា សម្បុរដូចផ្កា ម្ទិះ

លាក្រពុំ ៗ បូតបានច្រើនក្រៃ ប្រកក្នុងឆ្នាំងវៃ ដាក់លើក្រានថ្ម

កើង ឆះរំពេច ពុះស្រេចជាត់ថ្មី ឆ្អិនដោះរៀបចំ បរិភោគសប្បាយ ៗ

មិនព្រួយកេត្តិ៍ គេម្ហូបអ្វីៗ ឡើងទៀយខ្ជាប់ខ្ជាយ បរិភោគទេទេ ទុជា

សេសាយ ឈ្ងុយឈ្ងប់លើសបាយ ស៊ីទងសំឡ ៗ ពលទាំង

ប្រាំពីរ– អាខោប្រឹងរីរ បូតបានល្អ ៗ ត្បាញជាលប្រកច្រើន

ក្រវើនទីនយក ទីនដឹកនាំមក ផ្ញើកូនប្រពន្ធ ។ ខ្វះស៊ុំមើមឈើ ផ្លែឈើសារពើ ឆ្អែតឆ្អន់លើសលន់ បាត់ឃ្លានបាយសោះ ស្រួលស្រស់ពេកពន់ កំលាំងលើសលន់ មាំមួនធំធាត់ ។ មានឈើគ្រឿងទេស ថ្នាំទិព្វវិសេស វិសាលច្រើនក្តាត់ ដូងតាន់ក្រស្នា កន្ទ្រាស្នែងសត្វ កំចាយកំចាត់ ក្លាំពាក់ក្លាំពា ។ កញ្ចាខដីប៉ូ ក្រវាញកាកី សម្បុរល្វែងល្វា កគោកកកោះ ទ្រៀលត្រស់ធ្នង់ធ្នា ពជត្ថិះទន្ទា កណ្តឹងជំរី ។ កុមារពេចពួច សង្ឃ្យរសេង្ឃ្យួច សន្សូរស្វែងស៊្វា លំពាកលំពោះ មោកមោះមេត្រី ស្នាច់ស្នាក្របី ក្រពៅពកមាស ។ ម្រេចម្រំអង្គ្រង សំពេនក្លូក្លង រាំងពេកពជដាស កណ្តាលកណ្តុក តាបុកខ្លែងខ្លាស់ បង្រាសអាកាស កែវកាសកន្ទី ។ គោតសគោតខ្មៅ ពានពេជកៅ សារីយុគទន់ដី រាយរើកកៅមាន់ ពោតពាន់ពិសី ប្រស់ប្រង់ឈ្មោលញី ញីញែកសិលា ។ ចំរុះបាកាល ឯអះគ្រុយឈ្មោល ពិកុលពិកា លំពាន់បំពាំង មាសមាំងបេដា មានម្នាងសិលា លោតលៀបលាំងដៃ ។ ព្រះខ្វបព្រះក្រាច ព្រះក្រុងដើងតាប ចេកតាកពានតៃ រលួបរលាយ ក្រូចក្រាយធ្មួងឆ្មៃ សណ្តាន់សន្ធៃ សន្ទះខ្យូងខ្យា ។ ពកពុកឆ្មាជ្រុង ពេនពកសំកុង ក្តោមក្តាតគោ រៀបទកពារ ចាគូចែបារ សម្រែកកុមារ កុមារមហាវិគ្គ ។ ចំត្រមូបក្តៀង ក្រាំងយាង

ឈើភ្លើង កន្ត្រាកប្រយុទ្ធ ស្រមពិភេក សម្រែកថ្ងូថ្ងឹង កណ្តាល
កណ្តឹង ដំរីរំដេញ ៗ រំជួលជោះទាង ជោះទិងឥជាន ក្រញូវ
ក្រញិញ ក្រញាំសុខខ ចំបក់ប្រផិញ ប្រជាក់ម្រះម្រេញ ព្រាមដៃទាន
នួន ៗ សហស្សគុណ តាំងទុំតាំងគុណ ដំដុះប្រក់គួន ប្រក់ដីសីសាច់
ស្មៅស្មោះចំម្ញុខបួន លីងលាក់ត្រកួន កំព្រាតខុម្ពរ ៗ ស្មាក់ស្មែង
ស្មូតស្មុឹក សោកម៉ោកញាតញឹក កំទីកំទរ កំទេចប្រាក់ប្រេញ
រំដេញជកពរ ដកពាយវាយវរ រមៀតមៀនមង ៗ ជនស្ម
ជន្ទាត់- ដៃដើមពាល់ពាត់ ពោះពាយហួតហួង ស្រកាក្តាមក្តាត ស្អុំ
ស្អាតដូងដង ដើងដីសដុះរង សំពេងពេគកជ ៗ ឈើឯម
អកល្អួន អកកពជតបដូង កញ្ចើបាយជាប ជ្រួយប្រែសប្រកែង-
ខ្ទួយតែងប៉ប្រាប ប៉ប្រក់ស្នាយស្នាប នាងនិលពិសី ៗ បន្ទួញ
ពាំងក្អួ ទុំពេកសុក្រំ សុក្រាបតាលី ដីប្ញុំបក់ ត្របកឆ្ញេញត្រី
ក្របកក្របី កប្បាសព្រៃព្រាល -ៗ ប្រមាត់ដីដុះ ក្អែកព្រាបលាជផ្ដុះ
កញ្ច្រាលមហាពល មហារីកស្រឡប់ ឆ្លួនងឹបពពាល នាក់និលបាក់ជាល
បាក់ជោរជាតព្រឹក្ស ៗ ដូងដុះសែជា តោលទឹកជោះខ្វា ប្រមាត់សត្វ
ម្រឹគ ត្រចៀកប្រើសប្រោង លោតលោងប្រវឹក ស្រវឹងផ្អាក់ទឹក
ផ្អាក់ទេសទុល្យភេ ៗ

(នៅមានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## រឿងនាងសក់ក្រអូប

លោក ញ៉ែម-ទឹម រៀបរៀង

កាលពីសម័យដើម មានស្ដេចមួយព្រះអង្គព្រះនាមបទុមតារសោយរាជ្យនៅក្នុងនគរកូមា ។ ព្រះមហាក្សត្រអង្គនោះទ្រង់សព្វព្រះរាជហឫទ័យចង់បាននាងសក់ក្រអូបធ្វើជាមហេសី ។ នាងសក់ក្រអូបជាស្ត្រីមានរូបឆោមលោមពណ៌ល្អក្រៃលែង តែនាងមានព្រះស្វាមីរួចទៅហើយ គឺព្រះបាទបយង្កោរសោយរាជ្យនៅនគរទ្រាំង(១) ជិតភ្នំជើងកងជុំ ។ ព្រះនាងសក់ក្រអូបនេះទ្រង់មានព្រះរាជបុត្រមួយ ព្រះនាមព្រះបាទព្រះហស្តខ្លី ។

ដោយព្រះបាទបទុមតារនៃនគរកូមា ទ្រង់ចង់បាននាងសក់ក្រអូបធ្វើជាមហេសីពន់ប្រមាណ ព្រះអង្គក៏ទ្រង់សម្រេចព្រះទ័យថានឹងដណ្ដើមយកនាងសក់ក្រអូបដោយកលឧបាយឲ្យខាងតែបាន ។ ដូច្នេះ ព្រះអង្គក៏ទ្រង់ត្រាស់បង្គាប់ឲ្យគេធ្វើក្បួនមួយយ៉ាងធំ នៅក្នុងត្រពាំងមួយឈ្មោះត្រពាំងខ្ទក ដែលកាលជំនាន់នោះជាសមុទ្រ ។ រួចព្រះអង្គក៏នាំនាដការីនីពួកក្មេង

១– ទ្រាំងជាខេត្តមួយនៃប្រទេសកម្ពុជា ឋិតនៅខាងទិសនិរតីនៃក្រុងភ្នំពេញ ពីដើមគេច្រើនហៅថា ដីទ្រាំង, មានខេត្ត ១១ រួមបញ្ចូលហៅថា នគរទ្រាំង: គឺ ទ្រាំង, បន្ទាយមាស ពាម, កំពត, កោះធំ, ស្អាង, ព្រៃកប្បាស, បាទី, កណ្ដាលស្ទឹង, តងពិសី មឹងភ្នំស្រួច ។

ទៅលេងកំសាន្តលើទីនោះ ព្រមទាំងបានអញ្ជើញស្តេច នឹងព្រះនាង សក់ក្រអូបទៅរួបរួមជាមួយនឹងព្រះអង្គផង ។

ជាអកុសលនៅថ្ងៃនោះ, ព្រះបាទបយង្ក្រាមមិនបានយាងមកកាន់ទីកំសាន្ត តាមសេចក្តីអញ្ជើញនៃព្រះបាទបទុមតរទេ ព្រះនាងសក់ក្រអូប ទ្រង់យាងមកមួយអង្គឯង ជាមួយនឹងព្រះរាជបរិពារ ។ ព្រះបាទបទុមតរ ទ្រង់សង្កេតឃើញព្រះនាងយាងមកមួយអង្គដូច្នោះ ហើយនៅពេលដែល ព្រះនាងកំពុងគង់ទតអ្នកកំទឹងស្តាប់ភ្លេង ក៏ទ្រង់លបកាត់ព្រួរចងក្បូនបណ្តែត ចេញទៅកណ្តាលសមុទ្រ ។ អាស្រ័យហេតុដូច្នោះហើយ បានជានាង សក់ក្រអូបត្រូវព្រះបាទបទុមតរ ចាប់នាំយកទៅដល់នគរកូមា ។

ព្រះនាងក៏ត្រូវស្តេចបទុមតរ បង្ខំឲ្យនៅក្នុងនគររបស់ព្រះអង្គ អស់កំឡុង ២២ ឆ្នាំ ។ នៅពេលនោះ ព្រះអង្គម្ចាស់ព្រះហស្តទ្វីក៏ទ្រង់ធំពេញវ័យហើយ ។ ព្រះអង្គក៏ទ្រង់សួរទៅបិតាព្រះអង្គថា តើព្រះមាតាព្រះអង្គនៅឯណា ។ ស្តេចបយង្ក្រាមក៏ឆ្លើយប្រាប់ថា ស្តេចបទុមតរសោយរាជ្យនៅនគរកូមា, បានមកលេងនឹងព្រះអង្គតាមក្បូនមួយយ៉ាងធំ ។ នៅលើក្បូននោះ មានពួកនាងកាទីងពួកភ្លេងជាច្រើនមកជាមួយព្រះអង្គផង ដើម្បីនឹងមកអញ្ជើញមាតាកូនឲ្យទៅលេងជាមួយ ហើយទៀតយកឱកាសដែលមាតាកូនឯងយាងទៅតែម្នាក់ឯងនោះ, ចាប់មាតាកូនឯងយកទៅបាត់ទៅ ។

ព្រះបាទបយនេគ្រ ទ្រង់មានព្រះរាជបន្ទូលរ៉ាប់រៀបប្រាប់ព្រះរាជបុត្រព្រះអង្គតាំងអំពីរឿងដែលស្តេចបទុមតរបាទលបការត់ឬបង្គប្បន, បណ្តែតទៅកណ្តាលសមុទ្រ, ហើយលួចយកមហេសីព្រះអង្គបាត់ទៅ អស់ពេលចំនួន ២២ ឆ្នាំមកហើយ ។

ព្រះអង្គម្ចាស់ព្រះហស្តខ្វី កាលបើបានទ្រង់ព្រះសណ្តាប់នូវព្រះបន្ទូលបិតាដូច្នោះ គឺសុំអនុញ្ញាតព្រះបិតាចេញទៅរកព្រះមាតាឯនគរកូមា ។ ព្រះវរបិតាក៏ទ្រង់យល់ព្រមតាមសេចក្តីសុំនៃព្រះរាជបុត្រ ។ លុះក្រោយពីបានយាងទៅដល់នគរនោះ ទឹងក្រោយពីបានធ្វើឲ្យព្រះមាតាស្គាល់ព្រះអង្គម្ចាស់ហើយ, ព្រះអង្គម្ចាស់ក៏បបួលព្រះមាតារត់ចេញពីនគរកូមាជាមួយព្រះអង្គ ។ អាស្រ័យហេតុនេះ, ព្រះនាងសក់ក្រអូបក៏បានត្រឡប់មកជួបនឹងព្រះបាទបយនេគ្រឯប្រាសាទដើងកងជុំទៅនគរទ្រាំងវិញ ។

ឯស្តេចបទុមតរកាលបើទ្រង់បានជ្រាបថា ព្រះនាងសក់ក្រអូបបានរត់ចេញពីមហាប្រាសាទបាត់ហើយ ក៏ទ្រង់លើកពលរេហ៍តាមមួយរំពេច (មកដល់បន្ទាយព្រាល ដែលបិតនៅទិសនិរតីពាយព្យ នៃប្រាសាទតាទីសព្វថ្ងៃនេះ) ប៉ុន្តែ ឥតបានទាន់ព្រះនាងសក់ក្រអូបទេ ។ ព្រះបាទបទុមតរក៏បញ្ឈប់កងទ័ពនៅទីនោះ ដើម្បីនឹងរៀបចំក្បួនចម្បាំង ។

ព្រះនាងសក់ក្រអូបកាលបើទ្រង់បានជ្រាបថា ស្តេចបទុមតរទ្រង់

យេប់នៅត្រង់កន្លែងនោះ ‚ គំហាត់ប្រតិភូម្នាក់ឲ្យទៅទូលព្រះអង្គថា សូមព្រះអង្គកុំបាំបាច់ធ្វើចម្បាំងជាមួយនឹងស្តេចឋយរោគ ជាព្រះស្វាមីព្រះនាងព្រោះតែរឿងព្រះនាងដូច្នោះធ្វើអ្វី, ព្រោះព្រះនាងមានមធ្យោបាយប្រសើរជាងនេះ ដើម្បីនឹងដោះស្រាយរឿងនេះ ឲ្យបានស្រួលដោយសន្តិវិធី គឺព្រះនាងបានសន្យាថា នឹងត្រឡប់មករកព្រះអង្គវិញ បើសិនជាព្រះអង្គអាចសង់ប្រាសាទមួយនៅជិតបន្ទាយព្រះអង្គនេះ ឲ្យបានហើយស្រេចមុនពេលផ្កាយព្រឹករះ ។

ព្រះបាទបទុមពារក៏ទ្រង់យល់ព្រម តាមសេចក្តីស្នើរបស់ព្រះនាងហើយបានទ្រង់ឆ្លើយប្រាប់ទៅព្រះនាងវិញថា ព្រះអង្គនឹងសង់ប្រាសាទមិនត្រឹមតែមួយប៉ុណ្ណោះទេ គឺពីរក៏បានដែរ ឲ្យបានហើយមុនពេលផ្កាយព្រឹករះ ។ បន្ទាប់ពីនោះក្រោយមក, ព្រះអង្គក៏ទ្រង់ត្រាស់បង្គាប់ឲ្យពលសាកលយោធាព្រះអង្គ ចាប់សង់ប្រាសាទពីរ មួយនៅត្រង់កន្លែងវត្តប្រាសាទតំបន់តាទីសព្វថ្ងៃនេះ ក្នុងស្រុកបន្ទាយមាស, មួយទៀតនៅលើកំពូលភ្នំកំពែង ក្នុងស្រុកត្រាំង ។

ចំណែកឯព្រះនាងសក្រអូបវិញ ក៏ចាប់សង់ប្រាសាទមួយនៅលើកំពូលភ្នំកន្ទុំ, កាលបើសង់ប្រាសាទបានប៉ុនថ្នាក់ហើយ ព្រះនាងដែលជាស្ត្រីមានប្រាជ្ញានឹងមានកលល្បិចយ៉ាងខ្ពង់ខ្ពស់ ក៏ទ្រង់បង្គាប់ឲ្យគេ

បង្ហោះគោមមួយធំឡើងខ្ពស់ទៅលើចំកណ្តាលប្រាសាទ ដែលសង់ពុំទាន់ហើយ, ដើម្បីបំភាន់ព្រះបាទបទុមតាថាជាផ្កាយព្រឹករះ ហើយព្រះអង្គមុខជាអស់សង្ឃឹមឲ្យពួកជាងឈប់សង់ប្រាសាទទាំងពីរនោះពុំខាន ។

ស្តេចបទុមតាទ្រង់ពលទាហាន កាលបើក្រឡេកទៅឃើញពន្លឺគោមដូច្នោះ ក៏យល់ថាជាផ្កាយព្រឹករះ ហើយអស់សង្ឃឹមក៏មកឃាត់ពួកពលសេនាឈប់សង់ប្រាសាទតាទី និងប្រាសាទភ្នំកំពែងនោះទៅ ។

លុះក្រោយបន្តិចមក ទើបឃើញផ្កាយព្រឹកមែនទែនរះឡើង, ព្រះអង្គយល់ថា ពិតជាចាញ់ឧបាយកលព្រះនាងសក់ក្រអូបហើយ តែធ្វើដូចម្តេចបើវាជ្រុលហួសទៅហើយ ។ អាស្រ័យហេតុនេះបានជាព្រះបាទបទុមតា ត្រូវព្រាត់ប្រាសពីនាងសក់ក្រអូប, ព្រាត់ប្រាសដោយចាញ់ឧបាយកលព្រះនាង, តែព្រះអង្គពុំហ៊ានប្រើកំឡាំងតទល់ឡើយ ហើយព្រះអង្គក៏លើកកងទ័ពថយដោយសេចក្តីអាឡោះអាល័យ ទៅតាំងទីលំនៅខាងកើតភ្នំក្រម ខាងត្បូងតានវិញ ។ នៅទីនោះ ព្រះអង្គបានទ្រង់ព្រះបញ្ញាឲ្យគេចារឹករឿងនៅលើសិលាមួយផ្ទាំងធំ និងឆ្លាក់រូបព្រះនាងសក់ក្រអូបជាប់នៅជាមួយនោះផង ។ រួចព្រះអង្គក៏យកសិលាចារឹកនិងរូបចម្លាក់នោះទៅដំកល់ទុកនៅលើភ្នំក្រម រួចព្យាករថាកុំឲ្យនរណាមួយអាចមើលអក្សរចារឹកនេះយល់បានឡើយ ។ តមក, ព្រះមហាក្សត្រ

ព្រមទាំងពួកពលសេនាយោធា ស្ដេចយាងនឹងធ្វើដំណើរត្រឡប់ទៅនគរកូមាវិញ ។

ព្រះនាងសក់ក្រអូបកាលបើទ្រង់បានជ្រាបថា ស្ដេចបទុមតាបានយាងថយចេញពីនគរហើយ ។ បានចារឹកអក្សរនឹងរូបចម្លាក់ទុកពោលនៅលើភ្នំម្រុំ ក៏ប្រញាប់ប្រញាប់យាងទៅមើលរូបចម្លាក់នោះ ជាមួយនឹងពួកទាហានព្រះនាង ។ កាលបើព្រះនាងបានទតរូបចម្លាក់ នឹងអក្សរចារឹកនោះចប់ ព្រះនាងក៏ទ្រង់ព្រះកន្សែងហើយដួលសន្លប់បាត់ស្មារតីនៅត្រង់ទីនោះ ។ ពួកទាហានរក្សាព្រះអង្គ កាលបានឃើញដូច្នេះក៏ចូលទៅជិតហើយសាកសួរព្រះនាងអំពីហេតុ ដែលព្រះនាងទ្រង់ព្រះកន្សែង, ប៉ុន្តែព្រះនាងមិនមានព្រះសវនីយ៍ឆ្លើយតបដូចម្ដេចឡើយ ។ ដូច្នេះក៏គ្មានជនណាម្នាក់អាចដឹងរឿងនោះ, ព្រោះគ្មាននរណាម្នាក់អាចមើលអក្សរចារឹកនោះដាច់ឡើយ ។

លុះក្រោយមក ដោយហេតុថា ប្រាសាទដែលព្រះបាទបទុមតាបានសង់នោះនៅត្រង់វត្តតានី, គេហៅវត្តនោះថា វត្តប្រាសាទតានី, ឯកន្លែងរូបចម្លាក់ព្រះនាងសក់ក្រអូប ដែលឋិតនៅលើភ្នំម្រុំនោះ, ក៏បានឈ្មោះថាភ្នំម្រុំព្រះឧង្ហារ ។

---

# រឿងសង្គ្រាមរវាងគីង្គក់ និង ព្រះព្រហ្ម

លោក លាង-ហាប់-អាន រៀបរៀង

---

សម័យពីព្រេងនាយ ក្នុងកាលមួយ, ពិភពលោកកើតមានទុរ្ភិក្សអត់បាយ ក្តៅហួតហែងគ្រប់ទិសទី ព្រោះតែព្រះពិរុណមិនបង្អុរភ្លៀងមួយដំណក់មកលើផែនដីនៃទ្វីបលោកនេះសោះ ៗ ស្មៅ ចុក, ត្រពាំង, បឹង, ព្រែក, រហូតដល់ទៅទន្លេរីងទឹកសឹងតែគ្មានមួយដំណក់; សត្វធំទាំងឡាយ ស្លាប់គរឆ្អឹងលើគ្នា រុក្ខជាតិនានាស្វិតក្រៀមក្រញង់បាត់បង់ជីវិត សឹងតែឥតសល់ឡើយ ៗ ពួកមណ្ឌុកសត្វ មានគីង្គក់, ហ៊ីង, កង្កែប, ដែលជាសត្វពុំនអត់ធន់ ស្គមលៀនក្អែកនៅតែស្បែកនិងឆ្អឹង មិនដឹងរកទឹកឯណាអាស្រ័យរស់នៅបាន ៗ ថ្ងៃមួយ គីង្គក់ជាមេបានប្រកាសដល់ក្រុមញាតិសាលោហិតទូវហ៊ីង កង្កែបជាមិត្តថា ហៃមិត្តទាំងអស់គ្នាអើយ មើលទៅព្រះព្រហ្មមិនបង្អុរភ្លៀងមកទល់ដល់ជីវិតយើងទេ បើយើងនៅស្ងៀមយ៉ាងនេះ មិនអើពើទេ មុខជាដាច់ពោះលៀនអណ្តាតស្លាប់អស់ហើយ ៗ មករួមមិត្តយើង កេណ្ឌគ្នាទៅតយុទ្ធនឹងតាព្រហ្មយកព្រះពិរុណឲ្យបាន, អាសន្នដល់ហើយ ស្ងៀមក៏ស្លាប់, ចូលប្រយុទ្ធក្នុងសង្គ្រាមក៏ស្លាប់ បើម៉្យាងនឹងស្លាប់ ៗ ក្នុងចម្បាំង យកជ័យដល់ក្រុមញាតិនិងដល់ជីវិត ទើប

ប្រសើរ, មក! មក! ទៅប្រយុទ្ធ! ។ ក្រោយដែលបានប្រកាសយ៉ាងនេះ ពលគីង្គក់ជាញាតិនិងមិត្តទាំងអស់ ក៏ព្រមព្រៀងលើកព្យូហយាត្រាចេញទៅកយុទ្ធនឹងតាព្រហ្មដ៏អាកាស ក្នុងព្រះវិមានលោកឥតបង្អង់ ។ កងទ័ពមណ្ឌុកសត្វដើរកាត់ទីវាលឥតញាប់ញ័រ បន្តិចមកស្រាប់តែប្រទះនូវទ័ពមួយហ្វូងធំទៀត លើកកាត់ដម្រង់មក ។ មេបញ្ជាការធំ នៃទ័ពគីង្គក់បានស្រូតទៅពិនិត្យ ស្រាប់តែប្រទះនូវពលត្រីអណ្ដែងធំៗ យ៉ាងខ្លាច ខ្លួនប្រឡាក់ស្រមក ក្រាំងទៅដោយកំទេចផ្លូលីនឹងផេះនៃវាលស្រែ ។ មេគីង្គក់សួរប្រញាប់ថា «នែវើយ តើកងឯងទៅណាក៏ប្រមៀលខ្លួនហុយដីសំពោងកាត់មុខទ័ព ឲ្យរំខានដល់សេន្យានុភាពអញដែលកំពុងលឿនយ៉ាងនេះ?» ត្រីអណ្ដែងជាមេទ័ពតបឥតសង្ស័យថា «លឿនអើយ! យើងដឹងហើយ; មកយើងព្រួតគ្នាជាទ័ពតែមួយ ទៅកយុទ្ធយកជ័យកុំបង្អង់ ក្រុមយើងនេះជាដំណាងមិត្តភក្តិមច្ឆាគាយើង ដែលបានបញ្ជូនយើងជាមួយបងក្រាញ់ ប៉ុនប្រសប់ខាងរត់លូនធ្លុងក្ន ទឹងបាកយណ៍ជាច្រើន ទៅវាយយកភ្លៀងពីព្រះព្រហ្ម មកបំពេញបឹងស្ទឹង យើង; ទៅ! ទៅកឿន! ។ គីង្គក់ព្ជូរហ្វោះអរណាស់ ក៏នាំដំណឹងមកកងទ័ពគេៗ មួយរំពេចនោះ ស័ព្ទដ៏ហោ ទីងការស្រែកអំណរ បានលាន់ឮចេញពីទ័ពទាំងពីរក្រុម ហើយសត្វទាំងពីរពួកក៏ប្រមូលគ្នាខយាត្រា

កាត់តាមវាលក្ដៅហួតហែងទៅមុខឥតឈប់ឈរ ។ ឆ្ងាយបន្តិចទៅ ស្រាប់តែភ្ញាក់ទីងស័ត្វហើរនៃបាណកជាតិមួយហ្វូង ខ្ទៅខ្ទាប់ឮសូរខ្ទឹង ៗ ។

ទ័ពដើងគោកឈប់ម្រឹងម្រុងស្មារតី ស្រាប់តែមួយរំពេចនោះមេទ័ពយំទីងផុម៉ាល់បន្ទឺសម្លេងពីអាកាសមកថា «នៃវើយ! កខឯង គីង្គក់, ហ៊ុង, កង្កែប, ត្រីអណ្ដែង, ត្រីក្រាញ់, ឯងទៅណាខ្លួនស្រមុកយ៉ាងនេះ?។ គីង្គក់រៀបទាត់តបក្លាមថា «មកៈវុយ! កៀនយំ យើងដឹងហើយថាក្រុមបងលើកទ័ពទៅច្បាំង ព្រោះទត់ក្អែង ខ្ទះឈើព្រៃផ្ដល់ផ្កាធ្វើសំបុកដល់បងមែនប្ដូរ ៖ មកកុំបង្អង់ យើងត្រូវគ្នាទៅតយុទ្ធនឹងតាព្រហ្មកុំឲយដៃ កុំខ្លាចស្លាប់! ទៅ!" ទ័ពគោកទីងអាកាស ហោយកជ័យស្រុះស្រួលគ្នាហើយក៏លើកតទៅទៀត ។ លុះដល់ជិតបក្ការស្ទួតមួយស្រាប់តែទ័ពនេះប្រទះនូវផ្ទៃត្រសក់ស្រូវ រដូករណែលលើផ្ទួង ដាច់របេះពីទងគួរឲ្យអាណិតអាសូរពេក ។ ត្រសក់មួយស្រែកដោយមានសង្ឃឹមថា កៀនអើយ! ឲ្យគ្នាយើងដោយសារទៅផង តែខំយើងស្ទួតស្លាប់អស់ហើយ កៀនទៅច្បាំងយើងក៏ស៊ូស្លាប់ចំពោះគ្រួសារយើងដែរ មិនឲ្យនៅវេទនាទេ; មេទ័ពអាំងបីក៏យល់ព្រមឲ្យត្រសក់ស្រូវប្រមៀលខ្លួនទៅតាមក្បួន ។ លុះផុតពីវាល ក៏បានដល់ទៅព្រៃមួយដែលរុក្ខជាតិទាំងឡាយក្រៀមក្រញ៉ាមស្លាប់ជិតអស់ ។ ទ័ពបានទៅដល់

ឃើញវល្លិផ្កាធំ ៗ ពីរដើមនៅនឹងគល់ឈើស្តុកមួយដើម ៗ ផ្កាស្អូរ យ៉ាងកេកាយថា នែះគឿន ! ទៅណាហ្នឹងក៏សន្ទឹកម្ល៉េះ គឿនមិនអាស្រូរ ដល់មិត្តក្រុមតែគ្នា យើងទេឬ ? ឃើញទេស្តាប់ដេករតូនដោយដៃតាព្រហ្ម អស់ហើយ, ឲ្យយើងទៅច្បាំងផង យើងនៅយ៉ាងនេះក៏វេទនាណាស់ ដោយការសន្តិតសន្តិនពីគេ យើងស៊ូទៅស្តាប់កងសង្គ្រាមជ័យ ដើម្បី ដណ្តើមយកជ័យ មកផ្តល់ដល់ជីវិតសត្វលោក ៗ ទ័ពទាំងអស់ក៏មិន បានឃាត់យ៉ាងទេ គេបានឃល់ព្រមឲ្យផ្កាគោចរទៅតាមគេ ៗ

ក្រោយមកទ័ពទាំងអស់ក៏បានមកដល់ទីឋានព្រះព្រហ្ម ៗ គឺង្គក់ បានបញ្ជាឲ្យឃ្មុំប្រុងវាយសម្រុក នៅខ្វាងទ្វារខាងមុខនឹងខាងក្រោយ ត្រីអណ្តែង, ទីងក្រាញ់ ដែលខ្ទង់ប្រឡាក់ពេញដោយក្បួងនេះ ឲ្យទៅ ចូលកងពាងទឹងផើងទឹកនៅមាត់ទ្វារក្រោយ ទឹងពាងផ្សេង ៗ ឲ្យតែ មានទឹក, ផ្កាទាំងពីរធំ ៗ ឲ្យឈរប្រុងនៅមាត់ទ្វារប្រាសាទ, ត្រសក់ ស្រូវឲ្យប្រមៀលទៅទៀបដើងក្រោមអាសនៈតាព្រហ្មគង់នៅ, ឯក្រុម គីង្គក់, ហ៊ុង, កង្កែប, ជាទ័ពស្រួចអ្នកចូលលុក ៗ លុះចាត់ស្រេច ហើយ ទ័ពមណ្ឌកសត្វក៏ចូលស្រែ ចំពោះអាសនៈព្រះព្រហ្មគង់នៅ ដោយស្រែកហោសន្ធាប់យ៉ាងខ្លាំង ធ្វើឲ្យពលរេហ៍អស់ទាំង ទេវតា, មេទំ, មេនាង, ចៅដិត, ចៅចម ជំពាររត់ចេញពីប្រាសាទស្ទុះស្ទាទៅត្រូវទឹក

ផេះ, ទឹកក្បួនដែលពួកត្រីឡណ្ដែនទីនក្រាញ់ កញ្ជ្រោកប៉ោកប៉ាបជះមក លើក្អែកផ្កាលេញទឹងស្រពាំងកេទិសដំបងពុំឃើញ ថែមទាំងត្រូវពួកឃ្មុំ, ឪមាល់ទិច ចុកឈឺមួលស្រែកយំពេងកេប្រកពុំយល់ ៗ ព្រះព្រហ្ម កេប្រកពុំទាន់ស្រែកសួរថា នែវើយ អាពួក គង្គក់, ហ៊ុង, កង្កែប ចង្រៃឯងទៅណា ? ពួកមណ្ឌុកសត្វឆ្លើយថា យើងមកច្បាំង យើងមកច្បាំង . . តែប៉ុណ្ណោះ ៗ តាព្រហ្មក៏ចុះចាកអាសនៈដោយមិនមើលក្រោម ក៏ជាន់លើត្រសក់ស្រូវអើលដួលផ្កាស្រពាន ត្រូវផ្តៅទាំងពីរបន្ទន់ខ្លួន ប្រញាប់ សង្កត់កជាប់ ឃ្មុំក៏ទិចឈឺផ្សា ស្រែកចុះញ៉ឹមពួកសត្វទីងរុក្ខជាតិ ថា៖ ចាញ់ហើយ ! ចាញ់ហើយ ! ៗ ពួកនោះ មេបញ្ជាការ សេនាទុកាពគង្គក់ ក៏ឃាត់ទ័ពឲ្យឈប់ ដើម្បីដោះស្រាយបញ្ហាចុះចាញ់ គង្គក់សួរទៅតាព្រហ្មបពជ័យថា « ម៉េចក៏លោកបង្អត់ភ្លៀងដល់សត្វលោកយ៉ាងនេះ ? ធ្វើឲ្យស្លាប់គ្រប់កន្លែងដូច្នេះ, គ្នាយើងមកនេះមិនសុខចិត្តទេ បើលោកមិនបង្អុរភ្លៀងចុះទៅទេ នោះយើងនឹងក៏ទេចរមានលោក សម្លាប់អស់ពលនឹងលោកពុំខាន' តាព្រហ្មទកក័យក៏និយាយអង្វរអស់ពលសាកលយោធាសត្វនឹងរុក្ខជាតិថា: សូមអស់ព្រះស្តេចកុំខឹង, យើងខ្លាចហើយ យើងនឹងផ្តល់ទឹកភ្លៀងឲ្យព្រះស្តេចឥឡូវនេះហើយ សូមអ្នកអញ្ជើញចុះទៅវិញៈដោយក្សេមក្សាន្តទៅ, កុំខឹងអី, គង្គកតប

ថា ទេ ! កូនយើងមិនយល់ព្រមទេ, បើយើងទៅ នោះលោកនឹងផ្ដល់ ភ្លៀងឲ្យយើងតែមួយមេ ដល់ក្រោយទៀតលោកព្រងើយកន្ដើយ នាំឲ្យពិបាកយើងលើកទ័ពឡើងមកទៀត ដូច្នេះ សូមលោកសន្យាឲ្យពរពិសេសដល់យើងសិន ទើបកូនយើងព្រមសុខចិត្ត ។ លុះជញ្ជឹងមួយសន្ទុះ ព្រះព្រហ្មក៏មានបន្ទូលថា អើ ! យើងព្រមឲ្យពរដល់អ្នកពលគ្នា ។ គីង្គក់, ហ៊ុង, កង្កែប ! បើកាលណាអ្នកត្រូវការភ្លៀង ត្រូវអ្នកសង្កៀតធ្មេញបន្ទឺសម្លេងពីក្រោមមក ពេលនោះយើងនឹងបង្អុរភ្លៀងឲ្យអ្នកភ្លាម ។ កាលបើសន្យាចុះហត្ថលេខា លើសន្ធិសញ្ញារួចស្រេច ទ័ពមណ្ឌកសត្វ, បាណកសត្វ នឹងរុក្ខជាតិក៏លើកថយមកលំនៅរៀង ៗ ខ្លួន ។ ដល់ដី កង្កែប, គីង្គក់, ហ៊ុង, ក៏តាំងសង្កៀតធ្មេញបន្ទឺសម្លេង អែបៗ ! អោកៗ ។ ហ៊ុងហ៊ីងៗ ! ភ្លៀងក៏ធ្លាក់មកជាខាងក្រោយ ។

យ៉ាងនេះហើយ បានជាគេនិយមជឿតគសមហេតុសមផលថា ភ្លៀងគឺតាព្រហ្មព្រះព្រហ្មធ្វើឲ្យធ្លាក់មក ។ ដោយពិត គឺចំហាយទឹកដែលហួតហែង ដោយកំដៅព្រះអាទិត្យកកដោយធាតុត្រជាក់ជាពពកទន្ទិចគ្នាបង្កើតជាទឹកធ្លាក់មកសោះ ៗ ឯថាហ៊ុង, កង្កែប, គីង្គក់យំហៅភ្លៀងនោះ ក៏ជាពាក្យដំណាលកំសាន្តសោះ, ដោយពិតគឺវាក្ដៅហើយស្រែករកទេ តែបើនរណាគេជឿតាមរឿងនិទានខាងលើនេះក៏មិនខុសដែរ ព្រោះគេតែងសំគាល់ឃើញក្រោយការមណ្ឌកសត្វយំក៏មុខជាមានភ្លៀងមែន ។

## រឿងព្រេងប្រទេស អ៊ុយក្រែន

ចែងអំពី

# កូនឲ្យបិតាជរាយាត្រាទៅរៀន

ភិក្ខុ ម៉ែន រៀម

សិស្សពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ

ប្រែពីភាសាអង់គ្លេស

---

សម័យមួយ មានតាចាស់ម្នាក់ មានកូនប្រុសបួននាក់ ។ តាចាស់នោះ កាលដែលវ័យរបស់គាត់កាន់តែជរាទៅ គាត់បានចែកទ្រព្យសម្បត្តិទាំងអស់របស់គាត់ ឲ្យកូនប្រុសទាំងបួននាក់នោះ ដោយគាត់គិតថា ថ្ងៃណាមួយ អាត្មាអញនឹងទៅកាន់បរលោក ពេលកូនទាំងអស់មិនទាន ។

កាលចែករួចហើយ តាជរាក៏យាត្រាទៅនៅជាមួយកូនច្បងរបស់គាត់ ។ ដំបូង កូនច្បងនោះ បានគោរពប្រតិបត្តិគាត់ ដោយគេនិយាយថា យើងត្រូវតែជូនម្ហូបចំណី, ទីសំណាក់អាស្រ័យ, សម្លៀកបំពាក់ឲ្យគាត់ ទីដេកដាក់ថែរក្សាគាត់ឲ្យត្រឹមត្រូវ ហើយឲ្យស្អាតបាតផង ។ ពេលនេះហើយជាពេលដែលកូនច្បង បានទៅជាកូនមួយយ៉ាងគាប់ប្រសើរចំពោះបិតារបស់ខ្លួន ។

ប៉ុន្តែ មិនយូរប៉ុន្មាន, កូនប្រសារនោះក៏ទៅជាមានវិប្បដិសារី ចំពោះគ្រឿងសក្ការៈរបស់ខ្លួនទៅលើបិតា, ជាអ្នកគ្រោតគ្រាតទៅលើគាត់ ថែមទាំងពេលខ្លះ បានគំហកកំហែង ដាក់គាត់ទៀតផង ។

គាត់សត់ មិនអាចទ្រាំនៅអាស្រ័យក្នុងផ្ទះកូនប្រសារនោះ ឲ្យយូរតទៅទៀត ដូចកាលទើបមកនៅនោះបានឡើយ ។ សំលៀកបំពាក់របស់គាត់ដាច់ដាច ដោយគ្មានអ្នកណាប៉ះឲ្យ, គ្មានអ្នកណាចាត់ចែងរៀបចំម្ហូបអាហារឲ្យគាត់ទៀតឡើយ ។ កូនប្រសារ ដោយកើតវិប្បដិសារី ចំពោះការដែលខ្លួនបានថែរក្សាតាចាស់ ក៏សម្តែងអាការៈមិនពេញចិត្ត ( ស្តាយ ) គ្រប់ចំណាក់នំបុ័ង ដែលគាត់ពិសារ ។

ទីបំផុត ដោយតាគ្មានការគាប់ចិត្តបែបនេះសោះនោះ គាត់បានចេញពីផ្ទះកូនប្រសារ រួចទៅនៅជាមួយកូនទីពីរ ។ ប៉ុន្តែ ក្នុងពេលយ៉ាងខ្លី តាចាស់បានភ្ញាក់ខ្លួនដឹងថា គាត់គ្រាន់តែប្តូរស្រូវសាលី យកចំបើងវិញប៉ុណ្ណោះឯង ។

គ្រប់តែពេលដែលគាត់បរិភោគ, បុត្រទីពីរ និងកូនប្រសាស្រីរបស់គាត់ ក៏សំដែងអាការៈជូរចត់, ខ្សឹបខ្សៀវអ៊ុចេះអ៊ុចុះ រអេចរអូច ដែលមិនជាទីគាប់ចិត្ត ចំពោះគាត់ ។ ជាញឹកញយណាស់, នាងកូនប្រសា ចេះតែរអ៊ូរទាំដាក់តាដោយពោលថា ៖

– កាលពីពេលមុនដែលតាកញ្ញាសមកនៅផ្ទះយើង, យើងមានប្រាក់កាសល្មមតែនឹងសេចក្ដីត្រូវការរបស់យើងប៉ុណ្ណោះ; ស្រាប់តែឥឡូវនេះ យើងត្រូវទ្រាប់ទ្រុកមួយថែមមកទៀត ! . . ។

ពេលនោះ តាចាស់ ក៏មិនអាចទ្រាំនៅជាមួយកូនទីពីរនេះទៀតបាន ម៉្លោះហើយ គាត់ក៏ចេញទៅនៅជាមួយកូនទីបី ។ កូនទីបីនេះ ក៏ដូចជាកូនទីពីរដែរ ហើយតានោះគាត់បានចេញទៅនៅជាមួយកូនពៅរបស់គាត់ទៀត ។

ឯកូនពៅសោត ក៏មិនថ្លៃកអ្វីពីពួកកូនបង ៗ ដែរ ។ តាចាស់បានចេញទៅ ពីផ្ទះកូនមួយ ទៅផ្ទះកូនមួយទៀត តាមបែបនេះ ។ ទីបំផុត តាមានសេចក្ដីកកយ ចេញពីផ្ទះកូនទាំងអស់នោះតែម្ដង ។

គ្រប់កូនទាំងអស់ ម្នាក់ៗបានជម្រុញបន្ទុកនៃការថែរក្សាបិតាខ្លួនទៅលើម្នាក់ដទៃទៀត ។ ពេលនោះ, មានការពិភាក្សាគ្នាយ៉ាងសម្បើមរវាងកូនទាំងឡាយនោះ ដើម្បីដោះស្រាយបញ្ហាថា «តើអ្នកណាល្មមទទួលខុសត្រូវចំពោះបិតាបាន ?» ។ ម្នាក់ថា ពិបាកយ៉ាងនេះ, ម្នាក់ទៀតថា មានការពិបាកយ៉ាងនោះ ។ ទីបំផុត គ្មានអ្នកណាមួយស្ម័គ្រទទួលចិញ្ចឹមបិតាខ្លួនឡើយ ។ ម្នាក់នេះ មានកូនតូចៗច្រើនពេក, ម្នាក់ទៀតនោះ មានប្រពន្ធជាស្រីញ៉ាំញ៉ីវជាក់គាត់, ផ្ទះកូន

នេះតូចពេក ហើយផ្ទះឯណោះក្រពេក ៗ «ណ្ហើយ ! សព្វញៀវទៅណា ក៏តាមចិត្ត ប៉ុចុះ ! គ្រាន់តែគុំមកកើយើងតែប៉ុណ្ណោះបានហើយ !» ( ពួកកូននិយាយ ) ៗ

តាក៏សត់ ក៏យំហ៊ឺៗ មុខកូនខូច, មិនដឹងថាទីនៅឯណា មកខាងណា ៗ គាត់អស់ការគស្បីស្អីទៀតហើយ, ស្រេចតែកូនប្រាថ្នាចង់ធ្វើអ្វីចំពោះគាត់ ក៏តាមចិត្តចុះ ៗ

ពេលនោះ ពួកកូនមកជួបជុំគ្នា ដើម្បីសំរេចការថា តើត្រូវធ្វើដូចម្ដេចចំពោះគាត់ ? ៗ ទីបំផុត, គេព្រមព្រៀងគំនិតគ្នាថា កិច្ចការប្រសើរបំផុត ដែលមនុស្សចាស់អាចធ្វើបាន គឺត្រូវបញ្ជូនគាត់ទៅរៀនឯសាលាគង់ទីណាមួយ ឲ្យស្រឡះទៅ ៗ គេនិយាយថា នៅសាលារៀនឯណោះ នឹងមានដើងម៉ាស៊ាកប់ឲ្យគាត់អង្គុយរៀន, កាលណាគាត់ទៅរៀន ត្រូវយើងដាក់អាហារគង់ស្បៀងរបស់គាត់ ដើម្បីឲ្យគាត់យកទៅពិសារតាមផ្លូវចុះ ៗ

ពិភាក្សារួចហើយ, គេបានប្រាប់តានោះឲ្យជ្រាបពីរឿងនេះ ៗ ដឹងហើយ, តាឥតចង់ទៅសាលានោះសោះ, គាត់បានអង្វរសុំកុំឲ្យកូនបញ្ជូនគាត់ទៅទីនោះធ្វើអ្វី, រួចហើយគាត់ខ្សឹកខ្សួលម្ដងទៀត ៗ គាត់រៀបរាប់ថា ៖

- ក្មេកប៉ាក់ស្រាំនរស់ទៅហើយ ប៉ាមើលឃើញតែភ្នែក ៗ ដែលមាននៅជុំវិញប៉ា ដោយពិបាកណាស់ បើដូច្នេះ ឲ្យប៉ាទៅមើលអក្សរពុម្ពខ្មៅល្អិត ៗ ក្នុងសៀវភៅម្ដេចបាន ថែមទាំងមួយអាយុប៉ានេះ ប៉ាឥតដែលបានរៀនអក្សរលំនាំអ្វីទាំងគេបន្តិចសោះផងនោះ ? ឲ្យប៉ាទៅផ្ដើមរៀនឥឡូវនេះ ម្ដេចកើត ? តើឲ្យគេយកមនុស្សកញ្ចាស់ដូចប៉ា ដែលជិតវិលទៅស្រុកដើមវិញហើយនោះ ធ្វើជាស្មៀនម្ដេចបាន ? ។

ប៉ុន្តែការស្ដីអន្ទះកនេះ ជាការឥតប្រយោជន៍ ។ ពួកកូនបានសំរេចថា ត្រូវតែឲ្យគាត់ទៅសាលារៀន, រួចគេបញ្ជូនគាត់ឲ្យទៅទាល់តែបាន ។

កាលដែលតាកំសត់ បានចរយាត្រាកាត់ព្រៃព្រឹក្សាឆ្ពោះទៅសាលារៀន ដែលតាំងនៅក្បែរទីក្រុងតូចមួយនោះ, គាត់បានជួបអភិជនម្នាក់ កំពង់បរសេះតាមផ្លូវឆ្ពោះមក ។ តាចាស់ បានឈប់អែបចិញ្ចើមថ្នល់ ដោយសេចក្ដីគោរព ដើម្បីបើកផ្លូវឲ្យសេះបរមក ។ ប៉ុន្តែពេលនោះអភិជន បានបញ្ឈប់សេះ ហើយលោតចេញពីសេះមកស្រែកសួរទៅតាចាស់ថា ៖

- អញ្ជើញទៅណា តា ?

- ទៅរៀន ! ( តាឆ្លើយ )

- ទ ! ទៅរៀនឬ លោកឪពុក ? ។ តាមពិតចំណាស់ប្រហែលលោកឪពុក គួរតែឈប់សំរាក ដោយស្ងប់ស្ងៀមក្នុងផ្ទះវិញទើបសម ! ។

ពេលនោះ ទឹកភ្នែក បានហូរជោកមុខតាកំសត់រួចគាត់បានថ្លែងសេចក្តីទុក្ខរបស់គាត់ ប្រាប់អភិជននោះ ។ កាលអភិជន បានស្តាប់រឿងតានោះហើយ គេមានចិត្តអាណិតតាយ៉ាងក្រៃលែង ។ គេគិតមួយសន្ទុះ រួចនិយាយថា ៖

- ល្អហើយ លោកឪពុកជាក, តាមពិតសាលារៀនមិនមែនជាកន្លែងរបស់លោកឪពុកទេ, សូមលោកឪពុកឈប់សោយសោកទៅហើយសូមលោកឪពុក កុំបង្អៀតបង្អល់ចិត្តឡើយ ខ្ញុំនឹងជួយលោកឪពុក ។

អភិជនបានយកចេញពីខ្សែក្រវាត់គាត់ នូវកំប្លោកស្ពាន់មួយ - គឺជាវត្ថុមួយ ដែលពួកចៅកែតែងតែយួរ, ហើយគាត់បានចាក់ជាក់ទៅក្នុងកំប្លោកនោះ នូវវត្ថុមួយលុះត្រាជិតពេញដល់មាត់កំប្លោក ។ គាត់បង់មាត់កំប្លោកយ៉ាងជិតជាប់ រួចដាក់កំប្លោកនោះ ទៅក្នុងហិបឈើមួយដែលគាត់យកពីក្នុងរទេះមក ។ គាត់ហុចហិបនេះទៅតាចាស់ ដោយ

រ៉ាថា ៖

— អញ្ជើញយកវត្ថុនេះទៅផ្ទះលោកឪពុកចុះ ហើយប្រាប់កូន ៗ លោកឪពុកថាយ៉ាងនេះ ៗ

ពេលនោះ អភិជនបានបង្រៀនពាក្យ ដើម្បីឲ្យតាចាស់យកទៅប្រាប់កូន ៗ តាចាស់ បានអរគុណទីងសំដែលសេចក្ដីគួរជ្រាលជ្រៅចំពោះអភិជន រួចត្រឡប់ទៅផ្ទះពួកកូនគាត់វិញ ៗ កាលគាត់វិលទៅដល់ផ្ទះកូន, ពួកកូន ៗ ក៏បានឃើញគាត់យួរហិបនោះ ៗ តាមធម្មតា, កាលបើអ្នកណាមួយយួរហិបចូល ហិបនោះមុខជាមានអ្វីមួយនៅខាងក្នុងជាមិនខាន ៗ

ពេលនេះ ពួកកូន ៗ និងប្រពន្ធរបស់វា ឈប់ហាមឃាត់ឪពុកខ្លួនហើយ ៗ ពួកវា ស្ទុះរត់ទៅជួបគាត់ ដើម្បីឲ្យដឹងថា តើគាត់នាំយកអ្វីពីក្នុងព្រៃមក ៗ មានអាខ្ទះស្រែកយកពាក់ទាក់ចំពោះគាត់ថា ៖

— អញ្ជើញទៅសម្រាកលោកប៉ា, លោកប៉ាប្រាកដជាអស់កម្លាំងណាស់ហើយមើលទៅ ! ៗ

អ្នកខ្ទះថា ៖

— អញ្ជើញទៅពិសាលោកប៉ា, លោកប៉ាមុខជាស្រេកឃ្លានណាស់ហើយមើលទៅ ! ៗ

ក្សណនោះ តាចាស់ក៏ចាប់ផ្ដើមថ្លែងរឿងរបស់គាត់ប្រាប់កូន តាមពាក្យដែលអតិជនជាសំឡាញ់ បានបង្រៀនគាត់រួចមកហើយថា ៖

— អាពៅកូនប៉ា ជាទីស្រឡាញ់ទាំងអស់គ្នា, យូរអង្វែងណាស់ទៅហើយ កាលដែលប៉ាទៅពីកម្លោះ ហើយបានធ្វើដំណើរទៅកាន់ទីនេះទីនោះ ក្នុងពិភពលោកក្នុងពេលដ៏ខ្លីនោះ, ប៉ារកប្រាក់បានបន្តិចបន្តួច ៗ ប៉ាគិតថាអញនឹងសំចៃប្រាក់នេះ ទុកសម្រាប់អនាគត, ពីព្រោះថាដោយពិត មនុស្សម្នាក់ ៗ មិនអាចដឹងអនាគតរបស់ខ្លួនថាជាយ៉ាងណាបានឡើយ ៗ ប៉ាបានចូលទៅក្នុងព្រៃ រួចជីករណ្ដៅមួយក្រោមដើមអ្កូក ហើយកប់គំនរប្រាក់ទុកក្នុងទីនោះ ៗ ចាប់តាំងពីពេលនោះមក ប៉ាលែងភ័យព្រួយ ឬខ្វល់ច្របល់ចិត្តពីរឿងប្រាក់សោះតែម្ដង ពីព្រោះប៉ាមានកូនល្អ ៗ ប្រកបដោយធម៌ គឺអាពៅទាំងអស់គ្នានេះឯង ជាពិខឹង ៗ ប៉ុន្តែ លុះដល់អាពៅឯងបញ្ជូនប៉ាឲ្យទៅរៀនឯសាលា ប៉ាក៏បានដើរក្បែរដើមអ្កូកនោះ ហើយប៉ាក៏និយាយនឹងខ្លួនឯងថា យីអើហ៎, អញដូចជាសង្ស័យណាស់ ដុំប្រាក់ពីរ-បីដុំនេះ តើវានៅរង់ចាំម្ចាស់វាគ្រប់ពេលវេលាមួយយ៉ាងម៉េចអេះ ! ៗ ពេលនោះប៉ាក៏ជីករណ្ដៅកប់ប្រាក់នោះ ហើយបានឃើញប្រាក់ទាំងនោះនៅដូចដែល ទើបប៉ានាំយកមកផ្ទះពេលនេះឯង ៗ ប៉ានឹងរក្សាប្រាក់ទាំងនេះទុក ដរាបដល់

ប៉ាស្លាប់ ។ តែក្រោយប៉ាស្លាប់ទៅ, អ្នកណាដែលនឹងរក្សាប៉ាជាងគេ, អ្នកណាដែលនឹងប្រព្រឹត្តប្រតិបត្តិប៉ាដោយត្រឹមត្រូវបំផុត, អ្នកនោះត្រូវបានចំណែកប្រាក់ដែលមានកំប៊ិថនេះច្រើនជាងគេ ។ ដូច្នេះ, ឥឡូវនេះ ចូរកោក់តាំងអស់គ្នាទទួលប៉ាវិញចុះ មើល៍, កាក់ណាដែលសប្បុរសចំពោះប៉ាចាស់ ដើម្បីប្រាក់ ? ។

ពួដូច្នោះ ពួកបងប្អូនទាំងនោះ ក៏ដេញគ្នាទៅវិញទៅមក ក្នុងការធ្វើសប្បុរសដល់បិតាខ្លួន ។ ម្នាក់និយាយថា "សូមលោកប៉ាអញ្ជើញទៅនៅផ្ទះខ្ញុំ" ។ ម្នាក់ទៀតថា "ទេ ! ទៅផ្ទះខ្ញុំវិញ" ។

ពួកអ្នកអស់នោះ បានយកចិត្តទុកដាក់បំពេញមាតាចាស់ដោយត្រឹមត្រូវ ហើយថែទាំបះសំលៀកបំពាក់ឲ្យគាត់ ព្រោះតែចង់បានសម្បត្តិរបស់គាត់ប៉ុណ្ណោះឯង ។

នេះជាឧបាយកលមួយ ដែលប្រព្រឹត្តទៅហួតដល់ទីបំផុត ហើយតាចាស់ក៏អនិច្ចកម្មទៅ ។

ពេលនោះ កូនទាំងឡាយនោះ បានប្រញាប់ប្រញាល់ទៅយកហិបមកពិភាក្សាគ្នាថា តើអ្នកណាដែលជាអ្នកសប្បុរសបំផុត ចំពោះឪពុក ហើយដែលត្រូវបានទទួលចំណែកប្រាក់ដែលមានកំប៊ិថនោះច្រើនជាងគេ, ។ ពួកអ្នកស្រុកភូមិផងរបងជាមួយ បានត្រូវគេហៅ

មកធ្វើជាចៅក្រមក្នុងរឿងនេះ ៗ ទីបំផុតទៅ គេសំរេចថា កូនទាំងបួននាក់ សុទ្ធតែជាអ្នកមានចិត្តសប្បុរស ចំពោះបិតាខ្លួនស្មើ ៗ គ្នាចាប់តាំងពីពេលដែលគាត់ត្រឡប់មកពីព្រៃ, ម្ល៉ោះហើយត្រូវតែចែកមត៌កឲ្យស្មើភាគគ្នាទើបបាន ៗ

ពួកកូនទាំងនោះ បានរៀបចំធ្វើបុណ្យយ៉ាងអស្ចារ្យ ឧទ្ទិសចំពោះខ្មោចឪពុកខ្លួន, បានរៀបជប់លៀងយ៉ាងឧឡារិកដល់ភ្ញៀវក្នុងភូមិ ដែលបានជួយកាន់ទុក្ខ, បានចំណាយប្រាក់និមន្តព្រះសង្ឃពីព្រះវិហារ (Church) មកសូត្រធម៌អស់សែសិបថ្ងៃ ៗ ម្នាក់ៗ ខំធ្វើឲ្យលើសគ្នាទៅវិញទៅមក, គេបានចំណាយប្រាក់ថែមទៀត ទៅលើព្រះវិហារ ជាគ្រឿងជូនចំពោះការសូត្រធម៌ ៗ

កាលដែលពិធីបុណ្យចប់ហើយ គេបានប្រញាប់ប្រញាល់ទៅបើកហិបមើល ៗ គេក៏បានឃើញកំប៉ោកស្បូវដ៏ធេងធាយនៅក្នុងហិបនោះ ៗ គេលើកកំប៉ោកអង្រួនមើល ក៏ឮសំឡេងច្រើនៗ យ៉ាងពីរោះ ៗ ពួកគេបានស្រាយមាត់កំប៉ោកចេញ រួចតាំងរលាក់អាច្រើន ៗ នោះដាក់ទៅលើតុមួយ ៗ

បពិត្រអើយ ឮដំកាលនោះ ពួកគេរកកល់មិនជឿភ្នែកគេសោះឡើយ, វាគ្មានឃើញអ្វីសោះ, ឃើញដូចជាសុទ្ធតែអំបែងកែវ ! ... ៗ

លុះដល់ព្រលឹមស្រាងឡើង កូនអាកែកទាំងនោះ ក៏ឃើញច្បាស់លែងសង្ស័យថា អាច្រើងៗនោះ សុទ្ធតែជាអំបែងកែវ គ្មានតម្លៃអ្វីបន្តិចសោះ ដែលជាហេតុនាំឲ្យគេច្រឡោតខឹង ហើយដដែកគ្នាយ៉ាងសម្បើម ៗ ប៉ុន្តែ ពួកអ្នកស្រុក នាំគ្នាសើចស្ទើរបុកពោះ ៗ ពួកអ្នកស្រុកនាំគ្នានិយាយថា ៖

- អើ! ហ្នឹងហើយជាកម្រៃនៃការបញ្ជូនឲ្យកូនទៅសាលារៀនការពេះដងរបស់គាត់ នាំឲ្យគាត់សុខសប្បាយបានយូរ; ប៉ុន្តែ អ្វីដែលគាត់បានរៀន គឺគាត់ពេះចំណាប់មែន! ។

# រឿងសាមកុក

## កណ្ឌទី ៤២

ឧកញ្ញាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកភាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ។

ជាប្រក្រតីមកហើយនៅរដូវនេះតែធាតុខ្យល់នឹងធាតុភ្លើងនៅខ្ទន់ណាស់ បើខ្យល់បក់មកត្រូវភ្លើងកំរើកឡើងក្លាហើយ រោគលោកក៏នឹងជាស្រឡះ ៗ

ជីវយ៉ីឃើញសំបុត្រនឹងស្តាប់ពាក្យខុងបេងនិយាយឧបមាដូច្នោះក៏តក់ស្លុតស្មារតីគិតថា ខុងបេងនេះកន្លងដឹងដម្រិះរិះគិតរបស់យើង ដូចទេពតាមកបញ្ចូលចិត្ត ជីវយ៉ីក៏សាស្រាយអធិប្បាយសេចក្តីទាំងពួង ដែលគិតនោះឲ្យខុងបេងស្តាប់គ្រប់ប្រការហើយសួរខុងបេងថា គំនិតរបស់អ្នកនឹងគិតឃើញប្រការម្តេច ទើបឲ្យកើតខ្យល់សលាតន៍មកបាន ឯខុងបេង

នោះបានដឹងក្នុងតម្រាថា ដល់ថ្ងៃ៥ រោចខែបុស្ស នោះនឹងកើតខ្យល់សលាតន៍ជាប្រាកដ តែខ្លាចក្រែងដំរីយើងនឹងយើងធ្វើការជាមួយគ្នាទៅ ដំរីយើងមិនគោតខ្លាចគំនិតដែលគិតនឹងនាំឲ្យដំរីយើងមើលងាយ យើងត្រូវតែប្រើកលឧបាយនិយាយប្រាប់ឲ្យដំរីយើងគិតធ្វើការ ហើយនឹងបបរតទៅ ។

លុះគិតហើយខុងបេងថា ខ្ញុំនេះមានជម្រេះប្រាជ្ញាតិច តែបានប្រទះឃើញក្បួនតម្រាឥតាវម្នាក់ ប្រដៅឲ្យរៀនសុំខ្យល់សុំភ្លៀង ខ្ញុំចាំទុកមក បើលោកនឹងប្រាថ្នាចង់បានខ្យល់សលាតន៍ ត្រូវឲ្យចាត់សង់ពន ៣ ជាន់កំពស់ ១ ជាន់ ៣ ហត្ថបាយ នៅលើកំពូលភ្នំឡាំពិនសាននេះ ហើយសូមតាហាន ១២០ នាក់ កាន់ទង់ផ្សេង ៗ អង្គុយព័ទ្ធរោងពិធីជុំវិញ ដើម្បីនឹងបានបំរើប្រើការ ខ្ញុំនឹងឡើងទៅសែកគាថាមន្តតាមតម្រាគ្រប់ ៣ ថ្ងៃ៣យប់ សុំឲ្យខ្យល់សលាតន៍មានមក ៣ ថ្ងៃ ៣ យប់បាន លោកនឹងបានលើកកងទ័ពទៅបំផ្លាញទ័ពទឹកចូចូបានយ៉ាងមាំ ។ ដំរីយើថា អ្នកកុំបាច់ធ្វើឲ្យដល់ ៣ យប់ ៣ ថ្ងៃឡើយ សូម្បីតែ ១ ថ្ងៃឬ ១ យប់គឺនឹងធ្វើការនោះយកជ័យជំនះបានដោយស្រួល បើអ្នកនឹងធ្វើហើយ គឺត្រូវធ្វើឲ្យបានពេលយប់នេះឬស្អែកបើចង់ទុកឲ្យយូរតទៅ សេចក្ដីដែលគិតនោះគឺនឹងព្រួសាយសុសទៅដល់ចូចូ; ខុងបេងថា ខ្ញុំនឹងធ្វើការហៅខ្យល់ឲ្យបានក្នុងថ្ងៃ ៥ រោចខែបុស្ស ពេលយាម ១ បាយឲ្យខ្យល់សលាតន៍ធ្លាក់មកជា

យ៉ាងខ្លាំង លុះដល់ថ្ងៃ ៧ កេចទើបស្ងប់ ។

ដំរីយើញដូច្នោះ ក៏មានចិត្តសោមនស្សត្រេកអរ ដូចខុនបេនយកថ្នាំទិព្វមកលាយលាបឲ្យកេតដែលឈឺនោះសះជាមួយរំពេច ទើបក្រោកឡើងគំនាប់ខុនបេនហើយក៏បង្គាប់ឲ្យពួកមេការទៅរៀបចំធ្វើកនពិធី ឲ្យទាហានយាមរក្សាតាមពាក្យខុនបេនបង្គាប់ ។ ខុនបេនថា ដែលលោកទីនឲ្យទៅសុំខ្សែលំនោះ ខ្ញុំត្រូវសុំអាជ្ញាសិទ្ធិទៅផង ទើបទីនធ្វើការបានស្រួល ។ ដំរីយើមិនទាន់គិត ក៏យកក្របីដែលស៊ីនគួនឲ្យមកនោះ ប្រគល់ទៅឲ្យខុនបេន ខុនបេនទទួលយកក្របីហើយក៏នាំទៀស្រុកទីនទាហានទាំងពួងឡើងលើកំពូលភ្នំឡាំពិនសាន ហើយធ្វើជាមើលភូមិឋានដែលទីនឲ្យទាហានសង់កេនពិធីនោះគ្រប់ ៣ ជាន់ កន្ទ្រ ១ ជាន់កំពស់ ៣ ហត្ថប្មាយ ជាន់ដើមទំហំ ២០ ព្យាម ៤ ជ្រុង ហើយឲ្យដីកយកដីខាងទិសអគ្នេយ៍ មកប៉ាន់ជារូបមករដំកល់ទុកខាងទិសបូព៌ា កន្ទ្រានជាន់ដើមឲ្យដោតទង់ខៀវ ៧ រួត ប៉ាន់ជារូបទេវតា ឈ្មោះហៀនប៊ូដំកល់ទុកខាងទិសឧត្តរដោតទង់ខ្មៅ ៧ រួតប៉ាន់ជារូបខ្លាដំកល់ទុកខាងទិសបស្ចិមដោតទង់សរ ៧ រួត ប៉ាន់ជារូបក្អែកដំកល់ទុកខាងទិសទក្សិណដោតទង់ក្រហម ៧ រួតដូចគ្នា ឯជាន់កណ្តាលនោះមានមនុស្សកាន់ទង់លឿងប្រចាំទិសទាំង ៨ ទិសទិសមួយៗ មនុស្ស ៨ នាក់ ជាន់លើបង្អស់មានមនុស្ស ៨ នាក់ ម្នាក់នៅទិសបូព៌ា កាន់គោម

វៃយាំ ៧ដួន ម្នាក់ទៅទិសឧត្តរកាន់ឈើចង្កឹងមាន់ ម្នាក់ទៅទិសបស្ចិមកាន់ក្របី ម្នាក់ទៅទិសទក្សិណកាន់តោករងធូបទៀន លុះបាត់ការស្រេចហើយខុនបេនក៏ធ្វើជានិយាយនឹងឡោសុកថា អ្នកបួរជួយត្រឡប់ទៅប្រាប់ជីវយើផា ដែលខ្ញុំមកសុំខ្យល់ឲ្យនេះ បើមិនបានដូចសេចក្តីគិតទេក៏កុំឲ្យជីវយើយកទោសខ្ញុំឡើយ ។ ឡោសុកទទួលពាក្យហើយក៏លាចុះទៅ ។

ឯខុនបេននោះ កាលថ្ងៃ ៣ កេដខែបុស្សវេលាព្រឹក ក៏តាំងទៅងួតទឹកជំរះកាយ ហើយតែងខ្លួនស្លៀកពាក់ដណ្តប់សំពត់ធៀនស្នាម្នាន រំសាយសក់ចុះ ហើយនិយាយនឹងទាហានទាំងពួងថា គ្រានេះយើងនឹងធ្វើការតាំងពិធីជាធំ ឯបណ្តាទាហានដែលយើងបានរៀបចំបាត់តែងទុកទាំងប៉ុន្មាន បើឃើញយើងធ្វើប្រការម្តេច ក៏កុំឲ្យនិយាយគ្នា ឬដើរទៅមកបាកទីកន្លែងឡើយ ត្រូវតែនៅឲ្យស្ងៀមជាប្រក្រតី ទំរាំយើងធ្វើការឲ្យបានសម្រេច បើនរណាហើយមិនស្តាប់ យើងនឹងយកក្របីអាជ្ញាសិទ្ធិដែលជីវយើឲ្យមកនោះកាត់ក្បាលចេញ លុះផ្តាំទាហានរួចហើយ ខុនបេនក៏ឡើងទៅលើពនពិធីជាន់លើ ទើបតាំងអុជធូបទៀនឡើងបូជាទេវតាហើយធ្វើជាអង្គុយភាវនាសែកមន្តគាថាហៅខ្យល់ លុះវេលាសមគួរហើយក៏នាំទាហានទាំងអស់ចុះមកងូតទឹកបរិភោគអាហារ ហើយក៏ត្រឡប់ឡើង

ទៅធ្វើការដូចដើម ។

ឯជីវ័យក៏បង្គាប់ឲ្យឡោស្រុកនឹងធៀកៅចាត់ចែងកងទ័ពទូកឲ្យព្រមបើកើតខ្យល់សលាត់ទមកកាលណា ក៏ឲ្យលើកទាហានទៅធ្វើការឲ្យទាន់ពេលហើយធ្វើសំបុត្របកទៅដល់ស៊ុនគួនឲ្យលើកកងទ័ពមកជួយ ៖ ឯអ៊ុយកាយក៏រៀបចាត់ចែងទូក ២០ យកស្មៅ នឹងចម្បើងផ្ទុកពេញទូកទាំងអស់ ហើយក៏យកខ្លាញ់ត្រីបាចសាចទៅលើស្មៅ នឹងចម្បើង ឲ្យទទឹកជាប្រាធេះក្ដើង ហើយយករំសេវនឹងស្ពាន់ធ័រ បាចសាចទៅលើស្មៅចម្បើងថែមទៀត គ្រប់ទាំង ២០ ទូក ហើយយកទង់ក្អែបខៀវដោតលើក្បាលទូកជាសំគាល់ លុះត្រៀមស្រេចហើយក៏ចតទូកចាំស្តាប់ជីវ័យមានបង្គាប់វេលាណា ក៏នឹងបានលើកចែវទៅដោយរហ័សវេលានោះ ៗ

កាលកាំឡៀងនឹងឆាំតេកបានសេចក្តីជាក់លាក់ហើយ ក៏ក្ដែងរក្សាឈួគុង, ឈួហោះទុកជាប់នឹងខ្លួន ហើយបង្គាប់ទាហានឲ្យរាំងមើលឈួគុង, ឈួហោកុំឲ្យវេះរត់រួចទៅបាន បើជីវ័យលើកទ័ពចេញទៅកាលណា នឹងបានធ្វើការតាមជីវ័យបង្គាប់ទុក ឯទាហានយាមល្បាតក៏ចូលទៅជំរាបជីវ័យថា ឥឡូវស៊ុនគួនលើកកងទ័ពមកឈប់នៅចម្ងាយផ្លូវពីចន្លាយនេះទៅប្រហែល ៨០០ ស៊ិន (៣២-គ.ម) ជីវ័យឮដូច្នោះក៏អរណាស់ទើបប្រើឡោស្រុកទៅប្រកាសប្រាប់ទាហានទាំងពួងថា ឲ្យរៀបចំទូកចម្បាំង

ទុកឲ្យព្រម  បើនឹងលើកចេញទៅកាលណាឲ្យទាន់ការ  បើកងណាមេណាធ្វើឲ្យយឺតយូរត្រូវប្រហារជីវិត  ឡោសុកក៏ចេញទៅប្រកាសតាមពាក្យជីវយីបង្គាប់  នោះនាយកងនាយទ័ពក៏ប្រុងប្រៀបរៀបចំព្រមស្រេចទាំងទូកនិងគ្រឿងសស្ត្រាវុធតាំងពីព្រលប់  លុះដល់ភ្លឺក៏មិនបានឃើញខ្យល់ធ្លាក់មកសោះ  ជីវយីក៏និយាយនឹងឡោសុកថា  ខុងបេងទៅធ្វើការអស់ ១ ថ្ងៃ ១ យប់ទៅហើយ  ក៏មិនបានឃើញមានខ្យល់សលាត៍ធ្លាក់មកសោះ ៗ  ឡោសុកថា  ខុងបេងធ្វើការនោះមុខជាកើត  លុះនិយាយគ្នាដូច្នោះហើយក៏នាំគ្នាចាំមើលពីព្រឹក លុះដល់ពេលយប់យាម ២ ផុយ  ក៏ឮស្នូរសំឡេងសន្ធឹកសន្ធាប់ពីខាងទិសអគ្នេយ៍  ជីវយីក៏នាំឡោសុកចេញទៅមើលកណ្ដាលវាល  ក៏មិនឃើញមានខ្យល់អ្វីសោះ  ស្ងប់ឈឹងទាំងអស់  លុះមួយស្របក់ក៏ធ្លាក់ខ្យល់ព្យុះសលាត៍បក់បោកមក ៗ  ជីវយីក៏មានអំណរណាស់  និយាយនឹងឡោសុកថា  ឯជម្រះប្រាជ្ញាខុងបេងដឹងតម្រាហៅខ្យល់ក្នុងអាកាសបានដូច្នេះ  និងរកអ្នកឯណាប្រៀបផ្ទឹមឲ្យត្រឹមស្មើគ្នា  ឧបមាដូចនឹងរាប់ផ្កាយតារាពនៅលើអាកាសបានទាំងអស់ពុំនោះនឹងញាំងព្រះមហាសមុទ្រ  ដ៏ជ្រៅឲ្យមើលឃើញរបស់ទាំងពួងបាន  បើយើងទុកខុងបេងឲ្យនៅតទៅខាងមុខ  ទុក្ខក៏នឹងមានដល់ស្រុកកាំងតាំងគង់អន្តរាយ  ត្រូវតែរិះគិតរកកលឧបាយសម្លាប់ខុងបេងចេញ  ទើបស្រុក

យើងនឹងបានសេចក្ដីសុខតទៅ លុះនិយាយហើយក៏បង្គាប់តេងហាងទឹង ឈើសេងឲ្យលើកទាហានម្នាក់ ១០០ ចេញទៅចាប់ខ្លួនខុនបែនសម្លាប់ ។ ឯឈើសេងក៏លើកទាហានស្រូតទៅចុះទូក លើកស្កាត់ទាំងមាត់ទន្លេ ថា បើឃើញខុនបែនទឹងចាប់ខ្លួនសម្លាប់ចេញ ។

ខណៈនោះខុនបែនដែលបានឃើញខ្យល់សលាតន៍ប្រាកបក់មកជាខ្លាំង ក៏សំឡឹងមើលទាហានទាំងពួង ឃើញកាន់ទង់ទឹងគ្រឿងពិការគ្រប់ដៃជាប្រក្រតីតាមបង្គាប់ខុនបែនក៏លបតែចុះពីលើកនពិធី ស្រូតរូតទៅកាន់កំពង់ទឹកដែលបានកំណត់ទុកឲ្យជូឡងមកទទួលនោះ ។ ទាហានទាំងអស់ក៏មិនបានសំគាល់ជាខុនបែនទឹងតែទេ ។ លុះតេងហាងទៅដល់កណ្ដាលផ្លូវ ទទួលខ្យល់សលាតន៍ប្រាកបក់មកយ៉ាងខ្លាំង តេងហាងក៏បង្ខំបរសេះឡើងទៅដល់ទីកនពិធី ឃើញទាហានទាំងពួងកាន់ទង់ប្រុងខ្លួនមិនមានកំរើក តេងហាងក៏ចុះពីលើសេះកាន់គ្រឿងឡើងទៅលើរាន ស្រាប់តែរកខ្លួនខុនបែនមិនឃើញសោះ ក៏ត្រឡប់ចុះមកសួរពួកទាហានដែលនៅក្នុងទីនោះថា ខុនបែនទៅឯណាទៅហើយ ? ។ ទាហានដែលកាន់ទង់ប្រាប់ថា ខុនបែនចុះទៅមុនលោកអម្បាញមិញទៅហើយ ។ តេងហាងក៏ចុះទៅដល់ដី ឡើងសេះបំផាយចុះមកវិញ លុះទៅដល់មាត់ទន្លេប្រទះនឹងឈើសេងក៏សាកសួរគ្នាទៅវិញទៅមកមិនបានសេចក្ដី ទទួល

មានកូនទាហានម្នាក់មកប្រាប់ថា កាលពេលព្រលប់ខ្ញុំបានឃើញទូកតូច ១ មកចតនៅក្បាលជ្រោយត្រង់ឆ្នេរខ្សាច់មាត់ទន្លេ លុះវេលាយាម ២ ជាយ ឃើញខុនបេនដើរមកចុះទូកនោះ ហើយចែវលឿនទៅទិសឯជើង តេងហានទីងឈីសេងក៏ចុះទូកហើយ បើកក្តោងញែកគ្នាតាមទៅ ។

ឈីសេងចែវតាមទៅទាន់ហើយ ស្រែកហៅខុនបេនឲ្យឈប់នៅសិន ហើយប្រាប់ថា ជីវយីឲ្យតាមមកអញ្ជើញទៅវិញ ។ ខុនបេនឮទាហានស្រែកហៅដូច្នោះ ក៏ឆ្លើយតបទៅវិញថា អ្នកឯងត្រឡប់ទៅប្រាប់ជីវយីវិញចុះថា ខ្យល់ដែលយើងសូត្រស្រែកហៅនោះបានធ្លាក់មកហើយ ឲ្យខំធ្វើការនឹងបូជឲ្យល្អចុះ ឯខ្លួនយើងនឹងលាជីវយីត្រឡប់ទៅស្រុកកាំងហៃសិន ដល់ថ្ងៃក្រោយសឹមត្រឡប់មកសួរជីវយីវិញ ។ ឈីសេងក៏ថែមថាឲ្យឈប់សិន ! ខ្ញុំនឹងជំរាបសេចក្តីដែលជីវយីបង្គាប់មកជាការសម្ងាត់ ។ ខុនបេនថា ដែលអ្នកមកនេះយើងក៏ដឹងជាមុនទៅទៀត គឺជីវយីរិះគិតទុកនឹងធ្វើអន្តរាយដល់យើង ។ ក៏ឲ្យជូឡុងមកចាំទទួល អ្នកឯងចូលវិលត្រឡប់ទៅប្រាប់ជីវយីចុះ បើមិនព្រមស្តាប់ខ្ញុំទេ ចូលមក នឹងរកកំឡាំងតនឹងយើងមិនបានទេ ។

ឈីសេងឃើញទូកខុនបេនមិនបានបើកក្តោង ក៏ឲ្យទាហានចែវ

ស្រុកតាមទៅ ៗ ជូឡុងឃើញឈើសេងតាមមកជិតក៏ស្រែកថា អញឈ្មោះជូឡុង បានទទួលពាក្យខុងបេងបង្គាប់ឲ្យអញឡើងមកទទួល វេលានេះខុងបេងក៏បាននិយាយហាមប្រាមខ្លួន ៗ មិនស្តាប់ បេះតែតាមមក ប្រុងនឹងធ្វើអន្តរាយខុងបេង បើយើងមិនយកធ្នូបាញ់ឲ្យស្លាប់ឥឡូវនេះទេ ទៀតពីចៅហ្វាយយើងនឹងស៊ុនគួនក៏ខឹងខុសអធ្យាស្រ័យគ្នាមិនស្រួល យើងក៏បាញ់ឲ្យតែល្មមដឹងថ្វីដៃចុះ ថាហើយក៏យឹតធ្នូបាញ់ត្រូវខ្សែក្តោង ដាច់ធ្លាក់ក្តោងចុះ ទូកឈើសេងក៏វិលត្រឡប់ស្ទើរតែនឹងភ្លុកលិច ជូឡុងក៏ឲ្យទាហានបើកក្តោងចេញទៅ ៗ

ឯឈើសេងលុះឃើញទូក តងហងតាមទៅទាន់ ក៏ប្រាប់អាចិសេចក្តីទាំងពួងឲ្យស្តាប់ ហើយថាជូឡុងនោះមានថ្វីដៃខ្លាំងពូកែណាស់ កាលគ្រាច្បាំងនៅវាលប័នបោនោះ ក៏បានសម្លាប់ទាហានចូចូអស់ជាច្រើន ដែលយើងនឹងតាមជិតដោយទៅមុខជាតស៊ូបឹងជូឡុងមិនបាន លុះប្រឹក្សាគ្នាហើយក៏ត្រឡប់ទៅប្រាប់ជីវយី តាមដំណើរដើមហេតុដល់ចប់សព្វគ្រប់ប្រការ ៗ ជីវយីបានឮដូច្នោះក៏ភ័យណាស់ហើយថា ជម្រះរិះគិតរបស់ខុងបេងនោះជ្រៅទូលាយឆ្ងាយណាស់ បើមិនគិតសម្លាប់ឲ្យហើយទេខ្លួនយើងក៏នឹងដេកធ្មេចភ្នែកមិនជិត ទុកមាដូចបន្ទាមុតជាប់ក្នុងដើមទ្រូង ៗ ឡោសុកក៏និយាយឃាត់ថា លោកកុំបង្ខិតគិតឲ្យកើតវិកវរឡើយ ចូរតាំង

ចិត្តខំគិតធ្វើការកំចាត់ចួចួចេញឲ្យបាន ឯការខាងខុងបេងនោះសឹមគិតតទៅជាឯក្រោយ ។

ខណៈកាលកើតខ្យល់ព្យុះសលាត់ទនោះ ដីវយើក៏បង្គាប់កាំឡេងឲ្យលើកទាហានទៅផ្លូវគោកដល់ដំបន់ប៉ូលីម ហើយឲ្យចូលលុកដុតចួចួ កាលបានឫក្សទឹងលើកទៅឲ្យសម្លាប់ឈ្មួតុងចេញ ហើយកាត់យកក្បាលសែនទង់ជ័យឲ្យជាអំណាចកងទ័ព ឯខ្លួនឈ្មួហោនោះឲ្យយកទុកប្រើធ្វើកជការខាងទ័ពទឹកទឹងបានធ្វើការ ឲ្យលីបងលើកទាហាន ៣ ពាន់ជាកងជំនួយកាំឡេង ហើយថៃស៊ូជូលើកទាហាន៣ ពាន់ខាងជើងគោកទៅដំបន់ហ័បហ៊ុយ ចាមវ៉ាយកាត់ទាហានចួចួកុំឲ្យលើកជំនួយមកបាន បើឃើញភ្លើងឆេះឡើងក្នុងកងទ័ពទូកចួចួ ត្រូវឲ្យមើលទង់ក្រហមជាសំគាល់ហើយ ឲ្យបង្ខំទាហានលើកមកប្រសព្វគ្នា កាំឡេង, លីបង ទឹងថៃស៊ូជួ ក៏លាទៅចាត់ចែងលុះបានឫក្សល្ងាចលើកញែកគ្នាទៅជាមុខកងទ័ពទូក ព្រោះជាផ្លូវឆ្ងាយ កាលកាំឡេងទឹងលើកទ័ពទៅនោះ ក៏ចាប់យកខ្លួនឈ្មួហោទៅប្រគល់ទុកក្នុងទ័ពទូក ហើយយកឈ្មួតុងទៅសម្លាប់ចេញ រួចកាត់យកក្បាលទៅសែនទង់ជ័យទើបលើកទ័ពទៅ ។

ដីវយើក៏ឲ្យឡេងថងលើកទាហាន ៧ ពាន់ទៅដំបន់អ៊ុឡេង បើ

ឃើញពន្លឺភ្លើងនៅដំបន់ហ៊ូលីមនេះឡើង ក៏ឲ្យទាហានចាំស្កាត់រាំ យកនឹងទ័ពចូឆូ ហើយឲ្យតាំងសិតលើកទាហាន ៣ ពាន់ទៅចូនបន្ទាយចូឆូនៅដំបន់ក្បែរស៊ឹងហ័ខឈ្លួន ហើយឃើញទង់សជាសំគាល់ ត្រូវលើកទាហានទៅប្រសព្វគ្នា កងមួយឲ្យកួយជៀងលើកទាហាន ៣ ពាន់ទៅដែនស្រុកហ័នយ៉ុង ឲ្យទាហានដោតទង់សជាសំគាល់ បើចុញទាល់ប្រការម្តេចនឹងបានជួយបំពេញជាជំនួយគ្នាទៅខាងតាំងសិត នាយទាហានទាំង ៣ កង ក៏លើកពលបែកញែកគ្នាទៅផ្លូវគោក តាមពាក្យជីវយីបង្គាប់ ។

ឯជីវយី ក៏ឲ្យអ៊ុយកាយសរសេរសំបុត្រជាកំណត់ពេលទៅដល់ចូឆូសេចក្តីថា ខ្ញុំបាទអ៊ុយកាយគិតបានឧកាសហើយ ព្រោះជីវយីប្រើខ្ញុំបាទឲ្យទៅទទួលទូកស្បៀងឯស្រុកហ៊ួនយ៉ុង ខ្ញុំបាទនឹងកាត់យកក្បាលនាយទូកដែលនាំស្បៀង នឹងទូកប្រចាំជូនមកជាជំនូនមហាឧបរាជ ក្នុងវេលាយប់យាម ២ ក្នុងថ្ងៃនេះ សុំឲ្យមហាឧបរាជចាំទទួលចុះ ហើយជីវយីឲ្យរៀបទូកចម្បាំង ៤ ផុកកូនទាហានដែលមានថ្វីដៃនឹងនាយទូកទាំង ៤ នាក់នោះ ឈ្មោះហ័នតុង , ជីវថាយ , ជីវឃឹម , ត័នចូ ឯទាហានទាំង ៤ នាក់នេះ ឲ្យនាំទូកចម្បាំងម្នាក់ ៣០០ រួមជា ១ ២០០ ទូក សម្រាប់ការពារអ៊ុយកាយចូលដុតភ្លើងនោះ បើឃើញសត្រូវមាន

កំឡាំងប្រការម្ដេច នឹងបានជួយច្បាំងឲ្យឡោសុក ឆ្មាំគេគនៅគ្រប់បន្ទាយ ៗ ជៀតៅឃើញជីវយើចាត់វែងទ័ពគោកទ័ពទឹកជាក្បួនមួនមាំ ដូច្នោះ កំគិតខ្លាចជីវយើជាច្រើន ៕

ខណៈនោះមានសំបុត្រស៊ិនគួនមកដល់ជីវយើសេចក្ដីថា ស៊ិនគួនឲ្យឡុកស៊ិនលើកទាហានជាកងមុខ ខ្លួនស៊ិនគួនជាទ័ពហ្លួង នឹងលើកជាជំនួយទៅផ្លូវអ៊ុយតេ ជីវយើឃើញសំបុត្រស៊ិនគួនដូច្នោះកំត្រេកអរណាស់ បង្គាប់ទាហានឲ្យយកដាវឡើងទៅចាំនៅលើកំពូលភ្នំឡាំពិនសាន ហើយដល់ពេលព្រលប់ឲ្យអុជដាវជាសំគាល់ កងទ័ពទូកនឹងបានលើកព្រមគ្នាចូលទៅ ។

ឯឡេវពីដែលតាំងទ័ពនៅបន្ទាយហៃខៅនោះ លុះបានឃើញខ្យល់សលាត័នធ្លាក់បក់មក កំតាំងចិត្តគិតទន្ទឹងមើលផ្លូវដូឡុងដែលទៅទទួលខុងបេង លុះឃើញឡេវគីលើកទ័ពទូកមកដល់ ហើយឡើងទៅជួបនឹងឡេវពីៗកំប្រាប់ថា យើងឲ្យដូឡុងទៅទទួលខុងបេងកំទៅមិនទាន់នៅមិនទាន់ឃើញត្រឡប់មកវិញសោះ នឹងជាប្រការម្ដេចកំឥតដឹងដំណឹងឡើយ ឡេវគីមិនទាន់នឹងតបឆ្លើយថាប្រការម្ដេច ទទួលឃើញដូឡុងនាំខុងបេងចូលទៅដល់ ឡេវពីកំមានចិត្តអរណាស់ ទើបសាកសួរថា លោកទៅធ្វើការអ្វីខ្លះ ? ៗ ខុងបេងថា នឹងឆ្លើយដំកបមិនទាន់ផ្លាកទេនាំឲ្យ

យុវការ ហើយសួរទៀតថា កិច្ចដែលខ្ញុំបង្គាប់ទុកនោះ បានរៀបចំ ជាស្រេចហើយ ឬមួយ ៖ ។ ទៀតឆ្លើយថា ការទាំងអស់បានរៀបចំ ទុកព្រមអស់ហើយ ។ ខុនបេងក៏ប្រើឲ្យជូឡុងលើកទាហាន ៣ ពាន់ ជូន ទន្ទេស្រួតកាត់ទៅពួនបង្កប់នៅជិតដំបន់ហ៊ួលឹម ពេលយាម ៣ ថ្ងៃនេះ កងទ័ពចូចូនឹងបែកទៅតាមផ្លូវនោះ អ្នកចូរលើកទាហានដោយកាត់ កណ្តាលទ័ព ពោះបើទាហានចូចូនវិនាសមិនអស់ ក៏គង់ស្លាប់ប្រហែល ពាក់កណ្តាលគង់នឹងបានសេះនឹងអាវុធជាច្រើន ។ ជូឡុងថា ដំបន់ ហ៊ួលឹមនោះជាផ្លូវបំបែក ២ អន្លើ ផ្លូវ ១ទៅស្រុកឡាំកុន ផ្លូវ១ទៅស្រុក កេងជីវ ខ្ញុំបាទមិនដឹងជាចូចូនឹងលើកទៅខាងផ្លូវណា ។ ខុនបេងថា ផ្លូវទៅស្រុកឡាំកុនជិតខាងកងទ័ពជីវយើ ទាហានជីវយើគង់នឹងដេញតាម មុខជាចូចូនឹងបែកទៅផ្លូវស្រុកកេងជីវ អ្នកចូរទៅចាំនៅផ្លូវនោះ ហើយ ឲ្យទៀវហ៊ុយលើកទាហាន ៣.០០០ ទៅបង្កប់នៅនឹងក្នុងព្រៃផ្លូវនឹងទៅ ដំបន់ហោលោកុក វេលាព្រឹកនេះភ្លៀងនឹងធ្លាក់ បើភ្លៀងរាំងហើយ ចូចូទៅដល់ដំបន់នោះនឹងឈប់សំរាកឲ្យទាហានដាំបាយស៊ី បើអ្នកបាន ឃើញផ្សែងភ្លើងកាលណា ក៏ឲ្យដេញទាហានចេញចោមរោមវាយកុំឲ្យ ដណ្តាំបាយឆ្អិនទាន់ ពោះបើនឹងវាយចូចូមិនបាន អ្នកក៏នឹងមានសេចក្តីគាប់ ប្រសើរព្រោះបានកាប់សម្លាប់ទាហានចូចូអស់ជាច្រើន ។ ជូឡុងនឹងទៀវ

ហ៊ុយទទួលពាក្យខុនបេងហើយ ក៏លើកទាហានចេញទៅ ។

ខុនបេងក៏ប្រើប៊ីតុក; ប៊ីហាង, លើកទាហានទូកទៅប្រចាំនៅតាមមាត់ទន្លេ ចាំចាប់ទាហានចូច្ចដែលរត់ចុះមក ហើយឲ្យឡៅគីនាំទូកចម្បាំងទៅតាំងនៅដំបន់ហូជៀងដែលជាទីសំខាន់ បើឃើញចូច្ចបែកទៅផ្លូវនោះលុមការដែលនឹងចាប់បានក៏ព្រួតចាប់ទុក មួយទៀតអ្នកនឹងបានការពារស្រុកកាំងហែផង ។ ឡៅគីនឹងនាយទាហានទាំងពួកនេះក៏ទទួលពាក្យខុនបេង ហើយលើកទូកចម្បាំងចេញគ្នាទៅ ។ ខុនបេងក៏និយាយនឹងឡៅពីថា ឲ្យលោកនាំទាហានទៅចាំមើលលើកំពូលភ្នំ ពេលយប់នេះដីវយឺនឹងធ្វើការបានសម្រេចហើយ ។

គួនអ៊ូ ឃើញខុនបេងប្រើអ្នកឯទៀតទៅធ្វើការតាមមុខងាររស់ហើយក៏គិតតូចចិត្តថា ខុនបេងមិនបានចាត់តែងប្រើខ្លួនទៅធ្វើការនៅទីកន្លែងណាមួយសោះ ទើបចូលទៅនិយាយនឹងខុនបេងថា ខ្លួនខ្ញុំបាទនេះបានចូលមកនៅធ្វើការនឹងឡៅពីជាបងក៏យូរហើយ តែរាល់ឡៅពីនឹងធ្វើការអ្វីក៏រមែងប្រើប្រាស់ខ្ញុំបាទឲ្យអាសាទៅធ្វើការមុនគេគ្រប់កន្លែង គ្រានេះលោកមានមន្ទិលសង្ស័យនឹងខ្ញុំបាទយ៉ាងម្តេចបានជាមិនប្រើទៅធ្វើការដូចគេទាំងពួងផង ។ ខុនបេងថា នៅមានទីសំខាន់មួយអន្លើ តែថាបើនឹងប្រើអ្នកឲ្យទៅធ្វើការនោះក៏នាំឲ្យមានមន្ទិលសង្ស័យ ។ គួនអ៊ូថា

លោកសង្ស័យដោយហេតុអ្វី ? ។ ខុងបេងថា ដែលយើងមន្ទិលសង្ស័យនឹងអ្នកនោះ ព្រោះហេតុថាកាលពីដើមអ្នកបានទៅនៅនឹងប្អូនៗ គឺបានអាណិតស្រឡាញ់ជួយទំនុកបំរុងអ្នកដោយអស់ពីចិត្ត ឯចិត្តរបស់អ្នកមានសេចក្ដីស័ត្យកតញ្ញូដឹងគុណគេ វេលាថ្ងៃនេះប្អូនបែកទ័ពត្រឡប់រត់ទៅតាមផ្លូវហ្វីយ៉ុង បើយើងនឹងឲ្យអ្នកទៅចាំបំរុងចាប់ប្អូននៅទីនោះ មុខជានឹងបាន បើជួបប្រទះមិនខានក៏គង់មិនសម្លាប់ ព្រោះអ្នកនឹងគិតដល់គុណដែលគេមានមកស្រាប់ ឃើញបានចំណាប់ហើយក៏ឲ្យរួចខ្លួនទៅជាអាសារតគារ ។ គួនអ៊ូថា ឯដម្រេះប្រាជ្ញារបស់លោកនោះជ្រៅទូលាយមែនណាស់ហើយ តែថាដែលប្អូនបានមានគុណូបការនឹងខ្ញុំបាទនោះ ខ្ញុំបាទក៏បានធ្វើការយកអាសារតបគុណប្អូនរួចជាស្រឡះព្រោះខ្ញុំបាទបានសម្លាប់ឆាទលៀវនឹងប៊ុនដីវជាទីតបគុណ បើលោកឲ្យខ្ញុំបាទទៅគ្រានេះ ហើយបានជួបប្រទះនឹងប្អូន ខ្ញុំបាទមិនបានកាត់ក្បាលប្អូនមកជូនលោកទេ សុំឲ្យលោកកាត់ក្បាលខ្ញុំបាទជំនួសវិញចុះ តែខ្ញុំបាទក្រែងប្អូននឹងមិនរត់ទៅតាមផ្លូវស្រុកហ្វីយ៉ុងនោះវិញ តើលោកនឹងមានប្រសាសន៍ដូចម្ដេចទៅទៀត ។ ខុងបេងថា បើអ្នកលើកទាហានទៅហើយមិនជួបប្រទះនឹងប្អូនទៅតាមផ្លូវនោះទេ ក៏ឲ្យប្រញាប់លើកទ័ពវិលមកវិញចុះ យើងនឹងកាត់ក្បាលរបស់យើងជាជំនួសក្បាលប្អូនឲ្យអ្នក លុះនិយាយ

ហើយក៏បង្គាប់ប្រើគួនអ៊ីឲ្យលើកទាហាន ៥០០ ទៅចាំស្កាត់នៅផ្លូវហ្វីយ៉ុន ព្រោះទីនោះជាផ្លូវ ២ រួមគ្នា ចិនទៅលើស្រុកកេងជីវ តែផ្លូវកោងឆ្ងាយជាងផ្លូវកាត់ដល់ ៥០០ សិន ឯផ្លូវកាត់នោះឆាប់ តែដើរលំបាក ព្រោះជាច្រកភ្នំ អ្នកចូរឲ្យទាហានជញ្ជូនយកចម្បើងនិងឧសទៅគរជាគំនរភ្លើងទុក នៅមាត់ផ្លូវកាត់ ឲ្យចូចូឃើញផ្សែងភ្លើង ក៏ចិនតែទៅតាមផ្លូវកាត់ ព្រោះជាផ្លូវត្រង់ ៗ គួនអ៊ីឬថា ចូចូនិងតែចៀសពីសេចក្ដីស្លាប់ ហេតុម្ដេចលោកត្រឡប់ថា ចូចូនឹងសំដៅទៅតាមផ្សែងភ្លើងនោះវិញ ៗ ខុងបេងតបថា ចូចូនោះជាមនុស្សឈ្លាសវៃណាស់ គង់ការល្បួងបញ្ឆោត បើឃើញផ្សែងភ្លើងហើយក៏គង់គិតថា ដើរយើងកែងធ្វើកលឲ្យទៅគរភ្លើងទុក មុខជាពួនបង្កប់ទ័ពស្កាត់ខាងផ្លូវធំវិញ ចូចូក៏គង់ទៅខាងផ្លូវដែលមានភ្លើង អ្នកចូរចាប់សម្លាប់ចេញ ហើយកាត់យកក្បាលមក ៗ គួនអ៊ីទទួលពាក្យខុងបេងហើយ ក៏នាំគួនប៉េង, ជីវឆង និងទាហាន ៥០០ លើកចេញទៅ ៗ

កាលគួនអ៊ីចេញទៅហើយ ឡេវពីក៏សួរខុងបេងថា ខ្ញុនលោកបានជ្រាបចិត្ត គួនអ៊ីថាជាមនុស្សមានសេចក្ដីសត្យកតញ្ញូ និងអ្នកមានគុណណាស់ ដែលលោកប្រើគួនអ៊ីទៅគ្រានេះ ទោះបីបានជួបនឹងចូចូមែន គង់គួនអ៊ីមិនធ្វើអន្តរាយ ព្រោះគិតដល់គុណូបការទាំងឡាយជាប្រាកដ ឯការដែលគិតមកហើយនឹងមិនអត់អំពើទៅឬ ? ៗ ខុងបេងតបថា ខ្ញុំ

បាទបានមើលផ្កាយសម្រាប់បុណ្យចូចូដាមហាទេពកដ កំឃើញនៅរុងរឿងជ្រះថ្លា ព្រោះជតាកសិបចូចូនៅមិនទាន់ជាចបានជាខ្ញុំក្លែងប្រើគួនអ៊ូទៅធ្វើការសឹកគ្រានេះ ដើម្បីទឹងឲ្យគួនអ៊ូសងគុណចូចូឲ្យអស់ទៅ គទៅមុខគួនអ៊ូទឹងបានធ្វើការគនឹងចូចូពេញដៃពេញជើង ។ ឡៀតពិបានឮដូច្នោះក៏កើតសេចក្ដីជ្រះថ្លាសរសើរដេម្រេះប្រាជ្ញាខុងបេងថា លោកគិតនេះហៅត្រូវពេកណាស់ៗ ខុងបេងក៏ទុកស៊ុនខៀនទឹងកាន់យ៉ុងឲ្យនៅរក្សាបន្ទាយហៃហៅ ហើយនាំឡៀតពិចុះទូកទៅចាំមើលកងទ័ពចូចូនៅទន្លេហៃហៅ ។

ឯចូចូនោះ តាំងចិត្តទន្ទឹងគិតមើលផ្លូវអ៊ុយកាយគ្រប់វេលា ៗ ជៀយ៉ុកក៏និយាយនឹងចូចូថា វេលាថ្ងៃនេះខ្យល់សលាត់នបក់មកខ្លាំងណាស់ សុំឲ្យលោករិះរាំងកងទ័ពយើងកុំឲ្យមានសេចក្ដីអន្តរាយ ។ ចូចូតបថា អ្នកកុំវិតក្កឡើយព្រោះទេសកាលនេះ ទោះបីខ្យល់សលាត់ននឹងបានមកក៏គិតបេទ បើនឹងមានហេតុគេទពុំដូកាលយ៉ាងណា ក៏លួមនឹងការពារបានៗ

ឯមនុស្សស្មិទអ៊ុយកាយ លុះទៅដល់ក៏ចូលទៅក្នុងបន្ទាយចូចូហើយជូនសំបុត្រទៅចូចូ ទទួលយកទៅមើលដឹងសេចក្ដីហើយ ក៏នាំទាហានចុះមកនៅក្នុងទ័ពទូក ដើម្បីចាំទទួលអ៊ុយកាយ ។

ឯជីវយ៉ លុះវេលាល្ងាចជិតបានថ្ងៃ ក៏ឲ្យយកខ្លួនឈួហោមកចងហើយសួរថា ហេតុម្ដេចបានជាឯងមកបញ្ឆោតអញ ឥឡូវអញនឹង

លើកកងទ័ពទៅនៅខ្ទះគ្រឿងទឹងសែនទង់ជ័យ អញឲ្យកាត់ក្បាលឯង សែនពីការយកឫក្សពារជ័យជំនះ ។ ឈ្មោះហោថា ការនេះកាំទ្បេងទឹង ឆ្នាំគេកក៏បានរួមគំនិតជាមួយគ្នា ទឹងខ្ញុំបានដែរ ហេតុម្តេចលោកមកសម្លាប់ តែខ្ញុំបាទម្នាក់ឯង មិនសម្លាប់អ្នកទាំងនោះបេញផង ។ ជីវយើថាឯកាំ ទ្បេងទឹងឆ្នាំគេកនោះ យើងប្រើឲ្យទៅបញ្ឆោតបៅហ្វាយឯង ទេតើ ខ្លួន ឯងទាំង ២ ទើបជារូបសេចក្តីដែលទុច្ចរិតទឹងអញ លុះនិយាយហើយឲ្យ សម្លាប់ឈ្មោះហោស្លាប់ហើយកាត់យកក្បាលសែនទង់ជ័យ លុះពេលព្រលប់ ជីវយើក៏ឲ្យអ៊ុយកាយនាំទូក ២០ ដែលរៀបដោតទង់ខៀវទុកនោះឲ្យបែរ បេញទៅ ។ អ៊ុយកាយក៏រៀបស្លៀកពាក់គ្រឿងប្រដាប់សម្រាប់ចម្បាំង គឺក្រឹសទឹងការុធ ហើយចុះទូកលើកទាហានជុតភ្លើងតាមគ្រប់ទូកទាំង ២០ ទៅគ្រង់ជំរង់សេកផេក ។

ខណៈនោះទទួលកើតព្យុះខ្យល់សលាត់នខ្លាំងណាស់ ព្រះច័ន្ទក៏ភ្លឺ ច្បាស់លើវេហាស៍ ។ ចូច្ចូបេញទៅអគ្គិយសន្ទនាទៅក្បាលទូកជួបជុំសេនា ទាហាន ក្រឡេកមើលទៅឃើញរលកធំ ៗ រណ្តំគ្នាតាមខ្យល់ចូច្ចូគាន ពិតាលស្ទើដោយប្រមាទថា ជីវយើម្តងនេះមុខជាមិនរួចពីដៃយើងទេទទួល មានទាហានម្នាក់ចូលមកប្រាប់ថា ឥឡូវអ៊ុយកាយឲ្យទូកតូចមួយចូលមក ប្តឹងថា ខ្លួនអ៊ុយកាយនាំទូកស្បៀងមកហើយ ចូច្ចូឮដូច្នោះក៏ត្រេក

អរណាស់ និយាយថា អ៊ុយកាយមកគ្រានេះ គឺជាបុណ្យវាសនារបស់យើង ដោយទេពតាបញ្ញាលចិត្តនាំឲ្យមក ទទួលក្រឡេកឃើញទូកទាំងនោះវែរជិតមក ចៀយ៉ុកមើលទៅឃើញទូកទាំងនោះ ស្រាលអណ្តែតខ្ពស់លើទឹក ក៏មានសេចក្តីសង្ស័យនិយាយនឹងប៉ូចូថា គ្រានេះ ខ្យល់សលាតនកំពុងមកជាខ្លាំង ដែលនឹងទុកចិត្តឲ្យអ៊ុយកាយចូលមកដល់តែម្តងមិនបាន ខ្លាចក្រែងជាកលឧបាយមានរឿងហេតុនឹងកែខែកទ្រណាស់ ។ ប៉ូចូសួរថា អ្នកឃើញហេតុយ៉ាងម្តេច ? ។ ចៀយ៉ុកថា ឯធម្មតាទូកផ្ទុករបស់ធ្ងន់មានតែពៀប ឥឡូវមើលទៅឃើញស្រាលអណ្តែតលើទឹកខ្ពស់ទាំងអស់ ទូកអ៊ុយកាយនេះមុខជាមានហេតុហើយ បានជាខ្ញុំបាទឃាត់ហោក ។ ប៉ូចូយល់ឃើញត្រូវ ទើបប្រើប៊ុនផេងចេញទៅឃាត់កុំឲ្យចូលមក ប៊ុនផេងនឹងទាហានប្រហែល១៤-១៥ នាក់ ក៏ចុះទូកតូចចេញទៅស្រែកឃាត់ថា មហាឧបរាជឲ្យមកហាមឃាត់ថា ឲ្យទូកអ៊ុយកាយបតទុកពីឆ្ងាយសិន កុំអាលចូលមក ព្រោះជាវេលាកណ្តាលយប់ ។ លុះជាផុតពាក្យ ទាហានអ៊ុយកាយក៏យឹតធ្នូបាញ់មក ត្រូវស្មាស្តាំប៊ុនផេងដួលចុះ ហើយថយទូកទៅកន្លែងអុចផាវជាសញ្ញាឡើង អ៊ុយកាយបានឮស្នូរផាវអុចជាសញ្ញាដូច្នោះ ក៏ឲ្យបោកចង់ជាសញ្ញាឡើងទៀត ទទួលខ្យល់ព្យុះសលាតនបក់មកខ្លាំង

ទូកទាំង ២០ ក៏បើកក្តោងតាមខ្យល់ចូលទៅដុតភ្លើងឡើង ហើយលឿន ប៉ះនៅលើគ្នា ចូលទៅទន្ទិចនឹងផែទ័ពចូចូ ។

---

## សាមកុកខ្សែ ៤៣

តាំងពីអ៊ុយកាយដុតទ័ពវ៉ាកូចូបែក ចូចូរត់ឡើងគោកទៅប្រទះនឹងជូឡុង. ទៀវហ៊ុយ, គួនអ៊ូ. ចូចូឲ្យហាយិនទៅឈរស្រុកឡាំកុន ចូចូលើកទ័ពទៅស្រុកហ៊ូតោ ហាហង៉ ហាយិន, ហាស៊ុនលើកចូលស្រុកឡាំកុន ។

---

ឯទាហានចូចូឃើញភ្លើងឆេះជាប់ឡើងលើទូកខ្មាន កំនាំគ្នាប្រាប សាចទឹករំលត់ភ្លើងជាច្រូលច្របល់ តែជាខ្យល់បក់មកជាខ្លាំងណាស់ ឃើញជាទប់ទល់ពុំឈ្នះ ព្រោះជាប់សាច្រវ៉ាក់ប្រទាក់ខ្សែគាបរឹងជាផែទាំងអស់ ភ្លើងក៏ឆេះពលជាលពេញទៅទាំងទូកផែ ឯអ៊ុយកាយក៏នាំទាហានប្រហែល ៩ នាក់ឬ១០នាក់ចុះទូកចូលទៅ ប៉ិនទឹនវ៉ាប់ចូចូសម្លាប់ចេញ ៗ ចូចូក៏គ្រវីដំបងទិនគ្រប៉ីដេញទាហានឲ្យចូលលត់ភ្លើង ។ ក៏កាន់តែឆេះពលឡើង ទាហានទាំងតួងធន់ទឹងភ្លើងមិនបានក៏ស្លុះរត់ទៅ ចូចូស្រែកឲ្យយកទូកតូច ៗ បំរួងមនុស្សឡើងគោក គ្រឡេកមើលទៅបន្ទាយគោក ភ្លើងក៏ឆេះឡើងជាច្រើនអន្លើ ក៏រឹតតែភ័យខ្លាំងណាស់ លុះភ្លើងពលឆេះទៅដល់ទូកខ្មានដែលចូចូនៅ ទទួលឃើញទៀវលៀវយកទូកមកទទួលចូចូ ។ក៏ចុះទូករត់ទៅឡើងលើគោក ។

អ៊ុយកាយកាន់ក្របីអង្គុយលើក្បាលទូក ក្រឡេកឃើញប្អូនពាក់អាវក្រហមរត់ចេញពីភ្លើង ចុះទូកប្រញាប់រត់ឡើងទៅលើគោក ក៏ឲ្យទាហានស្រួតទូកចូលទៅហើយស្រែកថា អាប្អូនអាឯងរត់ទៅណា ៗ ប្អូនឮដូច្នោះក៏រត់តែស្ទុតកន្ទុំចិត្ត ទៀវលៀវឃើញអ៊ុយកាយតាមមកក៏យិតធ្នូបាញ់ទៅត្រូវអ៊ុយកាយធ្លាក់ទៅក្នុងទឹក ទៀវលៀវក៏នាំប្អូនឡើងទៅដល់មាត់ច្រាំង ឃើញកង់ទ័ពភ្ញាក់ផ្អើលច្រួលច្របល់មិនបានជាក្បួនទ័ព ទៀវលៀវ ក៏បង្គាប់ឲ្យយកសេះ១មកឲ្យប្អូនជិះហើយនាំទាហានស្រួតរត់ទៅ ។

ឯហ័នតុងដែលនាំទូកចម្បាំង៣០០ លុះទៅដល់ក៏ចំរុលទូកទាំងអស់ចូលទៅតាមចន្លោះទូកខ្មាន ទទួលបានឮសំឡេងមនុស្សនៅក្នុងទឹកស្រែកឲ្យជួយ ក៏ចាំបានថាសំឡេងអ៊ុយកាយ តាំងតែដេញទាហានប្រញាយលោតហែលទឹកទៅស្រង់គ្រាហ៍ឡើងមក ហើយទាញកន្ត្រាក់ព្រួញដកចេញពីស្មាបាន ចុងព្រួញក៏បាក់ជាប់នៅក្នុងសាច់ ហ័នតុងយកចុងក្រចីវះផ្តួចខ្វះយកចុងព្រួយដែលបាក់នោះបាន ហើយយកក្រៅហែករុំបួសនោះ រួចហ័នតុងក៏ដោះអាវខ្លួនឲ្យអ៊ុយកាយពាក់ ។

ខណៈកាលភ្លើងឆេះទូកខ្មាននោះ នាយទាហានដែលឃុំនាំទូកចម្បាំងម្នាក់ ៣០០ ជីវឃីឌក៏លើកទូកចម្បាំងទាំង ៣០០នោះ ជាជំនួយហ័នតុងចូលទៅទៀត ចំណែកខាងត័នប៊ូក៏ឃុំទូកចម្បាំង ៣០០ វាយប្រសព្វ

ចូលតាមចន្លោះទូកខ្មានពីម្ខាងខាងលិចដីវផាយក៏នាំទូកចម្បាំង ៣០០វាយប្រសព្វពីទិសឯកើត ។ ក្នុងខណៈនោះទូកចម្បាំងដីវយីទឹងទៀតកៅ មានឈើសេន, គេនហានជាប៉ែកស្តាំនឹងឆ្វេង ដីវយីទៅដល់បន្ទាយក៏វាយប្រសព្វចូលទៅព្រមគ្នា ។ ឯភ្លើងដែលឆេះនោះ បើកលទៅដល់ទីណាក៏ឆេះជាប់នៅទីនោះ ។ ទាហានដីវយីតាមពីក្រោយភ្លើងចូលទៅដុតបន្ទមឲ្យឆេះពលតទៅទៀត ខ្យល់ព្យុះខ្លាំងភ្លើងរឹតតែឆេះខ្លាំងពេលអណ្តាតពលជាប់ពេញគ្រប់ទូកខ្មាន ទាហានដីវយីក៏ចូលប្រកាប់ជាប់ក្បែរភ្លើងពីលើខ្យល់ ទាហានបួនក៏ប្រួលប្របល់ពមកគតដៃ ណាក់យទឹងភ្លើងទាំងសងខាង ខ្លះក៏ត្រូវកាំបួរបួសពិការស្លាប់ ខ្លះក៏ជាប់នៅកណ្តាលភ្លើងឆេះឡើងពេលស្លាប់លើផែ ខ្លះក៏បែរទៅលោតទឹកធ្លាក់ស្លាប់ជាប់លើគ្នាទឹងគណនាគ្រាកប់ពុំបាន ។

ឯកាំឡេងមេទ័ពគោកខាងដីវយី កាលចូលទៅដុតស្បៀងក្នុងបន្ទាយហ្លួមឆេះអស់ហើយ លើថង់ក្រឡេកឃើញពន្លឺភ្លើង ក៏លើកទាហានជំនួយចូលទៅដុតបន្ទាយជាលំជាប់គ្នាទៅទៀត កាំឡេងទឹងលើបនក៏បានពាក់កាប់សម្លាប់កងទ័ពពេញស្លាប់ជាច្រើនណាស់ ។ ឯតាំងស៊ុតទឹងក្បួនដៀងក៏ឲ្យទាហានយកភ្លើងដុតរបន្ទាយ ទាហានបួនគ្រប់ទាំង ៤ ទិស ពួកកងទ័ពបួនក៏ស៊ុតច្បាំងតាល់តែរបួសពិការស្លាប់ទឹងកប់ពុំអស់

សល់អំពីនោះក៏រត់បែកបាក់អស់ទៅ ។ ប៊ូឆូទីងទៀវលៀវនៅសល់ទាហានប្រហែល ១០០ ប្លាយ កាលរត់ឡើងទៅលើមាត់ច្រាំង ក៏តាំងតែខំស្រូតចូលទៅរកបន្ទាយគោក កាលបើចូលទៅដល់បន្ទាយណា ភ្លើងក៏កាលដាលទៅដល់ទីនោះឆេះឡើងជាច្រើនបន្ទាយ ប៊ូឆូនាំទាហានទាំងឡាយរត់ទៅចូលបន្ទាយដែលភ្លើងមិនឆេះ ។

កាលប៊ុនឆេងត្រៀវព្រញត្រឡប់មកវិញ បានឃើញភ្លើងឆេះបន្ទាយទ័ពទឹកគ្រប់ទូកខ្មាន ។ មកាយរត់ចេញបាន ក៏ទៅជួបទីងប៊ុន ផង ហើយនាំគ្នាឡើងទៅលើច្រាំងបានទាហានប្រហែល ៥០ នាក់ ក៏រត់ប្រពួនប្រញាក់ទៅជួបទីងប៊ូឆូ ។ ក៏សួរទៀវលៀវថា យើងទីងរត់ទៅទីណាទើបរួចពីភ័យអន្តរាយនេះ ។ ទៀវលៀវឆ្លើយថា ឡេលោករត់ទៅផវដ៍ឋបន់ហ៊ូលីមទើបទីងរួចភ័យ ។ ប៊ូឆូក៏រៀសរៃនាំទាហានទាំងនោះរត់ចេញទៅ លុះរៀបទីងទៅដល់ដ៍ឋបន់ហ៊ូលីមក៏ឮសំឡេងស្រែកហោទទ្ទីមពីខាងត្បូងស្ដាំ ប៊ូឆូក៏ភ័យស្លុតស្មារតី ។

ឯលីបង់លើកទ័ពទៅដល់ជិតក៏ស្រែកថា អាប៊ូឆូឯងរត់ទៅណា ? អញជាទាហានស៊ុនគួនមកពួនចាំស្កាត់នៅទីនេះ អញនឹងប្រឡេះយកក្បាលអាឯងឲ្យបាន ប៊ូឆូឮដូច្នោះក៏ភ័យណាស់ ឲ្យទៀវលៀវកមកតទល់ពីក្រោយ ខ្លួនប៊ូឆូក៏សុះបណ្ដាយទៅមុខ ក្រឡេកទៅឃើញ

ក្មេងនេះគគឹកគគុកក្នុងទីផ្សារដែលទីនោះជាសន្ធឹកណាស់ មិនដឹងទៀសទៅទិសណា ឮសំឡេងទាហានម្នាក់ស្រែកចុះមកពីលើក្ដីថា អញឈ្មោះឡេងថង លើកកងទ័ពមកបង្ក្រាបចាំនៅទីនេះ ចាំយកជីវិតឯងហើយ ប្អូនភ័យណាស់ ទទួលស៊ុឡេងបរសេះទៅទាន់ហើយស្រែកថា មហាចោរជកុំខ្លាច ហើយស៊ុឡេងក៏បរសេះជ្រែកទៅមុខ ចូលក្រលុកតដៃនឹងឡេងថង់ជាប់គ្នា មិនទាន់ចាញ់ឈ្នះ ស៊ុឡេងក៏ស្ទុះបំពារនាំយកប្អូនចេញទៅមុខបាន ។

ឯម៉ាអៀននឹងទៀវគី ដែលប្អូនឲ្យទៅតាំងបន្ទាយនៅដំបន់លីមយ៉ុងនោះ ឃើញបន្ទាយប្អូនក្មេងនេះ ក៏លើកទាហាន ៣០០០ ស្រូតមកជួយ ទទួលជួបប្រទះគ្នាកណ្ដាលផ្លូវ ប្អូនក៏មិនសូវភ័យណាស់ បានធូរស្រឡះក្នុងចិត្ត ឲ្យម៉ាអៀននឹងទៀវគីនាំទាហាន ១០០០ នាំផ្លូវទៅមុខ, ឯទាហាន ២០០០ ទៀត ប្អូនឲ្យនៅការពារពីក្រោយ ម៉ាអៀន, ទៀវគីក៏នាំទាហាន ១០០០ នាំមុខប្អូនទៅ ចម្ងាយផ្លូវប្រហែល ១០០ សិន (៤ គ.ម) បានឮសំឡេងកងទ័ពស្រែកហ៊ោសន្ធាប់ពីមុខ នាយទាហាននោះស្រែកប្រាប់មកថា ខ្លួនអញឈ្មោះតាំឡេង លើកទ័ពមកចាំឯងនៅទីនេះ អញនឹងចាប់ពួកអាកំណាចទាំងអស់សម្លាប់ចេញ ។

(នៅមានត)

## ផ្នែកកំណាត់និងប្រវត្តិការណ៍

### វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

### ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អតិនិទ្រ គុ. ដែលដេកលក់ក្រៃពេក ។ *អតិនិទ្រាលុ* គុ. ដែលមានកិរិយាដេកលក់ក្រៃលែង ។

អតិនិភ្ឫតម ក្រិ. វិ. ដោយអាថិកំបាំងក្រៃលែង ។

អតិនិឃ្ឫណ គុ. សាហាវក្រៃលែង ។

អតិនិទ៌យ គុ. ដែលឥតមានសេចក្ដីអាណិតក្រៃលែង ។

អតិនិព៌ន្ធេន ឬ និព៌ន្ធតស៑ ក្រិ. វិ. ដោយអាការរួសរាន់ក្រៃលែង ។

អតិនិម៌ថន នបុំ. កិរិយាក្វារ ( សមុទ្រទឹកដោះ ) ក្រៃលែង ។

អតិនិវ៌តិន គុ. ដែលប្រៈព្រឹត្តផ្ទុយនឹងក្រៃលែង, ដែលប្រព្រឹត្តផ្ទុយ ( សុជីវធម៌ ) នឹងក្រៃលែង ។

អតិនិះស្វត្វ នបុំ. ភាពនៃបុគ្គលឥតទ្រព្យនឹងក្រៃលែង, សេចក្ដីក្រីក្រក្រៃលែង ។

អតិនិវ្ឫត គុ. ដែលប្រព្រឹត្តបានក្រៃលែង, ដែលមានទុក្ខរលត់ហើយក្រៃលែង, ដែលរីករាយក្រៃលែង ។

( នៅមានត )